**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# យន្តការនៃការដោះស្រាយវិវាទដោយសន្តិវិធី ក្នុងក្របខណ្ឌអន្តរជាតិ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **ហយ ហុនស៊ីវុធ**

**ហួត គឹមវទ្យ**

សាស្ត្រាចារ្យណែនាំ

លោក **អ៊ឹង រដ្ឋា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ហាយ ហុនស៊ីខុង** និង **ហួត គីមខេង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលសិក្សាក្នុងឆ្នាំ ២០១៦ និងបញ្ចប់ឆ្នាំសិក្សាឆ្នាំ ២០២០។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ លោកអ្នកមានគុណទាំងពីរជាទីគោរព ជាទីស្រឡាញ់នៃកូន ដែលបានលះបង់គ្រប់យ៉ាងទាំងកម្លាំកាយ និងកម្លាំងចិត្ត ដែលបានទំនុបបម្រុងដល់កូនគ្រប់បែប គ្រប់យ៉ាងដោយមិនបានគិតពីភាពនឿយហត់ រហូតដល់កូនបានបញ្ចប់ការសិក្សាកំរិតមធ្យមសិក្សាទុតិយភូមិទទួលបានជោគជ័យ ព្រមទាំងបានជំរុញ និងបានលើកទឹកចិត្តដល់កូនឲ្យបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សានៅរាជធានីភ្នំពេញ។

សូមសំដែងនូវការគោរពដ៏ខ្ពង់ខ្ពស់ផងដែរ ចំពោះថ្នាក់ដឹកនាំ លោកគ្រូនឹងអ្នកគ្រូសាស្ត្រាចារ្យ ដែលបានបង្ហាត់បង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចូលរួមចំណែកបណ្តុះនូវធនធានមនុស្សដ៏មានសារៈសំខាន់ណាស់ នៅក្នុងការអភិវឌ្ឍជាតិ ដែលធ្វើឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹងប្រកបដោយក្តីរីករាយបំផុត៖

- ឯកឧត្តម **លុយ ចន្ធា** ដែលជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានសម្រួលដល់ការសិក្សារបស់យើងខ្ញុំតាមរយៈការរៀបចំវិន័យយ៉ាងល្អទៅលើសាកលវិទ្យាល័យមួយនេះ។
- ជាពិសេស សូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ លោកសាស្ត្រាចារ្យ **អ៊ឹម រដ្ឋា** ដែលជាសាស្ត្រាចារ្យប្រកដដោយសមត្ថភាពនឹងគុណធម៌ខ្ពស់ បានផ្តល់កិត្តិយសធ្វើជាគ្រូណែនាំ ទាក់ទងការចងក្រងសារណារបស់យើងខ្ញុំឲ្យកាន់តែប្រសើរ។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខ និងកតញ្ញូកតវេទីចំពោះអ្នកមានគុណទាំងអស់ ហើយយើងខ្ញុំសូមគោរពជូនពរ អ្នកមានគុណ លោកគ្រូនឹងអ្នកគ្រូសាស្ត្រាចារ្យទាំងអស់ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

ក្នុងរយៈពេលបួនឆ្នាំកន្លងមក គឺជាពេលវេលាមួយដ៏សែនមានតម្លៃបំផុតសម្រាប់និស្សិតទាំងឡាយ ក៏ដូចយើងខ្ញុំទាំងពីរនាក់ផង ដែលបានទទួលការអប់រំ ទាំងផ្លូវកាយផ្លូវចិត្ត និងចំណេះដឹង។ យើងខ្ញុំបាទ ដែលជានិស្សិតនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមានក្ដីសោមនស្សរីករាយយ៉ាងខ្លាំង ដែលមានឱកាសសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទស្ដីពី"**យន្តការនៃការដោះស្រាយវិវាទដោយសន្តិវិធីក្នុងក្របខណ្ឌអន្តរជាតិ**"។ យើងខ្ញុំបានស្រាវជ្រាវ ដោយយកចិត្តទុកដាក់ និងបកស្រាយចម្ងល់នានា ក្នុងគោលបំណង គឺពង្រីកការយល់ដឹងក្នុងវិស័យនីតិអន្តរជាតិសាធារណៈ ដែលខំប្រឹងប្រែងកន្លងមក។

ជាការពិតណាស់ សភាពការណ៍ពិភពលោកបន្តវិវឌ្ឍផ្លាស់ប្តូរយ៉ាងឆាប់រហ័សនឹងពិបាកប៉ាន់ស្មានបានរីឯបញ្ហាជម្លោះនៅក្នុងទំនាក់ទំនងអន្តរជាតិតែងតែកើតមានភាពតឹងតែងឡើងៗជាញឹកញាប់ដោយមិនអាចជៀសវាងបានឡើយ។ បញ្ហានេះកើតឡើងក៏ដោយសារភាគីជម្លោះប្រកាន់នូវជំហររៀងៗខ្លួនដើម្បីផលប្រយោជន៍និងការគ្រប់គ្រងធនធានអ្នកដទៃ។ ដូច្នេះនៅក្នុងកិច្ចការស្រាវជ្រាវនេះគឺបកស្រាយ និងស្វែងរកនូវដំណោះស្រាយដោយសន្តិវិធីឬតាមនីតិវិធីច្បាប់អន្តរជាតិ ពោលគឺការស្វែងរកនូវសន្តិភាព និងស្ថេរភាពក្នុងពិភពលោក។

ចំពោះលទ្ធផលនៃការចងក្រងប្រធានបទនេះឡើង យើងខ្ញុំបានខិតខំស្វែងរកគ្រប់ឯកសារពាក់ព័ន្ធសំខាន់នានាទាំង ឯកសារជាតិ នឹងអន្តរជាតិមកធ្វើជាទឡ្ហីករណ៍ដើម្បីឲ្យខ្លឹមសារកាន់តែប្រសើរ។ ចំណុចដែលគួរកត់សំគាល់ គឺឯកសារដែលទាក់ទងរួមមាន លិខិតបទដ្ឋានគតិយុត្ត នឹងករណីសិក្សា មានការបកប្រែពីភាសាអង់គ្លេសទៅខេមរភាសាមានពាក្យបច្ចេកទេសជាច្រើន។ ដូច្នេះការបកឲ្យចំអត្ថន័យមានភាពខ្វះខាតមួយចំនួនដែលជាហេតុធ្វើឲ្យខ្លឹមសារនៃការស្រាវជ្រាវមិនមានលក្ខណៈគ្រប់ជ្រុងជ្រោយដល់អ្នកអាននឹងអ្នកស្រាវជ្រាវ។ បន្ថែមពីលើនេះ យើងខ្ញុំសង្ឃឹមថា សារណានេះ និងក្លាយទៅជាឯកសារជំនួយស្មារតីក្នុងការសិក្សាស្រាវជ្រាវ និងជាគន្លឹះជួយបំភ្លឺផ្លូវដល់និស្សិតជំនាន់ក្រោយ នឹងអ្នកអានជាក់ជាមិនខានឡើយ។

ជាចុងក្រោយនេះ យើងខ្ញុំសូមស្វាគមន៍យ៉ាងរីករាយ និងរង់ចាំទទួលជានិច្ចនៅមតិរិះគន់ និងកែលម្អក្នុងគោលបំណងស្ថាបនា ពីសំណាក់និស្សិតរួមជំនាន់ អ្នកស្រាវជ្រាវ នឹងមិត្តអ្នកអានទាំងអស់ ដែលចាប់អារម្មណ៍ឬស្រឡាញ់លើការសិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធនិងវិស័យមួយនេះ៕

# មាតិកា

ទំព័រ


តារាងសម្គាល់អក្សរកាត់.......................................................iv

សេចក្តីផ្តើម .......................................................០១

ជំពូកទី១

សញ្ញាណទូទៅនៃវិវាទក្នុងទំនាក់ទំនងអន្តរជាតិ

ផ្នែកទី១៖ ការបង្កើតទំនាក់ទំនងរវាងរដ្ឋនឹងរដ្ឋ .......................................................០៤

១.១.ការកកើតរដ្ឋ.......................................................០៥

១.២.ការភ្ជាប់និងកាត់ផ្តាច់ទំនាក់ទំនងការទូត.......................................................០៦

ផ្នែកទី២៖ មូលហេតុនៃវិវាទរវាងរដ្ឋនឹងរដ្ឋ.......................................................០៨

២.១.និយមន័យ .......................................................០៩

២.២.មូលហេតុចំបងដែលនាំឲ្យមានវិវាទ .......................................................០៩

២.២.១.ផលប្រយោជន៍សេដ្ឋកិច្ច.......................................................០៩

២.២.២.ផលប្រយោជន៍ទឹកដី .......................................................១១

២.២.៣.ជាតិនិយម .......................................................១១

២.២.៤.វិវាទសាសនា.......................................................១៣

ជំពូកទី២

យន្តការនៃការដោះស្រាយជម្លោះអន្តរជាតិ

ផ្នែកទី១ ៖ ដំណោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ.......................................................១៥

១.១.ការចរចា .......................................................១៦

១.១.១.ការចរចានៃជម្លោះ.......................................................១៦

១.១.២.ភាតព្វកិច្ចបង្ខំឲ្យចរចា ( ផ្តោតទៅលើមូលដ្ឋានគតិយុត្ត ) .......................................................១៦

១.១.៣.មុខងារនៃការចរចាដោះស្រាយជម្លោះ .......................................................១៧

១.១.៤.ខ្លឹមសារនៃការបង្ខំឲ្យចរចា .......................................................១៧

១.១.៥.បែបបទនៃការចរចា .......................................................១៨

១.២.ដំណោះស្រាយវិវាទដោយពឹងពាក់អន្តរាគមន៍ពីតតិយភាគី.......................................................១៨

១.២.១.ការបញ្ចុះបញ្ចូលភាគី ( Good Offices ) និង សន្ធានកម្ម ( Mediation ) .......................................................១៩

១.២.១.១.ការបញ្ចុះបញ្ចូលភាគី ( Good Offices ) .......................................................១៩

១.២.១.២.សន្ធានកម្ម ( Mediation ) ..................................................................២០
១.២.២.ការអង្កេត ( Inquiry ) និង ការផ្សះផ្សា ( Conciliation ) ........................................២០
១.២.២.១.ការអង្កេត ( Inquiry ) ......................................................................២០
១.២.២.២.ការផ្សះផ្សា( Conciliation ) ...............................................................២១
ផ្នែកទី២៖ ដំណោះស្រាយជម្លោះអន្តរជាតិតាមផ្លូវតុលាការ ....................................... ..២២
២.១.ដំណោះស្រាយជម្លោះតាមតុលាការមជ្ឈត្តិវិនិច្ឆ័យ ..........................................២២
២.១.១.ប្រភពដើមនៃតុលាការមជ្ឈត្តិវិនិច្ឆ័យ..................................................... .២២
២.១.២.រចនាសម្ព័ន្ធ........................................................................................២២
.. ២.១.២.១.ក្រុមប្រឹក្សារដ្ឋបាល...........................................................................២២
២.១.២.២.ការិយាល័យអន្តរជាតិ .......................................................................២៣
២.១.៣.ការបង្កើត និងសមត្ថកិច្ចរបស់តុលាការមជ្ឈត្តវិនិច្ឆ័យ ....................................២៣
២.១.៣.១.នីតិវិធីអាជ្ញាកណ្ដាល.........................................................................២៣
២.១.៣.២.ថវិកានិងថ្លៃឈ្នួល ...........................................................................២៤
២.១.៤.សេចក្ដីសម្រេចតុលាការមជ្ឈត្តវិនិច្ឆ័យ.......................................................២៤
២.២.ដំណោះស្រាយជម្លោះតាមផ្លូវតុលាការយុត្តធម៌ខន្តរជាតិ.....................................២៤
២.២.១.ការរៀបចំតុលាការ ICJ..........................................................................២៥
២.២.១.១.ការបង្កើតតុលាការយុត្តិធម៌អន្តរជាតិ ........................................................២៥
២.២.១.២.សមាសភាពតុលាការ ICJ .....................................................................២៧
ក.ចៅក្រមនៃតុលាការ................................................................................២៧
ខ.ចៅក្រមបណ្ដោះអាសន្ន ( ah hoc ) ...........................................................២៩
២.២.១.៣.វិសមិតភាព...................................................................................៣០
២.២.២.នីតិវិធី ..............................................................................................៣០
២.២.២.១.ដំណាក់កាលនីតិវិធីជាលាយលក្ខណ៍អក្សរ ................................................៣១
២.២.២.២.ដំណាក់កាលផ្ទាល់មាត់ .......................................................................៣២
២.២.២.៣.នីតិវិធីចែជន្យឬរជំទាស់បឋម ................................................................៣២
២.២.២.៤.វិធានការបណ្ដោះអាសន្ន .....................................................................៣២
២.២.២.៥.ការមិនបង្ហាញខ្លួន.............................................................................៣៣
២.២.២.៦.កិច្ចដំណើរការនីតិវិធីប្រឹក្សា ...................................................................៣៣
២.២.៣.សេចក្ដីសម្រេច.....................................................................................៣៤

២.២.៣.១.ការបកស្រាយសាលក្រម ....................................................................................៣៥

## ជំពូកទី៣

## ករណីសិក្សាស្តីពីដំណោះស្រាយវិវាទតាមរយៈតុលាការយុត្តិធម៌អន្តរជាតិ

ផ្នែកទី១ ៖ រឿងក្តីស្តីពីប្រាសាទព្រះវិហារ ក្នុងឆ្នាំ២០១៣...................................................៣៦
ផ្នែកទី២ ៖ រឿងក្តីស្តីពី ដែនដីកោះលីហ្គីតាន់ (Ligitan) នឹងកោះស៊ីប៉ាដាន់ (Sipadan)ក្នុងឆ្នាំ ២០០២ ...........................................................................................................៤០
សេចក្តីសន្និដ្ឋាន ........................................................................................................ ៤៧
អនុសាសន៍ ............................................................................................................... ៤៩
ឯកសារយោង
ឧបសម្ព័ន្ធ

# តារាងសម្គាល់អក្សរកាត់

- **ASEAN** : សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of Southeast Asian Nations)
- **ICJ** : តុលាការយុត្តិធម៌អន្តរជាតិ ( International Court of Justice)
- **NATO** : អង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង (The North Atlantic Treaty Organization)
- **PCA** : តុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល (Permanent Court of Arbitration)
- **PCIJ** : តុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិ (Permanent Court of International Justice)
- **TAC** : សន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (Treaty of Amity and Cooperation in Southeast Asia)

# សេចក្តីផ្តើម

ការកើតឡើងនូវវិវាទមិនអាចជៀសវាងបានទេ ចាប់តាំងពីរូបវន្តបុគ្គល នីតិបុគ្គល រហូតដល់ទំនាក់ទំនងរវាងរដ្ឋនឹងរដ្ឋ។ នៅពេលដែលភាគីចាប់ផ្តើមមានទំនាក់ទំនងគ្នា តែងតែមានជម្លោះដែលមិនអាចជៀសផុតបានឡើយ។ ជាការពិតណាស់ជម្លោះអន្តរជាតិដែលកើតមាន អាចជាជម្លោះផ្ទៃក្នុងឬក្រុមខាងក្រៅ។ នៅពេលមានជម្លោះម្តងៗ ភាគីនីមួយៗអាចស្វែងរកនីតិវិធីដោះស្រាយតាមរបៀបអតីតកាលគឺច្បាប់ព្រៃ (រដ្ឋមួយប្រើប្រាស់អំណាចគំរាមកំហែងទៅលើរដ្ឋតូច) ឬ ពឹងពាក់ភាគីណាមួយមកចូលអន្តរាគមន៍ ឬបច្ចុប្បន្នដោះស្រាយដោយសន្តិវិធី។ យ៉ាងណាមិញជម្លោះក្នុងសភាពការណ៍ពិភពលោកវិញ បន្តវិវឌ្ឍផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅឆាប់រហ័សប្រកបដោយភាពស្មុគស្មាញ ពិបាកប៉ាន់ស្មានបាន ទាំងកិច្ចការក្នុងតំបន់និងពិភពលោកបាននាំមកនូវវិនាសកម្មទាំងសេដ្ឋកិច្ច នយោបាយ និងសង្គម។ ជាក់ស្តែងបទពិសោធន៍វិវាទកន្លងមកមានផលប៉ះពាល់យ៉ាងធំធេងដែលនាំឲ្យមានសង្គ្រាមធំៗកើតឡើង (សង្គ្រាមលោកលើកទី១ សង្គ្រាមលោកលើកទី២នឹងសង្គ្រាមត្រជាក់) ការអនុវត្តនយោបាយជៀតជ្រែកចូលកិច្ចការផ្ទៃក្នុងឬការដាក់ទណ្ឌកម្ម នយោបាយ ឬសេដ្ឋកិច្ច ជាដើម។ វិបត្តិដែលបានកើតឡើងមក ប្រសិនបើភាគីជម្លោះដោះស្រាយដោយសន្តិវិធីតាមរយៈយន្តការចំបងៗដូចជា ដំណោះស្រាយជម្លោះក្រៅផ្លូវតុលាការ ឬក៏បញ្ហាទាំងនោះបញ្ជូនទៅតុលាការអន្តរជាតិដោះស្រាយក្នុងករណីជាប់គាំងការទូត។ ដូច្នេះការបង្កឲ្យមានការព្រួយបារម្ភ លែងជាបញ្ហាដ៏ធំទៀតហើយទៅលើសន្តិភាព ស្ថិរភាពនិងសន្តិសុខ ក្នុងតំបន់និងពិភពលោក។

ដោយមានបំណងឆ្លុះបញ្ចាំងបែបនេះហើយ ទើបកិច្ចការស្រាវជ្រាវនេះ នឹងលើកយកបញ្ហាគតិយុត្តមួយចំនួនដែលជាកម្មវត្ថុនៃការស្រាវជ្រាវមកបកស្រាយដូចខាងក្រោម៖

- តើយន្តការសំខាន់ៗអ្វីខ្លះក្នុងការដោះស្រាយវិវាទដោយសន្តិវិធីក្នុងក្របខណ្ឌអន្តរជាតិ?
  - ➢ តើវិធីសាស្ត្រពេញនិយមចំពោះរដ្ឋដើម្បីកំណត់ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការនិងក្នុងប្រព័ន្ធតុលាការអន្តរជាតិមានអ្វីខ្លះ?

គោលបំណងនៃប្រធានបទនេះគឺផ្តោតសំខាន់ទៅលើយន្តការសំខាន់ៗនៃការដោះស្រាយវិវាទដោយសន្តិវិធីក្នុងក្របខណ្ឌអន្តរជាតិ។ ដើម្បីជាជំនួយដល់ការបកស្រាយគំនិតប្រធានបទខាងលើនេះយើងគប្បីស្វែងយល់នូវពាក្យគន្លឹះប្រធានជាមុន។ ពាក្យ "យន្តការ" សំដៅលើ ក្បួនប្រាប់វិធី ឬរបៀបរបបដើម្បីសំរេចកិច្ចឬអំពើដែលត្រូវធ្វើ។ រីឯពាក្យ "វិវាទ" កំណត់ថា ដំណើរមិនយល់ស្របគ្នាទៅលើបញ្ហាអ្វីមួយ។ រីឯពាក្យ "សន្តិវិធី" សំដៅលើរាល់វិធីឬមធ្យោបាយដោយគ្មានការបង្កហិង្សា។ ចំពោះពាក្យ "ក្របខណ្ឌអន្តរជាតិ" សំដៅលើរដ្ឋភាគីនឹងរដ្ឋភាគីនៃជម្លោះ។ សរុបមកខ្លឹមសារខាងលើមានន័យថា ជារបៀបដើម្បីសំរេចការដោះស្រាយវិវាទទៅលើបញ្ហាមិនយល់ស្របគ្នាប្រកបដោយអហិង្សារវាងរដ្ឋភាគីនៃជម្លោះ។

យន្តការដោះស្រាយវិវាទដោយសន្តិវិធីក្នុងទំនាក់ទំនងអន្តរជាតិនេះ បានបញ្ជាក់យ៉ាងច្បាស់លាស់ក្នុង

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិសំខាន់ៗដែលបានចែងកន្លងមក។ ជាក់ស្តែងក្នុងមាត្រា២.(៣)នឹង(៤) មាត្រា ៣៣.(១) និង មាត្រា៩២ដល់មាត្រា៩៤គឺការដោះស្រាយជម្លោះតាមផ្លូវតុលាការ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ (UN Charter) ឆ្នាំ១៩៤៥។ បន្ថែមពីនេះមាន គោលការណ៍ទូទៅសម្រាប់ការដោះស្រាយវិវាទអន្តរជាតិនៅប៉ាស៊ីហ្វិក (General Act for the Pacific Settlement of International Disputes) ឆ្នាំ១៩៤៩ និង សេចក្តីប្រកាសម៉ានីលស្តីពីការដោះស្រាយជម្លោះអន្តរជាតិដោយសន្តិវិធី (Manila Declaration on the Peaceful Settlement of International Disputes) ឆ្នាំ១៩៨២ និងសេចក្តីប្រកាសស្តីពីគោលការណ៍នីតិអន្តរជាតិទាក់ទងនឹងទំនាក់ទំនងដោយមិត្តភាពនឹងសហការរវាងរដ្ឋយោងតាមធម្មនុញ្ញអង្គការសហប្រជាជាតិ (Declaration on Principles of International law Concerning Friendly Relations and Co-operation Among States in Accordance with the Charter of the United Nations) ឆ្នាំ១៩៧០។ រីឯក្នុងតំបន់អាស៊ីអាគ្នេយ៍វិញ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា "អាស៊ាន" បានកំណត់ក្នុងមាត្រា១.(១), .(២), .(៤) នឹងមាត្រា ២ ព្រមទាំងមាត្រា២២ ដល់២៨នៃជំពូកទី៨ ស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធី បានកំណត់ក្នុងធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ASEAN Charter) ឆ្នាំ២០០៨។ជាចុងក្រោយ សន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) ក្នុងឆ្នាំ១៩៧៦ កំណត់ក្នុងមាត្រា២ និងជំពូកទី៤ ស្តីពីការដោះស្រាយជម្លោះដោយសន្តិភាព (មាត្រា១៣-១៧)។

ដោយហេតុថាប្រធានបទនេះរាប់បញ្ចូលគ្នានូវយន្តការដោះស្រាយជម្លោះទាំងក្រៅនិងក្នុងផ្លូវតុលាការ ប្រធានបទនេះអាចនិយាយបានថាទំហំរបស់វារាងធំទូលាយបន្តិច។ ថ្វីត្បិតតែទំហំកិច្ចការស្រាវជ្រាវរាងធំទូលាយបន្តិចក៏ពិតមែន គឺគោលបំណងឲ្យអ្នកអានមានលក្ខណៈងាយស្រួលយល់និងក្តាប់ខ្លឹមសារទាំងមូលនៃប្រធានបទ។បើក្រឡេកមកមើលលើដែនកំណត់នៃកិច្ចការស្រាវជ្រាវនេះវិញគឺ លើកឡើងពីសញ្ញាណទូទៅនៃវិវាទក្នុងទំនាក់ទំនងអន្តរជាតិ ព្រមទាំងវិធីសាស្ត្រដោះស្រាយវិវាទទាំងក្នុងនិងក្រៅផ្លូវតុលាការ និងចុងក្រោយគឺលើកយកករណីសិក្សាចំនួនពីរដែលសំរេចដោយតុលាការយុត្តិធម៌អន្តរជាតិ។

ចំពោះប្រធានបទនេះអាចនិយាយបានថាជាប្រធានបទមួយដែលអ្នកសិក្សាផ្នែកនីតិសាស្ត្រតែងតែលើកមកពិភាក្សា រាល់ភាគីដែលមានជម្លោះទាំងរូបវន្តបុគ្គល ឬក្នុងក្របខណ្ឌអន្តរជាតិ។ ពោលគឺតែងតែស្វែងរកនូវដំណោះស្រាយដោយសន្តិវិធី។ ដូច្នេះសារណាមួយនេះដែលទាក់ទងនិងការដោះស្រាយវិវាទអន្តរជាតិដោយសន្តិវិធី បានផ្តល់នូវចំណេះដឹងកំរិតមូលដ្ឋានដល់សិស្សនិស្សិតនឹងអ្នកស្រាវជ្រាវទាំងអស់ ដើម្បីជាឯកសារជំនួយស្មារតីក្នុងកិច្ចការស្រាវជ្រាវដែលមានខ្លឹមសារទាក់ទង។ បន្ថែមពីនេះសារណានេះក៏ជាពុទ្ធិសំរាប់ផ្តល់នូវចំណេះដឹងទូទៅដល់សាធារណៈជនដែលមានចំណាប់អារម្មណ៍លើផ្នែកនីតិអន្តរជាតិសាធារណៈផងដែរ។

ក្នុងវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ បានធ្វើការដកស្រង់យកពីប្រភពជាច្រើន។ចំពោះទិន្នន័យចម្បងគឺដកស្រង់ចេញពី ឯកសារជាតិនឹងអន្តរជាតិ ផ្តោតទៅលើច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសៀវភៅជាដើម។រីឯ

ទិន្នន័យបន្ទាប់បន្សំគឺ ដកស្រង់ចេញពីសារពត៌មានជាតិនិងអន្តរជាតិ តាមរយៈអ៊ីនធឺណិត នឹងគេហទំព័រមួយចំនួនដែលត្រឹមត្រូវនឹងទទួលយកបាន។ នៅក្នុងរចនាសម្ព័ន្ធនៃកិច្ចការស្រាវជ្រាវនេះ ត្រូវបានបែងចែកជា**៣**ជំពូកធំៗដូចតទៅ៖

- **ជំពូកទី១៖ស្តីពីសញ្ញាណទូទៅនៃវិវាទក្នុងទំនាក់ទំនងអន្តរជាតិ** សំដៅទៅលើការកកើតនៃរដ្ឋ ការភ្ជាប់និងកាត់ផ្តាច់ទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ ព្រមទាំងមូលហេតុខ្លះៗដែលនាំឲ្យមានវិវាទ។
- **ជំពូកទី២៖ស្តីពីយន្តការនៃការដោះស្រាយជម្លោះអន្តរជាតិ** គឺបកស្រាយយន្តការដោះស្រាយជម្លោះដែលពេញនិយមតាមរយៈក្រៅប្រព័ន្ធតុលាការនិងតាមផ្លូវតុលាការ។
- **ជំពូកទី៣៖ករណីសិក្សាស្តីពីដំណោះស្រាយវិវាទតាមរយៈតុលាការយុត្តិធម៌អន្តរជាតិ** ផ្តោតសំខាន់លើរឿងក្តីចំនួនពីរគឺ៖ **ទី(១)** ស្តីពីការបកស្រាយសាលដីកាប្រាសាទព្រះវិហារ ក្នុងឆ្នាំ២០១៣ និង **ទី(២)** ស្តីពីដែនដីកោះស៊ីប៉ាដាន់ (Sipadan) នឹង កោះលីហ្គីតាន់ (Ligitan) រវាងប្រទេសម៉ាឡេស៊ីនឹងឥណ្ឌូនេស៊ី ក្នុងឆ្នាំ ២០០២។

ដូច្នេះប្រធានបទនេះនិងធ្វើការបកស្រាយលម្អិតទៅតាមជំពូកនីមួយៗដូចតទៅ៖

# ជំពូកទី១
# សញ្ញាណទូទៅនៃវិវាទក្នុងទំនាក់ទំនងអន្តរជាតិ
## ផ្នែកទី១៖ ការបង្កើតទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ

ពាក្យថា "រដ្ឋ" គឺជាតួអង្គទី១នៃនីតិអន្តរជាតិ ហើយមានតែរដ្ឋម្នាក់ឯងទេ ដែលមានអធិបតេយ្យ។ រដ្ឋមានឥទ្ធិពលខ្លាំងណាស់ ដោយសារ រដ្ឋជាអ្នកបង្កើតតួអង្គដទៃទៀតដែលតួអង្គទាំងនោះសុទ្ធតែជាតួអង្គក្លាយ ដែលបានមកពីរដ្ឋទាំងអស់។ មួយវិញទៀត រដ្ឋបានកកើតយូរណាស់មកហើយ គឺរដ្ឋទំនើបបានកើតឡើងនៅសតវត្សទី ១៦ ចំណែកឯអង្គការអន្តរជាតិ ទើបតែកើតនៅសតវត្សទី១៩ប៉ុណ្ណោះ។ រដ្ឋអាចកកើតឡើង តាមរយៈការចាប់យកដីគ្មានម្ចាស់ អបគមន៍ ការបំបែករដ្ឋ ការប្រមូលផ្តុំរដ្ឋ ការរំដោះខ្លួនចេញពីនឹមអាណានិគម។[1] ជាក់ស្តែងក្នុងក្របខណ្ឌអន្តរជាតិ រដ្ឋត្រូវមានធាតុផ្សំចំនួនបីយ៉ាងគឺ ប្រជាជន ទឹកដី និងរដ្ឋាភិបាល។ យ៉ាងណាមិញដើម្បីឲ្យរដ្ឋមួយមានអត្ថិភាពទៅបានទាល់តែរដ្ឋនេះមានធាតុផ្សំបន្ថែមទៀត គឺអធិបតេយ្យមួយយ៉ាងពិតប្រាកដ។[2] ក្នុងន័យទូទៅការទទួលស្គាល់រដ្ឋ ដោយរដ្ឋមួយផ្សេងទៀតគឺជាការឆ្លុះបញ្ចាំងឲ្យឃើញថា រដ្ឋនោះមានសិទ្ធិ និងសមត្ថកិច្ចគ្រប់បែបយ៉ាង ដើម្បីធ្វើទំនាក់ទំនងអន្តរជាតិតាមផ្លូវច្បាប់ជាមួយរដ្ឋដែលត្រូវបានទទួលស្គាល់ជាផ្លូវការ។[3]

បន្ទាប់ពីរដ្ឋមួយត្រូវបានគេទទួលស្គាល់ហើយ រដ្ឋតែងតែធ្វើទំនាក់ទំនងការទូតឬការចងសម្ព័ន្ធមិត្តនិងគ្នាដូចជាការធ្វើទំនាក់ទំនងជំនួញដូរ និងការផ្សព្វផ្សាយសាសនា វប្បធម៌ ជាដើម។ ជាការពិតណាស់កិច្ចការការទូតបានចាប់កំណើតឡើងតាំងពីការកកើតមានរដ្ឋមកម្ល៉េះ ហើយប្រជាជាតិគ្រប់ជាតិសាសន៍ពីជំនាន់អតីតកាលបានបង្កើតឡើងដើម្បីផលប្រយោជន៍សេដ្ឋកិច្ចគឺការជួញដូរទំនិញ។ រដ្ឋសម័យបុរាណដែលមានអរិយធម៌ជឿនលឿន មានប្រទេសក្រិច ប្រទេសឥណ្ឌា ប្រទេសចិនជាដើមបានបង្កើតទំនាក់ទំនងការទូតជាច្រើនទៅកាន់បណ្តាលប្រទេសដទៃតាមរយៈសកម្មភាពពាណិជ្ជកម្ម។ ជាច្រើនសម័យកាលមកការទំនាក់ទំនងរវាងរដ្ឋនឹងរដ្ឋ កាន់តែមានសារៈសំខាន់ខ្លាំងឡើងៗ ដែលធ្វើឲ្យទំនាក់ទំនងការទូត បានក្លាយជាកត្តាចាំបាច់បំផុតសំរាប់ការរីកលូតលាស់របស់ប្រទេសរៀងៗខ្លួន។

ក្នុងករណីមានវិវាទរវាងរដ្ឋភាគីនឹងរដ្ឋភាគី ឈានទៅរកភាពធ្ងន់ធ្ងរដែលអាចនាំឲ្យក្លាយជាសង្គ្រាមនោះកិច្ចការការទូតត្រូវបានកាត់ផ្តាច់ដោយឯកតោភាគីដោយមិនសុំការយល់ព្រមតែម្តង។

ក្នុងទំនាក់ទំនងការទូតសម័យទំនើប ការអនុវត្តនេះយោងតាមគោលបំណងនិងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិដែលបានបង្កើតឡើងតាំងពីឆ្នាំ១៩៤៥ ទាក់ទងនិងភាពស្មើរគ្នានៃរដ្ឋអធិបតេយ្យការរួមគ្នាថៃទាំសន្តិភាពនិងសន្តិសុខអន្តរជាតិ និងការផ្សព្វផ្សាយទំនាក់ទំនងមិត្តភាពក្នុងចំណោមប្រជាជាតិនានា។

---

[1] សាស្ត្រាចារ្យ អ៊ឹង រដ្ឋា,នីតិអន្តរជាតិសាធារណៈ,ទំព័រ១៦៩,បោះពុម្ពលើកទី៨

[2] សាស្ត្រាចារ្យ អ៊ឹង រដ្ឋា,នីតិអន្តរជាតិសាធារណៈ,ទំព័រ១០៤-១០៥,បោះពុម្ពលើកទី៨

[3] សាស្ត្រាចារ្យ ជុំ អ៊ុម, ទំនាក់ទំនងអន្តរជាតិ,ទំព័រ១៥៩,បោះពុម្ពលើកទី២

បច្ចុប្បន្នយើងឃើញមានក្នុងអនុសញ្ញាអន្តរជាតិសំខាន់ៗក្នុងអំឡុងឆ្នាំ១៩៦០ ការភ្ជាប់និងការផ្តាច់ទំនាក់ទំនងការទូតត្រូវបានកំណត់មានដូចជា អនុសញ្ញាវីយែនស្តីពីទំនាក់ទំនងការទូត(Vienna Convention on Diplomatic Relations) ឆ្នាំ១៩៦១ អនុសញ្ញាវីយែនស្តីពីទំនាក់ទំនងកុងស៊ុល(Vienna Convention on Consular Relations) ឆ្នាំ១៩៦៣ នឹងអនុសញ្ញាញ៉ូវយ៉កស្តីពីបេសកកម្មការទូតពិសេស(Convention on Special Missions) ឆ្នាំ១៩៦៩។ ឋានុក្រមនឹងអភ័យឯកសិទ្ធិនៃអនុសញ្ញាទាំងអស់នេះ គឺចូលរួមចំណែកដល់ការអភិវឌ្ឍទំនាក់ទំនងមិត្តភាពក្នុងចំណោមប្រជាជាតិនានាដោយមិនគិតពីប្រព័ន្ធរដ្ឋធម្មនុញ្ញនិងសង្គមនយោបាយខុសៗគ្នា។

### ១.១ ការកកើតរដ្ឋ

រដ្ឋអាចកកើតឡើងមានច្រើនរបៀបតាមរយៈការបង្កើតអង្គការនយោបាយរបស់ខ្លួនលើទឹកដីគ្មានម្ចាស់ ដោយប្រើវិធីនៃការកាន់កាប់ជាក់ស្តែងឬដោយគ្រាន់តែដោតទង់ជាតិរបស់ខ្លួនមុនគេ។ ប៉ុន្តែបច្ចុប្បន្ន ទឹកដីបែបនេះពុំមាននៅសេសសល់អ្វីទៀតទេ។ ដូច្នេះការបង្កើតរដ្ឋថ្មីអាចធ្វើទៅបានតាមរយៈអបគមន៍ឬតាមការបំបែករដ្ឋចេញពីគ្នាចំពោះរដ្ឋមួយដែលមានស្រាប់ឬ តាមការប្រមូលផ្តុំគ្នានៃរដ្ឋជាច្រើនៗធ្វើជារដ្ឋតែមួយដែលហៅថា រដ្ឋសហព័ន្ធ។ចំណែកឯការដកនឹមអាណានិគមចេញ ក៏អាចបង្កឲ្យមានការកកើតរដ្ឋថ្មីៗបានដែរ។

រីឯអបគមន៍ធ្វើឲ្យ ចំណែកណាមួយប្រជាជន ដែលរស់នៅលើទឹកដីរដ្ឋណាមួយដែលមានស្រាប់ទាមទារបង្កើត "រដ្ឋឯករាជ្យថ្មីមួយ" ចេញពីរដ្ឋចាស់នោះ។ អំពើនេះមានផលប៉ះពាល់ដល់គោលការណ៍នៃ បូរណភាពដែនដីរបស់រដ្ឋ។ ដូច្នេះវាមិនអាចឲ្យសហគមន៍អន្តរជាតិទទួលយល់ព្រមបានឡើយ។ឧទាហរណ៍ ការប៉ុនប៉ងធ្វើអបគមន៍របស់ខេត្តការតង់ហ្គា (Katanga) ដែលមានរ៉ែត្បូងច្រើនចេញពីប្រទេសកុងហ្គោ (Congo) ឆ្នាំ១៩៦០ និងខេត្តប៊ីយ៉ាហ្វ្រា (Biafra) ចេញពីប្រទេសនីហ្សេរីយ៉ា (Nigeria) ត្រូវទទួលបរាជ័យ (ក្នុងឆ្នាំ១៩៦៧-១៩៦៩) ដោយក្រុមប្រឹក្សាសន្តិសុខ បានចេញដំណោះស្រាយមិនទទួលស្គាល់អបគមន៍ទាំងនេះឡើយ។ ប៉ុន្តែអបគមន៍គឺជាកិច្ចការផ្ទៃក្នុងរបស់រដ្ឋ លើកលែងតែមានជម្លោះយោធាដែលមានលក្ខណៈអន្តរជាតិ ទើបអាចមានអន្តរាគមន៍ពីខាងក្រៅនិងជាពិសេសអាចនិយាយបានថាវាមានលក្ខណៈនយោបាយសុទ្ធសាធ។

ការបំបែករដ្ឋគឺ ការបែកខ្ចាត់ខ្ចាយរដ្ឋមួយដែលមានស្រាប់ទៅជារដ្ឋឯករាជ្យថ្មីៗពីរឬច្រើន ដែលស្ថិតនៅលើទឹកដីរបស់រដ្ឋចាស់នោះ។ ឧទាហរណ៍ជាក់ស្តែង ការបែកបាក់នៃអតីតសហភាពសូវៀតទៅជា១៥រដ្ឋដូចជាប្រទេស Armenia, Azerbaijan, Belarus, Estonia, Georgia, Kazakhstan, Kyrgyzstan, Latvia, Lithuania, Moldova, Russia, Tajikistan, Turkmenistan, Ukraineនិង Uzbekistan។

ចំពោះការប្រមូលផ្តុំរដ្ឋ គឺជាការច្របាច់បញ្ចូលគ្នារវាងរដ្ឋពីរ ឬច្រើនបង្កើតបានជារដ្ឋតែមួយ អនុវត្តច្បាប់តែមួយរួមគ្នា។ រដ្ឋដែលស្ម័គ្រចិត្តចូលបង្កើតជារដ្ឋតែមួយនោះ សុទ្ធតែជារដ្ឋឯករាជ្យម្ចាស់ការរៀងៗខ្លួន។ រដ្ឋទាំងនោះនឹងក្លាយជាសមាជិករដ្ឋសម្ព័ន្ធដែលបង្កើតឡើងថ្មីៗនេះ។ ឧទាហរណ៍សម្ព័ន្ធរដ្ឋដែលបាននាំគ្នាបង្កើតបានជាសហរដ្ឋអាមេរិក នៅឆ្នាំ១៧៨៧បានក្លាយទៅជារដ្ឋសហព័ន្ធថ្មីមួយ។

ការរំដោះខ្លួនចេញពីនឹមអាណានិគមគឺជាប្រភពដើមនៃការកកើតរដ្ឋឯករាជ្យថ្មីៗ នៅសតវត្សទី១៩ និង ២០មួយបែបដែរ។ គឺគោលការណ៍សញ្ជាតិ និងគោលការណ៍នៃសិទ្ធិស្វ័យសំរេចរបស់ប្រជាជនត្រូវបានប្រកាស នៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិនៅក្នុងមាត្រា១.២ និងមាត្រា៥៥។ គោលការណ៍ទាំងនេះជំរុញ ឲ្យប្រជាជនដែលស្ថិតនៅក្រោមការត្រួតត្រាជិះជាន់និងកេងប្រវ័ញ្ច អាចងើបតស៊ូ រំដោះខ្លួនចេញពីនឹមអាណានិគមនេះបាន។ឧទាហរណ៍ប្រទេសទីម័រខាងកើត ដែលបានងើបតស៊ូរំដោះខ្លួនចេញពីនឹមអាណានិគមរបស់ប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ១៩៩៩។[4]

សរុបមកបន្ទាប់ពីការកកើតរដ្ឋរួចមកហើយ រដ្ឋចាំបាច់ត្រូវមានធាតុផ្សំនៃរដ្ឋបូករួមទាំងអធិបតេយ្យ។ ដូចនេះរដ្ឋដែលទើបកកើតអាចចាប់ផ្តើមចេញសកម្មភាពការទូតទៅកាន់ប្រទេសដែលគាំទ្រខ្លួននិងប្រទេសដទៃទៀត ក្នុងគោលបំណងពង្រីកពង្រឹងកិច្ចសហប្រតិបត្តិការទៅលើ សេដ្ឋកិច្ច នយោបាយ សង្គមនិងវប្បធម៌របស់ខ្លួន។

## ១.២ ការភ្ជាប់និងកាត់ផ្តាច់ទំនាក់ទំនងការទូត

ការទូត ក្នុងភាសាក្រិច មានន័យថា "Diploma" ដែលត្រូវយកមកប្រើប្រាស់សំរាប់សំគាល់នូវសារម៉្យាងដែលរដ្ឋមួយប្រគល់ជូនជនតំណាងរបស់ខ្លួនយកទៅ ឲ្យរដ្ឋមួយផ្សេងទៀត។ ក្រោយមកពាក្យនេះក្លាយមកជាភាសាអង់គ្លេស "Diplomacy" ដែលបកប្រែមកជាភាសាខ្មែរជា កិច្ចការការទូតឬការងារការទូត។ កិច្ចការការទូត គឺជាឧបករណ៍ដ៏ចាំបាច់បំផុតនៅក្នុងទំនាក់ទំនងអន្តរជាតិ ដែលចូលរួមចំណែកយ៉ាងមានប្រសិទ្ធិភាពក្នុងការការពារ និងអភិវឌ្ឍន៍ប្រទេសជាតិនានា។ ប្រសិនបើវិស័យការទូតមានភាពជោគជ័យ នោះការអភិវឌ្ឍន៍ជាតិក៏មានការជោគជ័យដែរ។[5]

ការទូតគឺការប្រតិបត្តិនូវការធ្វើទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋតាមរយៈតំណាងជាផ្លូវការរបស់ខ្លួន។ កិច្ចការការទូតអាចរួមបញ្ចូលដំណើរការ ទំនាក់ទំនងការបរទេសទាំងអស់ រួមបញ្ចូលទាំងការរៀបចំគោលនយោបាយព្រមទាំងការប្រតិបត្តិកិច្ចការផងដែរ។ នៅក្នុងន័យទូលាយការងារការទូត និងនយោបាយការបរទេស របស់ជាតិមួយគឺមានន័យដូចគ្នា។[6]

ជាទូទៅការបង្កើតឬការភ្ជាប់ទំនាក់ទំនងការទូតរវាងរដ្ឋនិងរដ្ឋ អាចធ្វើទៅបានតាមលក្ខណៈបីយ៉ាងដូចខាងក្រោមនេះ៖ ទី(១) តាមរយៈការត្រូវរ៉ូវគ្នាខាងនយោបាយការបរទេស (២)តាមរយៈការប្រែប្រួលស្ថានភាពថ្មីនៃនយោបាយការបរទេសនៃរដ្ឋទាំងពីរ ទី(៣)តាមរយៈការជួយអន្តរាគមន៍ពីប្រទេសទីបីឬប្រទេសមានឥទ្ធិពលណាមួយ។ ឧទាហរណ៍ប្រទេសមួយចង់ភ្ជាប់ទំនាក់ទំនងការទូត ជាមួយប្រទេសមួយទៀតតែខ្លួនមិនចង់ចេញមុខដោយផ្ទាល់ទេ ដោយមូលហេតុផ្សេងៗ ក៏អាចពឹងឲ្យប្រទេសមួយផ្សេងទៀតដែលជិតស្និទ្ធិនឹងប្រទេសនោះដើម្បីឲ្យ

---

[4] សាស្ត្រាចារ្យ អ៊ឹង រដ្ឋា,នីតិអន្តរជាតិសាធារណៈ,ទំព័រ១៧០-១៧៣,បោះពុម្ពលើកទី៨

[5] អនុបណ្ឌិត នួន សុធិមន្ត ,ច្បាប់ការទូត,ទំព័រ១,បោះពុម្ពលើកទី១

[6] សាស្ត្រាចារ្យ ជុំ អ៊ឹម, ទំនាក់ទំនងអន្តរជាតិ,ទំព័រ២២៧,បោះពុម្ពលើកទី២

ជួយសំរុះសំរួលឬចរចាររហូតដល់ប្រទេសទាំងពីរឈានទៅដល់ការបង្កើតទំនាក់ទំនងការទូតជាមួយគ្នាបាន។ ប៉ុន្តែបច្ចុប្បន្ននេះការភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នាគឺមិនមានបញ្ហាអ្វីលំបាកទេ ប្រទេសភាគច្រើនស្ទើរតែទាំងអស់ អាចធ្វើការភ្ជាប់ទំនាក់ទំនងការទូតជាមួយគ្នាបានគ្រប់កាលទេសៈនិងគ្រប់ពេលវេលា។[7]

បន្ទាប់ពីរដ្ឋត្រូវបានប្រសូតមក ការទូតបានចាប់កំណើតឡើងតាំងពីការកកើតមានរដ្ឋមកម្ល៉េះ ហើយរដ្ឋទទួលស្គាល់គ្នាតាមរយៈការដាក់ទូតទៅវិញទៅមក។ យោងតាមច្បាប់អន្តរជាតិ បណ្តាប្រទេសឯករាជ្យទាំងឡាយមានសិទ្ធិពេញលេញក្នុងការទទួល និងបញ្ជូនអ្នកការទូតរបស់ខ្លួនទៅបណ្តាប្រទេសដទៃ និងទទួលយកអ្នកការទូតបរទេសមកប្រទេសខ្លួនវិញ។ ទំនាក់ទំនងការទូតត្រូវបានបង្កើតឡើយដោយរដ្ឋឯករាជ្យទាំងសងខាងយល់ព្រមបង្កើត។ ការសម្រេចភ្ជាប់ និងរក្សានូវទំនាក់ទំនងការទូតបែបនេះ ជាកិច្ចឆន្ទានុសិទ្ធិ និងនយោបាយសុទ្ធសាធរបស់ភាគីពាក់ព័ន្ធ។ ក្នុងនីតិអន្តរជាតិ ការទទួលស្គាល់ចំពោះរដ្ឋនូវសិទ្ធិប្រតិភូ ហើយសិទ្ធិនេះអាចមានលក្ខណៈសកម្មនិងអកម្ម។ សិទ្ធិសកម្មក្នុងន័យថា រដ្ឋដាក់ទូតបញ្ជូន តំណាងរបស់ខ្លួនទៅប្រទេសបដិសណ្ឋាកិច្ច ដែលគេហៅថា រដ្ឋម្ចាស់ផ្ទះ និងសិទ្ធិអកម្មមានន័យថា រដ្ឋម្ចាស់ផ្ទះមានសិទ្ធិទទួលអ្នក តំណាងការទូតរបស់រដ្ឋដាក់ទូតឬហៅថារដ្ឋបញ្ជូន។

ការបង្កើតទំនាក់ទំនងរមេងតែងជួបប្រទះនូវវិវាទដែលមិនជៀសបាន ដែលបង្ខំឲ្យរដ្ឋភាគីណាមួយសម្រេចបញ្ចប់ទំនាក់ទំនងនឹងគ្នាដោយឆន្ទានុសិទ្ធិរបស់ខ្លួនឬកិច្ចឯកតោភាគី។ ការផ្តាច់ទំនាក់ទំនងការទូត ត្រូវបានធ្វើឡើងតាមរយៈដីកាកោះហៅអ្នកការទូតឲ្យត្រឡប់ចូលប្រទេសវិញ ឬតាមរយៈការបណ្តេញចេញពីប្រទេសម្ចាស់ផ្ទះតែម្តង។ក្នុងករណីការធ្លាក់ចុះដុនដាបខាងទំនាក់ទំនងនយោបាយនិងសង្គ្រាមរវាងគ្នានឹងគ្នា ទំនាក់ទនងការទូតនិងត្រូវបិទទារជាស្វ័យប្រវត្តិ។ ឧទាហរណ៍ការកាត់ផ្តាច់ទំនាក់ទំនងការទូតរវាងប្រទេសឥណ្ឌា និងប្រទេសប៉ាគីស្ថាន នៅដើមឆ្នាំ២០០២។ រីឯមាត្រា៤១នៃធម្មនុញ្ញសហប្រជាជាតិ ចែងថាការកាត់ផ្តាច់ទំនាក់ទំនងការទូត គឺជាទណ្ឌកម្មមួយដែលអាចសម្រេចឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ប្រឆាំងនិងរដ្ឋណាមួយ ក្នុងករណីមានការគំរាមកំហែងដល់សន្តិភាព ការកាត់ផ្តាច់សន្តិភាព ឬការឈ្លានពាន។ដូច្នេះអង្គការអន្តរជាតិអាចស្នើសុំឲ្យសមាជិករបស់ខ្លួនបញ្ចប់ទំនាក់ទំនងការទូតជាមួយនិងរដ្ឋណាមួយទៀតបាន ប្រសិនបើមានករណីធ្ងន់ធ្ងរកើតឡើង។[8]

សរុបមកការភ្ជាប់ទំនាក់ទំនងការទូតត្រូវបានកំណត់ក្នុងអនុសញ្ញាវីយែនស្តីពីទំនាក់ទំនងការទូតឆ្នាំ ១៩៦១ ដែលបានកំណត់អំពីការបង្កើតទំនាក់ទំនងដោយសន្តិភាព យោងតាមមាត្រា ២,៤ និង៥។ រីឯការបញ្ចប់នៃផ្នែកការទូតនោះក៏បានបញ្ជាក់ថា បុគ្គលទូតត្រូវត្រឡប់មកប្រទេសរបស់ខ្លួនតាមរយៈមាត្រា ៩, ៤៣-៤៥។ បន្ថែមពីនេះការភ្ជាប់និងការផ្តាច់ទំនាក់ទំនងកុងស៊ុលត្រូវបានកំណត់ក្នុង អនុសញ្ញាវីយែនស្តីពីទំនាក់ទំនង

[7] សាស្ត្រាចារ្យ ដុំ អ៊ីម, ទំនាក់ទំនងអន្តរជាតិ,ទំព័រ២២៩,បោះពុម្ពលើកទី២

[8] សាស្ត្រាចារ្យ អ៊ឹង រដ្ឋា,នីតិអន្តរជាតិសាធារណៈ,ទំព័រ១៨៤-១៨៥,បោះពុម្ពលើកទី៨

កុងស៊ុលឆ្នាំ១៩៦៣។ ចំពោះមាត្រា២ នឹង៤ សំដៅលើការបង្កើតកុងស៊ុលឡើងរវាងរដ្ឋនឹងរដ្ឋ រីឯជំពូកទី២ ការបញ្ចប់មុខងារកុងស៊ុល (មាត្រា២៥-២៧) សំដៅលើការបញ្ចប់បេសកកម្មរបស់ខ្លួនលើទឹកដីប្រទេសម្ចាស់ផ្ទះ។ យោងតាមឋានុក្រមនិងអភ័យឯកសិទ្ធិនៃអនុសញ្ញាទាំងអស់ខាងលើនេះ មានគោលបំណងមិនបម្រើលើផលប្រយោជន៍បុគ្គលណាម្នាក់ទេ ប៉ុន្តែវាធានានូវការអនុវត្តមុខងារប្រកបដោយប្រសិទ្ធភាពរបស់តំណាងរដ្ឋនីមួយៗនៃអនុសញ្ញាទាំងនោះ។

ជាការពិតណាស់ប្រសិនណាផ្នែកការទូតនៃរដ្ឋនោះ មិនបានដោះស្រាយវិវាទដែលជាប់គាំងជាច្រើនឆ្នាំមកទេ។ វិវាទនិងចាប់ផ្តើមកកើតធំឡើងៗគឺមានន័យថារដ្ឋតែងតែប្រើប្រាស់កម្លាំងបាយជាជាងយន្តការសន្តិភាព ជាពិសេសក្នុងអំឡុងពេលសង្គ្រាមលោក(លើកទី១នឹងទី២) និងសង្គ្រាមត្រជាក់។

ផ្នែកខាងក្រោមនេះនឹងលើកយកការកកើតនៃវិវាទ និងកត្តាខ្លះៗដែលកើតនូវវិវាទយកមកបកស្រាយដូចខាងក្រោម៖

## ផ្នែកទី២៖ មូលហេតុនៃវិវាទរវាងរដ្ឋនិងរដ្ឋ

សភាពការណ៍ពិភពលោកបន្ទាប់ពីសង្គ្រាមលោកលើកទី១នឹងទី២បានបញ្ចប់ រួចបន្តសង្គ្រាមត្រជាក់ក៏បានបញ្ចប់នៅពេលការដួលរលំនៃសហភាពសូវៀត។ ពិភពលោកបន្តវិវឌ្ឍផ្លាស់ប្តូរយ៉ាងឆាប់រហ័សប្រកបដោយភាពស្មុគស្មាញ ពិបាបប៉ាន់ស្មានបាន និងពោរពេញទៅដោយគ្រោះថ្នាក់។ ថ្វីត្បិតតែក្នុងក្របខណ្ឌអន្តរជាតិមានអង្គការពិភពលោក គឺអង្គការសហប្រជាជាតិដែលបានបង្កើតឡើងតាំងពីឆ្នាំ១៩៤៥ ក្រោយសង្គ្រាមលោកលើកទី២ ដើម្បីថែរក្សា សន្តិភាព និងសណ្តាប់ធ្នាប់ពិភពលោក។ អង្គការសហប្រជាជាតិនេះបានបន្តសកម្មភាព គោលបំណងចំបងៗរបស់ខ្លួនក្នុងការគ្រប់គ្រង់សន្តិភាព ការពារសិទ្ធិមនុស្ស បង្កើតក្របខណ្ឌតុលាការអន្តរជាតិ និងលើកតំកើនសេដ្ឋកិច្ច និងអភិវឌ្ឍសង្គម ដែលមានរយៈពេលជាងប្រាំពីរទសវត្សចាប់តាំងពីការបង្កើតនៃអង្គការនេះមក។ បច្ចុប្បន្នអង្គការនេះបានបន្ថែមនូវដោះស្រាយថ្មីមានដូចជា បំម្រែបំប្រួលអាកាសធាតុ ជនភៀសខ្លួន និងការផ្តល់ជំនួយ។បន្ថែមពីនេះអង្គការសហប្រជាជាតិបានស្វែងរក ការដោះស្រាយជម្លោះយ៉ាងសស្រាក់ស្រាំរបស់ខ្លួន និងបន្តសកម្មភាពរបស់ខ្លួនយ៉ាងសកម្មតាមរយៈការបន្តបញ្ជូនកងកម្លាំងមួកខៀវការពារតំបន់ដែលបានកំណត់ ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ហើយក៏បានចូលរួមសកម្មភាពជាមួយដៃគូជំនាញពាក់ព័ន្ធជាច្រើន ដើម្បីលើកតំកើនជីវិតប្រជាជននៅក្នុងពិភពលោក ចាប់តាំងពីគ្រោះធម្មជាតិ វិស័យអប់រំ និងការលើកកំពស់ស្ត្រី រហូតដល់ការប្រើប្រាស់នូវថាមពលអាតូមិច (Atomic Energy) ដោយសន្តិភាព។[9]

ថ្វីត្បិតតែមានការចូលរួមយ៉ាងសកម្មពីអង្គការនេះក៏ដោយ វិវាទនឹងស្ថានភាពនៅក្នុងទំនាក់ទំនងអន្តរជាតិមានភាពតានតឹងនៅឡើយនៅពេលបច្ចុប្បន្នមានដូចជា៖ វិបត្តិផ្ទៃក្នុងប្រទេសវេណេស៊ុយអេឡា (Venezuela) វិបត្តិផ្ទៃក្នុងប្រទេសអាហ្វហ្គានីស្ថាន (Afghanistan) វិបត្តិផ្ទៃក្នុងប្រទេសយេម៉ែន (Yemen) វិបត្តិផ្ទៃក្នុងប្រទេសអេត្យូពី

[9] https://www.un.org/en/sections/issues-depth/global-issues-overview/index.html ,ចូលទស្សនាថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២០

(Ethiopia) វិបត្តិផ្ទៃក្នុងប្រទេសប៊ូគីណាហ្វាសូ (Burkina Faso) វិបត្តិផ្ទៃក្នុងប្រទេសលីប៊ី (Libya)។ បូករួមទាំងភាពតានតឹងរវាងប្រទេសមួយចំនួនមានដូចជា រវាងប្រទេសសហរដ្ឋអាមេរិក និងប្រទេសអ៊ីរ៉ង់ រវាងប្រទេសសហរដ្ឋអាមេរិក និងប្រទេសកូរ៉េខាងជើង រវាងប្រទេសឥណ្ឌា និងប្រទេសប៉ាគីស្ថានជម្លោះលើខ្សែបន្ទាត់ត្រួតពិនិត្យដែលបែងចែកតំបន់កាស្មៀរ (Kashmir) និង រវាងប្រទេសអ៊ុយក្រែន និងប្រទេសរុស្ស៊ី។[10]

## ២.១. និយមន័យ

យោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត "វិវាទ" សំដៅលើ ដំណើរទាស់ទែងគ្នា ឬដំណើរឈ្លោះប្រកែកគ្នា។ រីឯក្នុងភាសាឡាតាំង(Latin)វិញ បានបកប្រែថា "Conflictus"មានន័យថា ការប៉ះទង្គិចប្រយោជន៍ ការប៉ះទង្គិចទស្សនៈ បញ្ហាទំនាស់ដែលគំរាមកំហែងឲ្យកើតមានឡើងនូវភាពស្មុគស្មាញ។ បើក្រឡេកមកមើលនិយមន័យក្នុងវិទ្យាសាស្ត្រនយោបាយវិញពាក្យនេះដដែរសំដៅលើ រូបភាពនៃការតស៊ូដើម្បីអំណាច និងការមិនពេញចិត្តនូវស្ថានភាពសង្គមក្នុងភាពវិបត្តនិងអតុល្យភាព យោងតាមអ្នកប្រាជ្ញសង្គមវិទ្យាអាមេរិក លោក កូស៊ុរ (L.Kozer)។ ដូចគ្នានេះដែរការសិក្សាវិវាទវិទ្យា (Conflictology) បានពន្យល់ថា វិវាទជាការប៉ះទង្គិចនូវផលប្រយោជន៍ សកម្មភាព ទស្សនៈ គោលជំហរបស់បុគ្គលណាមួយដែលមានតួនាទីខ្ពស់នៅក្នុងវិស័យនយោបាយ ឬមួយនៅក្នុងសង្គម។ [11]ចំពោះលោក ហូ វ៉ុន ជុង (Ho Won Jeong) បានឲ្យនិយមន័យថា នៅពេលក្រុមពីរឬច្រើន ចូលរួមដើម្បីទាមទារទៅលើតម្លៃអ្វីមួយឬប្រកាសទទួលយក ឋានានុក្រម អំណាច នឹងធនធាន នោះការប៉ះពាល់ឬរំលាយលើគូភាគី គឺជាគោលដៅដើម្បីសំរេច។[12]

សរុបមក ពាក្យវិវាទមានអត្ថន័យទូលំទូលាយដែលការកំណត់នោះ មាននិយមន័យស្រដៀងគ្នាៗហើយអាស្រ័យលើបុគ្គលឆ្លើមៗជាអ្នកផ្តល់ឲ្យ។ក្នុងទំនាក់ទំនងអន្តរជាតិវិវាទមានទម្រង់និងលក្ខណៈស្មុគស្មាញហើយផ្សេងៗខុសពីគ្នាជាច្រើន យោងទៅតាមបរិបទនៃពេលវេលា ភាគីចូលរួម ទីតាំងភូមិសាស្ត្រ ជាដើម។ ជាការពិតណាស់វិវាទជាទូទៅមានកត្តាជាច្រើនៗ ដែលនាំឲ្យកើតមានឡើងទាំងក្នុងប្រទេសនឹងក្រៅប្រទេស។

## ២.២. មូលហេតុខ្លះៗដែលនាំឲ្យមានវិវាទ

ការកកើតឡើងនូវវិវាទមានកត្តាជាច្រើនៗរាប់មិនអស់ ចាប់តាំងពីរូបវន្តបុគ្គល ដល់នីតិបុគ្គល រហូតទៅដល់ផ្ទៃក្នុងប្រទេស និងរវាងរដ្ឋនិងរដ្ឋ។ ក្នុងចំណោមបញ្ហាទាំងនោះ វិវាទដែលកើតឡើងជាចំបងៗមានដូចជាសេដ្ឋកិច្ច នយោបាយ និងសង្គម។ ក្នុងផ្នែកនេះនិងលើកយកមូលហេតុខ្លះៗនៃវិវាទដែលទាក់ទងវិវាទរវាងរដ្ឋភាគីជម្លោះមកបកស្រាយដូចខាងក្រោម៖

### ២.២.១. ផលប្រយោជន៍សេដ្ឋកិច្ច

កត្តាសេដ្ឋកិច្ច ក៏អាចជាមូលហេតុមួយក្នុងចំណោមមូលហេតុចំបងធំៗដែលនាំឲ្យមានវិវាទកើតឡើងផង

[10] https://www.crisisgroup.org/global/10-conflicts-watch-2020 ,ចូលទស្សនាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០

[11] បណ្ឌិត ឈុន ណារ៉េត, សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ,ទំព័រ៣០៤-៣០៥,បោះពុម្ពលើកទី៣

[12] Sheriff F.Folarin. "Chapter Three Types and Causes of Conflict" ,ទំព័រ២,ចូលទស្សនានៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០

ដែរ ដោយហេតុថាជម្លោះសេដ្ឋកិច្ចគឺការជួយប្រទេសខ្លួនគ្រប់គ្រង់ទៅលើសេដ្ឋកិច្ចរបស់ប្រទេសដទៃទៀត។ បើក្រឡកមកមើលលើជំនាន់មុនបដិវត្តន៍ឧស្សាហកម្ម ផលប្រយោជន៍របស់រដ្ឋគឺការស្វែងរកនូវវត្ថុធាតុដើម ដូចជា មាស ប្រាក់ ឬសត្វពាហនៈ ដូចជាគោឬសេះជាដើម។ រហូតដល់សម័យទំនើបនេះ ធនធានដែលមានសារៈសំខាន់ដែលរដ្ឋចង់បាននោះគឺ ប្រេងសាំង សារធាតុរ៉ែ ឬវត្ថុធាតុដើមសំរាប់ប្រើប្រាស់ក្នុងសង្វាក់ផលិតម្ម។[13]

វិវាទសេដ្ឋកិច្ចរវាងរដ្ឋនិងរដ្ឋ អាចប្រែក្លាយជាសង្គ្រាមពាណិជ្ជកម្មដែលជាស្ថានភាពមួយដែលជម្លោះសេដ្ឋកិច្ចរវាងប្រទេសមួយនិងប្រទេសមួយទៀត កើតចេញពីការអនុវត្តគោលនយោបាយការពារនិយមខ្លាំង។ សង្គ្រាមនេះដែរ ត្រូវបានបង្កើតឡើងនៅពេលប្រទេសមួយ បង្កើនឬដាក់ពន្ធ/កូតាទៅលើទំនិញនាំចូលពីប្រទេសមួយ ឬច្រើន ហើយ ភាគីម្ខាងទៀតឆ្លយតបទៅវិញជាមួយនឹងទម្រង់បែបការពារនិយមដូចគ្នា។ ការបន្តអនុវត្តបែបនេះរវាងគ្នាទៅវិញទៅមក គឺនាំឲ្យសង្គ្រាមពាណិជ្ជកម្មកើតមានឡើង។

ជាក់ស្តែង ក្នុងករណីសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិនបានកើតឡើងនៅពេលសហរដ្ឋអាមេរិកនឹងចិនគំរាមកំហែងគ្នាទៅវិញទៅមក។ ជាការពិតណាស់ ក្នុងចំណោមការសន្យារបស់លោក ត្រាំ មានការសន្យាមួយដែលទាក់ទាញប្រជាប្រិយភាពអ្នកបោះឆ្នោត នៅក្នុងយុទ្ធនាការបោះឆ្នោតជ្រើសរើសប្រធានាធិបតី គឺបានមកពីការប្រកាសយ៉ាងច្បាស់លាស់ លើការជួយសង្គ្រោះសហរដ្ឋអាមេរិកពីឱនភាពពាណិជ្ជកម្ម ដែលប្រទេសនេះកំពុងប្រឈមពីការធ្វើពាណិជ្ជកម្ម ជាមួយនឹងដៃគូពាណិជ្ជកម្មរបស់ខ្លួនសព្វថ្ងៃ។ ប៉ុន្តែបន្ទាប់ពីលោក ត្រាំ ជាប់ឆ្នោត ហើយឡើងកាន់តំណែងនៅឆ្នាំ២០១៧ ឱនភាពពាណិជ្ជកម្មអាមេរិកកាន់តែធ្លាក់ដុនដាបជាងមុន និងបានធ្វើឲ្យចំនួននៃឱនភាពពាណិជ្ជកម្មកើនឡើងដល់ចំនួន ៨១០ ពាន់លានដុល្លារអាមេរិកនៅក្នុងពាណិជ្ជកម្មទំនិញ ដែលតួរលេខនេះបានឈានដល់កំណត់ត្រាខ្ពស់បំផុតក្នុងរយៈពេលប្រាំបួនឆ្នាំចុងក្រោយ។

លុះដល់ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១៨ សហរដ្ឋអាមេរិកបានប្រកាសដាក់បន្ថែមពន្ធគយលើផលិតផលនាំចូលជាបន្តបន្ទាប់ រួមមានបន្ទះសូឡា (៣០ភាគរយ), ម៉ាស៊ីនបោកគក់ (២០ភាគរយ), ដែកថែប (២៥ភាគរយ) និងអាលុយមីញ៉ូម (១០ភាគរយ)។ បន្ទាប់មកស្ថានភាពកាន់តែតឹងរឹងក្រោយពេលដែល តំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិកបានបញ្ចប់ការស៊ើបអង្កេតទៅលើចោរកម្មកម្មសិទ្ធិបញ្ញា លោកត្រាំបានបញ្ជាឲ្យតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិក(USTR) ដាក់ពន្ធលើទំនិញនាំចូលពីប្រទេសចិនដែលមានតម្លៃប្រហែល ៥០ពាន់លានដុល្លារអាមេរិកនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨។ [14]

ដោយសារចិនមិនអាចទ្រាំទ្រនឹងការតំលើកពន្ធលើការនាំចូលពីអាមេរិក ចិនបានប្រកាសពីការតម្លើងពន្ធទៅដល់ ២៥ភាគរយ លើផលិតផលរបស់សហរដ្ឋអាមេរិកចំនួន ១២៨មុខ ដោយមានរាប់បញ្ចូលទាំងសាច់ជ្រូកក ស្រា ផ្លែឈើ និងគ្រាប់ធញ្ញជាតិ។ ចាប់តាំងពីពេលនោះមក ការដាក់បន្ថែមពន្ធទៅវិញទៅមកចេះតែបន្តនិង ពង្រីក

[13] https://owlcation.com/social-sciences/The-Main-Reasons-For-War ,ចូលទស្សនាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០

[14] ជា មុយគីម,ជំនួយស្មារតី "ការពន្យល់ពីសង្គ្រាមពាណិជ្ជកម្មអាមេរិក-ចិន" វ៉ុល១ លេខទី២,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩,ទំព័រ១-២

បញ្ជីនៃមុខទំនិញដែលត្រូវស្ថិតតម្លៃពន្ធខ្ពស់ គ្រោបដំណើបស្នើរគ្រប់ទំនិញនាំចូល។

### ២.២.២.ផលប្រយោជន៍ទឹកដី

ក្នុងសម័យកាលមុនៗប្រទេសមួយអាចប្រកាសថាធ្វើសង្គ្រាម លុះត្រាមានតំរូវការដូចជា ត្រូវការដីច្រើនជាងមុនសំរាប់ប្រជាជនរស់នៅ ប្រើប្រាស់ក្នុងវិស័យកសិកម្ម ឬប្រើប្រាស់ក្នុងគោលបំណងផ្សេងៗទៀត។ យ៉ាងណាមិញដែនដីមួយចំនួនដែលធ្លាប់មានវិវាទអាចក្លាយជា តំបន់គ្មានប្រដាប់អាវុធ (Buffer Zones) រវាងសត្រូវដែលកើតមានឡើងក្នុងអំឡុងពេលណាមួយ។

រីឯក្នុងអំឡុងពេលសង្គ្រាមត្រជាក់ ពាក្យ "Proxy Wars" បានកើតឡើងក្នុងពេលវេលានោះ។ វាគឺជាជម្លោះប្រដាប់អាវុធដែលកើតឡើងដោយការប្រព្រឹត្តផ្ទាល់ដោយប្រទេសមហាអំណាចធំៗក្នុងទឹកដីប្រទេសដទៃ។ បន្ថែមពីលើនេះភាគីនីមួយៗត្រូវបានការគាំទ្រពីមហាអំណាចរៀងៗខ្លួនដូចជា កងកម្លាំងប្រដាប់អាវុធ សព្វាវុធ និងប្រព័ន្ធដឹកជញ្ជូនជាដើម។[15]

ជាក់ស្តែងវិវាទអន្តរជាតិត្រូវបានបង្ហាញឲ្យឃើញថា បន្ទាប់ពីការបង្កើតរដ្ឋអ៊ីស្រាអែលនៅឆ្នាំ១៩៤៨ សង្គ្រាមបានកើតមានឡើងជាច្រើនលើករវាងអ៊ីស្រាអែល និងបណ្តាប្រទេសអារ៉ាប់ ដែលប្រឆាំងនឹងការបែងចែកទឹកដីប៉ាឡេស្ទីនជាពីររដ្ឋ គឺរដ្ឋអ៊ីស្រាអែល សម្រាប់ពួកជ្វីហ្វ និងរដ្ឋប៉ាឡេស្ទីនដែលទឹកដីទាំងនោះជារបស់ប៉ាឡេស្ទីន។ជាការពិតណាស់ "សង្គ្រាមឯករាជ្យ" បន្ទាប់ពីមួយថ្ងៃនៃការប្រកាសបង្កើតរដ្ឋឯករាជ្យ ប្រព្រឹត្រទៅអស់រយៈពេលជាង ៩ខែ នៃការវាយប្រយុទ្ធគ្នា បណ្តាប្រទេសអារ៉ាប់ដែលមានកងទ័ពមកពីប្រទេសអេហ្ស៊ីប ហ្សកដានី លីបង់ ស៊ីរី និងអ៊ីរ៉ាក់ ព្រមទាំងកងកម្លាំងប្រដាប់អាវុធរបស់ប៉ាឡេស្ទីនរួមគ្នាទាមទារទឹកដីមកវិញនៅឆ្នាំ១៩៤៩។ប៉ុន្តែកងទ័ពនៃប្រទេសទាំងនោះបានសុខចិត្តចុះចាញ់ ហើយចុះកិច្ចព្រមព្រៀងបញ្ចប់សង្គ្រាម។ ការបង្កើតនៃកិច្ចព្រមព្រៀងនេះបានកំណត់នូវព្រំដែនបណ្តោះអាសន្នមួយ ដែលក្រោយមកត្រូវបានអង្គការសហប្រជាជាតិទទួលស្គាល់ជាព្រំដែនស្របច្បាប់របស់រដ្ឋអ៊ីស្រាអែល។[16] ខ្សែបន្ទាត់ព្រំដែននេះ ដែលគេតែងតែហៅថា "បន្ទាត់បៃតង" (Green Line/Ligne Verte) បានកាត់យកទឹកដីជាច្រើន ដែលកាលពីមុនត្រូវបានអង្គការសហប្រជាជាតិបែងចែកទុកធ្វើជាទឹកដីរដ្ឋប៉ាឡេស្ទីន។

### ២.២.៣. ជាតិនិយម

ជាតិនិយម ត្រូវបានផ្តល់និយមន័យយ៉ាងទូលំទូលាយ អាស្រ័យលើអ្នកប្រាជ្ញនិងបុគ្គលល្បីៗជាអ្នកផ្តល់ឲ្យ។ ក្នុងន័យនេះពាក្យ ជាតិនិយម គឺជាកម្លាំងចិត្តសាស្ត្រដែលចងប្រជាជនឲ្យរួបរួមគ្នាដោយសំគាល់គ្នាទៅវិញទៅមក។ វាក៏ជាអារម្មណ៍នៃការផ្សាភ្ជាប់ពីសមាជិកមួយទៅសមាជិកមួយទៀតនៃប្រជាជាតិមួយទៅនឹងអារម្មណ៍មោទនភាពទៅលើសមាជិករបស់ខ្លួនព្រមទាំងប្រជាជាតិផងដែរ។[17] មួយវិញទៀតនិយមន័យជាតិនិយមអាច

---

[15] https://owlcation.com/social-sciences/The-Main-Reasons-For-War ,ចូលទស្សនាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០

[16] សង្គ្រាមរវាងអ៊ីស្រាអែលនិងប្រទេសអារ៉ាប់,វិទ្យុRFIខេមរភាសា, ចូលទស្សនាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០

[17] Daniel S. PAPP, Contemporaty international relations, ទំព័រ៣៩, បោះពុម្ពលើកទី៨

កំណត់បានថា ការឈរលើវប្បធម៌ ភាសា និងជាតិសាសន៍នៃប្រទេសមួយ។ វាក៏អាចរាប់បញ្ចូលនូវ អក្សរសាស្ត្រ កីឡា ឬសិល្បៈ។ ប៉ុន្តែអ្វីដែលទាញជាតិនិយមនោះគឺការផ្សាភ្ជាប់នូវវប្បធម៌។ បន្ថែមពីនេះវាលើកតំកើនប្រជាជាតិរបស់ខ្លួនខ្ពស់ជាងជាតិសាសន៍ដទៃ។ ប្រសិនប្រទេសឬអ្នកដឹកនាំដែលមានគំនិតជាតិនិយមនោះ ពួកគេមិនចូលរួមអង្គការអន្តរជាតិឬសមាគមនោះទេ ហើយរក្សារូបភាពរបស់ខ្លួនខ្ពស់ជាងប្រជាជាតិដទៃដើម្បីឲ្យមានភាពឈើចាប់។ ជាតិនិយមអាចមានរូបភាពល្អទៅក្រុមមួយចំនួនដោយសារតែការគ្រប់គ្រងប្រជាជាតិដទៃនិង ការមើលឃើញថាខ្លួនជាជាតិសាសន៍អស្ចារ្យ។ បន្ថែមពីនេះមនោគមវិជ្ជាណាដែលប្រឆាំងខ្លួនមិនត្រូវបានទទួលស្គាល់។

តែជាអកសុលជាតិនិយមក្នុងទម្រង់ជ្រុលនិយមក្លាយជាអំពើប្រល័យពូជសាសន៍។[18]ជាក់ស្តែងការបំផុសជាតិនិយមរបស់លោក អាឌុល ហ៊ីត្លែរ (Adolf Hitler) ក្នុងអំឡុងពេលក្រោយសង្គ្រាមលោកលើកទី១ នឹងសង្គ្រាមលោកលើកទី២ បានឈានទៅរកសង្គ្រាមនឹងការស្អប់ជាតិសាសន៍ដទៃ។ ចាប់ផ្តើមនៅក្នុងពេលលោកហ៊ីត្លែរកំពុងសម្រាកព្យាបាលរបួសនៅមន្ទីរពេទ្យ ដែលទទួលដំណឹងថា អាល្លឺម៉ង់បរាជ័យនៅក្នុងសង្គ្រាមលោកលើកទី១ នៅខែវិច្ឆិកាឆ្នាំ១៩១៨។ ដំណឹងនេះ ធ្វើឲ្យហ៊ីត្លែរមានការភ្ញាក់ផ្អើល រន្ធត់ចិត្ត និងពោរពេញដោយភ្លើងកំហឹងផងពីព្រោះគាត់ជឿថាបរាជ័យរបស់អាល្លឺម៉ង់ គឺជាបរាជ័យនយោបាយ មិនមែនជាបរាជ័យខាងយោធានោះទេ។ ហ៊ីត្លែរ ក៏ដូចជាអ្នកជាតិនិយមអាល្លឺម៉ង់ផ្សេងទៀតដែរ ប្រកាន់នូវជំនឿមួយថា ទាហានអាល្លឺម៉ង់នៅលើសមរភូមិមិនចាញ់ប្រៀបគូសត្រូវនោះទេ ក៏ប៉ុន្តែមេដឹកនាំរដ្ឋាភិបាលអាល្លឺម៉ង់បែរជាបានប្រកាសចុះចាញ់សង្គ្រាមទៅវិញ ដែលជាហេតុធ្វើឲ្យប្រជាជាតិអាល្លឺម៉ង់ទាំងមូលត្រូវទទួលរងនូវភាពអាម៉ាស់ ព្រមទាំងត្រូវសត្រូវមានសិទ្ធិសម្រេចតាមរយៈការដាក់លក្ខខណ្ឌយ៉ាងធ្ងន់ធ្ងរ និងដោយអយុត្តិធម៌ នៅក្នុងពេលចុះសន្ធិសញ្ញាសន្តិភាពនៅ Versailles នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩១៩។ កំហឹង និងភាពអាម៉ាស់នេះហើយ ដែលត្រូវបានហ៊ីត្លែរយកមកធ្វើជាឧបករណ៍នយោបាយ ដើម្បីឡើងកាន់អំណាចនៅប៉ុន្មានឆ្នាំក្រោយមកទៀត។

តាមរយៈការចេញផ្សាយសៀវភៅមួយ ដែលមានចំណងជើងជាភាសាអាល្លឺម៉ង់ថា "Mein Kampf" (ជាភាសាខ្មែរ "ការតស៊ូរបស់ខ្ញុំ")។ សៀវភៅដែលហ៊ីត្លែរសរសេរនៅក្នុងពេលកំពុងជាប់ក្នុងពន្ធនាគារ ហើយដែលត្រូវបានបោះពុម្ពផ្សាយរាប់លានក្បាល មុននឹងត្រូវក្លាយជាសៀវភៅគោលនយោបាយរបស់របបណាហ្ស៊ីអាល្លឺម៉ង់ក្រោមការដឹកនាំរបស់ហ៊ីត្លែរ (ឆ្នាំ១៩៣៣-ឆ្នាំ១៩៤៥)។ នៅក្នុងសៀវភៅនេះ ហ៊ីត្លែរបានសរសេររៀបរាប់អំពីប្រវត្តិផ្ទាល់ខ្លួនផង និងអំពីមនោគមន៍វិជ្ជានយោបាយ ដើម្បីនាំមកនូវការផ្លាស់ប្តូរប្រជាជាតិអាល្លឺម៉ង់ផង។ យោងតាមគោលគំនិតនៃសៀវភៅ ប្រជាជាតិអាល្លឺម៉ង់ត្រូវតែបង្កើតឡើងដោយឈរលើមូលដ្ឋានជាតិសាសន៍ជាធំ។សៀវភៅនេះមានគោលគំនិតធំៗពីរយ៉ាង។ ទី(១)បានបញ្ជាក់ថាប្រជាជាតិអាល្លឺម៉ង់ គឺទុកសម្រាប់តែជាតិសាសន៍អាល្លឺម៉ង់តែប៉ុណ្ណោះ ចំណែកឯជាតិសាសន៍ផ្សេងទៀតត្រូវតែកម្ចាត់ចោល ដើម្បីបន្សុទ្ធជាតិសាសន៍អាល្លឺម៉ង់។ គំនិតបន្សុទ្ធជាតិសាសន៍នេះហើយ ដែលជាដើមហេតុមួយ ដែលនាំឲ្យមានការសម្លាប់រង្គាលជនជាតិជ្វីហ្វនៅអាល្លឺម៉ង់ និងនៅ

[18] https://www.thestreet.com/politics/what-is-nationalism-14642847 ,ចូលទស្សនាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០

តាមបណ្តាប្រទេសស្ថិតក្រោមការកាន់កាប់របស់ហ៊ីត្លែរ នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២។ គោលគំនិតទី(២) គឺព្រំដែនរបស់ប្រទេសអាល្លឺម៉ង់នឹងមិនត្រូវកំណត់តាមលក្ខណៈភូមិសាស្ត្រនោះទេ តែទៅតាមលក្ខណៈជាតិសាសន៍ ឬអាចនិយាយបានម្យ៉ាងទៀតថា នៅទីណាក៏ដោយ ឲ្យតែមានជាតិសាសន៍អាល្លឺម៉ង់រស់នៅទីនោះត្រូវតែជាទឹកដីរបស់អាល្លឺម៉ង់។ ដោយឈរលើគោលគំនិតនេះហើយ ដែលហ៊ីត្លែរបានចូលឈ្លានពានតំបន់ ដែលមានប្រជាជនដើមកំណើតអាល្លឺម៉ង់រស់នៅក្នុងប្រទេសឆេកូស្លូវ៉ាគី និងប៉ូឡូញ ហើយដែលជាផ្នែកមួយនៃបុព្វហេតុសង្គ្រាមលោកលើកទី២ នៅឆ្នាំ១៩៣៩។[19]

បន្ថែមពីនេះបន្ទាប់ពីបានកាន់អំណាច លោកអាឌុល ហ៊ីត្លែរបានថ្លែងទៅកាន់ប្រជាពលរដ្ឋអាល្លឺម៉ង់ថា "ប្រជាពលរដ្ឋអាល្លឺម៉ង់ជាប្រជាពលរដ្ឋ ដែលខ្លាំងក្លាជាងគេនៅលើភពផែនដីនេះ។ ដូចនេះប្រទេសអាល្លឺម៉ង់ត្រូវតែដណ្តើមទឹកដី ដែលខ្លួនបានបាត់បង់ដោយសារសន្ធិសញ្ញាក្រុងវែរសៃ (Versailles) មកវិញទាំងអស់។"[20]

### ២.២.៤. វិវាទសាសនា

ជាទូទៅសាសនាគឺជាការប្រមូលផ្តុំនៃជំនឿ វប្បធម៌ ទស្សនៈនិងឆ្លុះបញ្ចាំងពីដំណើរធម្មជាតិរបស់មនុស្សលោកដែលពាក់ព័ន្ធនឹងការរស់នៅរបស់មនុស្សជាតិទូទាំងពិភពលោក។ សាសនានីមួយៗតែងតែមាននិមិត្តសញ្ញា ការទូលមានប្រៀនប្រដៅនិងលក្ខណៈពិសេសរបស់ពួកគេរៀងៗខ្លួន។ ដូច្នេះគោលការណ៍ឬមូលដ្ឋានគ្រឹះនៃគម្ពីរព្រះទាំងនោះគឺជួយពន្យល់ អប់រំ និងប្រតិបត្តិតាមខ្លឹមសារដែលបានចែង។

យោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យថា សាសនា មានន័យថា ពាក្យបណ្តាំ ពាក្យផ្តាំផ្ញើរ ពាក្យប្រៀនប្រដៅ ការបង្គាប់បញ្ជា ទណ្ឌកម្ម ការគ្រប់គ្រង ការត្រួតត្រា។ ចំណែកពាក្យនេះក៏មានអ្នកប្រាជ្ញទស្សនវិទូល្បីៗមួយចំនួននៅក្នុងលោកក៏បានឲ្យនិយមន័យពាក្យនេះផងដែរ។ លោក Friedrich Engels ជាទស្សនវិទូ ជនជាតិអាល្លឺម៉ង់ បានឲ្យនិយមន័យថា សាសនា គឺជាការឆ្លុះបញ្ចាំងតាមបែបស្រមើលស្រមៃ នូវកម្លាំងខាងក្រៅដែលត្រួតត្រាជីវិតមនុស្សរាល់ថ្ងៃ។លោក Durkheim គឺជាទស្សនវិទូ និងជាសង្គមវិទូជនជាតិ បារាំង បានលើកឡើងថា សាសនា គឺជាប្រព័ន្ធជំនឿឯកភាពរូបនីយកម្មមួយ និងការប្រតិបត្តិទាក់ទង់ទៅនិងវត្ថុដ៏ពិសិដ្ឋ។ សាសនាគឺជាការគោរពបូជាចំពោះឫទ្ធានុភាពដ៏ខ្ពង់ខ្ពស់នានា ពីតម្រូវការខាងស្មារតី។[21]

ថ្វីត្បិតតែសាសនាបានបង្រៀននិងប្រព្រឹត្តតែអំពើជាល្អតាមរយៈព្រះគម្ពីរ និងមានទស្សនវិជ្ជាដែលបង្កប់ដោយអត្ថន័យសន្តិភាពនិងអហិង្សា សាសនាក៏អាចប្រែក្លាយជាវិវាទ។ វិវាទសាសនានេះអាចផ្សាភ្ជាប់ជាមួយហេតុផលវិវាទផ្សេងៗដូចជា ការសងសឹកឬស្អប់ជាតិសាសន៍ដទៃ។ ឧទាហរណ៍ជាក់ស្តែង ការសម្លាប់រង្គាលនៅប្រទេស Bosnia and Herzegovina ដែលជាអតីតប្រទេសយូហ្គោស្លាវី(Former Yugoslavia) ក្នុងឆ្នាំ១៩៩២ ដល់

---

[19] https://www.rfi.fr/km/hitler-and-nazi-party-in-germany ,ចូលទស្សនាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០

[20] សាស្ត្រាចារ្យ ដុំ អ៊ឹម, ទំនាក់ទំនងអន្តរជាតិ,ទំព័រ៤២,បោះពុម្ពលើកទី២

[21] https://thmeythmey.com/?page=detail&id=37080 ,ចូលទស្សនាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០

១៩៩៥។ ទោះបីជាប្រទេស Bosniaមានក្រុមជាតិសាសន៍នឹងសាសនាជាច្រើនបានរួមរស់ជាមួយគ្នាជាង៤០ឆ្នាំក្រោម ការដឹកនាំកុំម្មុយនិស្តរបស់ប្រទេសយូហ្គោស្លាវី វាបានប្រែប្រួលនៅពេលប្រទេសយូហ្គោស្លាវីចាប់ផ្តើមដួលរលំ និងអំឡុងពេលធ្លាក់ចុះឥទ្ធិពលនៃរបបកុំម្មុយនិស្តនៅដើមឆ្នាំ១៩៩០។ បន្ទាប់មក Slovenia នឹងCroatia (អតីតយូហ្គោស្លាវី) បានប្រកាសឯករាជ្យ ហើយសង្គ្រាមចាប់ផ្តើមយ៉ាងលឿនបន្ទាប់ពី Serbia (អតីតយូហ្គោស្លាវី) នឹងប្រទេសសាធារណៈរដ្ឋផ្សេងៗបានផ្តាច់ខ្លួន។ រីឯជម្លោះជាតិសាសន៍ចាប់ផ្តើមកើតឡើងយ៉ាងឆាប់រហ័សផងដែរ។ រីឯប្រជាជនដែលធ្លាប់រស់នៅសុខសន្តិភាពអស់រយៈពេលជាច្រើនឆ្នាំ ហើយជាអ្នកភូមិផងរបងជាមួយបានក្លាយជាសត្រូវនិងប្រើប្រាស់កម្លាំងទ័ព។

ជាការពិតណាស់ ក្នុងឆ្នាំ១៩៩១សាធារណៈរដ្ឋ Bosnia and Herzegovina មានប្រជាជនសរុបប្រមាណ ៤លាននាក់ រួមមានបីជាតិសាសន៍ធំៗដូចជា Bosnian Muslim មាន៤៤ ភាគរយ, Bosnian Serb មាន៣១ ភាគរយនិង Bosnian Croat ១៧ ភាគរយ និងជាតិសាសន៍ដទៃទៀត ៨ ភាគរយ។ នៅថ្ងៃទី០៥ ខែមេសាឆ្នាំ១៩៩២ រាជរដ្ឋាភិបាលនៃBosnia បានប្រកាសឯករាជ្យពីប្រទេសយូហ្គោស្លាវី។ ការបង្កើតនៃរដ្ឋឯករាជ្យនេះត្រូវបានជាតិសាសន៍ Bosnian Serbsឬ Serb ប្រឆាំងនឹងជាតិសាសន៍ភាគច្រើន (Bosnain Majority) ពីការប្រកាសនេះ ដោយបានប្រើប្រាស់កំម្លាំងទាហានក្នុងគោលបំណងការពារទឹកដី និង ការសម្អាតប្រជាពលរដ្ឋ Bosnian Muslim។ Bosnian Serbs បានដាក់គោលដៅលើ ប្រជាជនBosnian Muslim និង Croatian នៅក្នុងតំបន់ដែលគេគ្រប់គ្រង បន្ទាប់មកបានក្លាយជាការសំអាតជាតិសាសន៍ (Ethnic Cleansing)។ អំឡុងពេលសង្គ្រាមផ្ទៃក្នុង ដែលកើតឆ្នាំ ១៩៩២ ដល់ ១៩៩៥ ប្រជាជនប្រមាណ ១០០,០០០ នាក់ត្រូវបានសម្លាប់ ៨០ភាគរយក្នុងចំណោមអ្នកស្លាប់គឺជាBosnian Muslim។ ក្នុងខែកក្កដា ឆ្នាំ១៩៩៥ កងកម្លាំងជាតិសាសន៍Bosnian Serb បានសម្លាប់ជាតិសាសន៍ Bosnian Muslim ទាំងក្មេងប្រុស និងបុរសក្នុងទីក្រុង Srebrenica ប្រហែលប្រហែល ៨,០០០ នាក់ ហើយវាជាការសម្លាប់រង្គាលដ៏ធំក្នុងអឺរុបចាប់តាំងពី Holocaust។[22] យ៉ាងណាមិញសង្គ្រាមនេះត្រូវបានបញ្ចប់ បន្ទាប់ពីយុទ្ធនាការទំលាក់គ្រាប់បែករបស់គំនិតផ្តួចផ្តើមNATO ទៅកាន់កងកម្លាំងBosnian Serbs ដើម្បីបញ្ចប់ការវាយប្រហារនិងជំរុញការចរចា។ដូច្នេះកិច្ចព្រមព្រៀងសន្តិភាពមួយត្រូវបានបង្កើតឡើងនិងត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៥ ហៅថាកិច្ចព្រមព្រៀង Dayton ”Dayton Accords”។[23]

[22] គឺការសម្លាប់រង្គាលជនជាតិជ្វីហ្វនៅអាល្លឺម៉ង់ស្ថិតក្រោមការកាន់កាប់របស់ហ៊ីត្លែរនៅក្នុងអំឡុងសង្គ្រាមលោកលើកទី២

[23] https://www.ushmm.org/genocide-prevention/countries/bosnia-herzegovina/case-study/background/1992-1995 ,ចូលទស្សនាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

# ជំពូកទី២

# យន្តការនៃការដោះស្រាយជម្លោះអន្តរជាតិ

## ផ្នែកទី១ ៖ ដំណោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ

ការប្រើប្រាស់ជម្លោះក្រៅប្រព័ន្ធតុលាការ គឺជាយន្តការដែលប្រជាជនប្រើប្រាស់ជាជម្រើសដើម្បីដោះស្រាយជម្លោះនៅក្រៅប្រព័ន្ធយុត្តាធិការរបស់តុលាការ។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ត្រូវបានចាប់ផ្តើមក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០និង១៩៨០ និងទទួលបាននូវប្រជាប្រិយភាពចាប់ពីពេលនោះមក។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយរឿងក្តីទាំងក្នុងកិច្ចការសង្គមដូចជាគ្រួសារ ជម្លោះជាមួយអ្នកជិតខាង ក៏ដូចជាជម្លោះពាក់ព័ន្ធនិងបរិស្ថាន ពាណិជ្ជកម្ម និងការងារ។ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការមានច្រើនទម្រង់ ហើយទម្រង់ដែលត្រូវបានគេស្គាល់ជាទូទៅ គឺតាមរយៈ ការចរចា ការផ្សះផ្សា សន្ទានកម្មជាដើម។[24]

ចំពោះគោលការណ៍នៃការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការមានដូចជា ដំណោះស្រាយជម្លោះអន្តរដ្ឋ (ការចរចា) គឺអាស្រ័យលើគូភាគីនៃជម្លោះ ឬដំណោះស្រាយជម្លោះដោយពឹងពាក់តតិយភាគី (ការបញ្ចុះបញ្ចូលភាគី សន្ទានកម្ម កិច្ចការអង្កេត និងកិច្ចការផ្សះផ្សា) គឺទាមទារស្វែងរកនូវភាគីទីបីចូលមកដោះស្រាយជាមួយ។ ជាក់ស្តែងការដោះស្រាយជម្លោះក្នុងក្របខណ្ឌអន្តរជាតិ គឺមានការចូលរួមពីគូភាគីជម្លោះដោយសារប្រទេសនីមួយៗតែងតែជ្រើសរើសវិធានការសន្តិភាព ជាជាងសង្គ្រាម។

ឧទាហរណ៍ជម្លោះតំបន់សមុទ្រចិនខាងត្បូងតែងតែមានការចរចាជាច្រើនដងតាមរយៈយន្តការទ្វេភាគីឬពហុភាគីរវាងភាគីជម្លោះ។[25] មួយវិញទៀតការដោះស្រាយតាមរយៈអង្គការតំបន់ជាពិសេសASEANរហូតបង្កើតបានសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់បណ្តាភាគីនៅសមុទ្រចិនខាងត្បូង (Declaration on the Conduct of Parties in the South China Sea) ដែលកម្ពុជាជាប្រធានអាស៊ានជាលើកដំបូងក្នុងឆ្នាំ២០០២ មានការចុះហត្ថលេខារវាងរដ្ឋមន្ត្រីការបរទេសអាស៊ាននិងសាធារណរដ្ឋប្រជាមានិតចិន។បន្ថែមពីនេះASEAN និងសាធារណរដ្ឋប្រជាមានិតចិន គឺបន្តកិច្ចខិតខំប្រឹងប្រែងសម្រេចបាននូវក្រមប្រតិបត្តិស្តីពីសមុទ្រចិនខាងត្បូង(Code of Conduct in the South China Sea)នៅថ្ងៃខាងមុខ។ ជាការពិតណាស់រាល់វិវាទនីមួយៗមានភាពស្មុគស្មាញនិងប្រើប្រាស់រយៈពេលច្រើនឆ្នាំណាស់ទំរាំរួចផុតពីការជាប់គាំងផ្នែកនយោបាយ ពោលគឺអាស្រ័យទៅលើទំហំនៃជម្លោះ ប្រវត្តិនៃជម្លោះ និង ឆន្ទៈរបស់គូភាគីជម្លោះក្នុងការដោះស្រាយជម្លោះ។ ដូច្នេះការជ្រើសយកយន្តការណាមួយមកដោះស្រាយក្រៅប្រព័ន្ធតុលាការ រដ្ឋអាចប្រើប្រាស់វិធីសាស្ត្រមួយ(ឧទាហរណ៍ការចរចា) មានលក្ខណៈច្រើនដងឬតាមវិធីសាស្ត្រផ្សេងៗអាស្រ័យលើគូភាគី។ យ៉ាងណាមិញវិធីសាស្ត្រនីមួយៗមិនតម្រូវឲ្យធ្វើជាលំដាប់លំដោយទេ

[24] វិទ្យាស្ថានសភាកម្ពុជា,ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ,ទំព័រ១-២,ឆ្នាំ២០១៥

[25] ប្រទេសសាធារណរដ្ឋប្រជាមានិតចិន ,សាធារណរដ្ឋចិន, ប្រ៊ុយណេ, ឥណ្ឌូណេស៊ី, ម៉ាឡេស៊ី, ហ្វីលីពីននិង វៀតណាម

ដូចដែលមានចែងក្នុងមាត្រា៣៣.(១) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

ផ្នែកខាងក្រោមនេះនិងបកស្រាយឲ្យបានស៊ីជំរៅនៃភាពខុសគ្នា និងដាច់ដោយឡែកនៃដំណោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ៖

## ១.១.ការចរចា

### ១.១.១. ការចរចានៃជម្លោះ

ការចរចា គឺជារបៀបដោះស្រាយជម្លោះដែលមានលក្ខណៈងាយស្រួលជាងគេដើម្បីឲ្យគូភាគីនៃជម្លោះចូលតុពិភាក្សា និងស្វែងរកដំណោះស្រាយដោយស្មោះត្រង់ឬសុទ្ធចិត្តដែលអាចទទួលយកបានដោយគូភាគីទាំងសងខាង។

យោងតាមរយៈលទ្ធិអន្តរជាតិ ការចរចាត្រូវបានកំនត់ថាជាយន្តការបឋម ចាស់ទុំ និងជាដំណាក់កាលមុនដំបូងគេបង្អស់ ដែលគូភាគីត្រូវធ្វើនៅក្នុងគ្រប់យន្តការនៃការដោះស្រាយជម្លោះទាំងអស់។ នៅក្នុងករណីខ្លះកាតព្វកិច្ចនៃការចរចាត្រូវបានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ ហើយការមិនអនុវត្តនៃកាតព្វកិច្ចនោះ អាចនឹងខុសលក្ខខណ្ឌទម្រង់ដែលបានចែងរួចមក។ ឧទាហរណ៍ការដោះស្រាយជម្លោះដែនទឹកអន្តរជាតិ គឺត្រូវមានការចរចាទើបចាត់ទុកជាលក្ខខណ្ឌទម្រង់មួយដើម្បីឲ្យពាក្យបណ្តឹងអាចទទួលយកបានពីតុលាការអន្តរជាតិ យោងតាមអនុសញ្ញានីតិសមុទ្រឆ្នាំ១៩៨២ ផ្នែកទីXV មាត្រា២៨៣ គឺតម្រូវឲ្យផ្លាស់ប្តូរយោបល់គ្នា (Obligation to Exchange Views)។[26]

### ១.១.២. កាតព្វកិច្ចបង្ខំឲ្យចរចា (ផ្តោតទៅលើមូលដ្ឋានគតិយុត្ត)

ក្នុងបរិបទទំនាក់ទំនងអន្តរជាតិកាតព្វកិច្ចបង្ខំឲ្យចរចា គ្រាន់តែជាវិធីនៃការចងក្រងជាច្បាប់លើវិធានទំនៀមទម្លាប់ទាំងនោះប៉ុណ្ណោះ។ យ៉ាងណាមិញការចរចានេះ គ្មានអ្វីហាមប្រាមរដ្ឋ ឬ អង្គការអន្តរជាតិឲ្យរំលឹក ឬបញ្ជាក់ខ្លឹមសារនៃកាតព្វកិច្ចឲ្យចរចាតាមផ្លូវសន្ធិសញ្ញានោះទេ។ ប៉ុន្តែកាតព្វកិច្ចបង្ខំឲ្យចរចាមានតម្លៃខ្ពស់ប្រសិនបើរដ្ឋឬអង្គការអន្តរជាតិ ត្រូវបានអនុវត្តដោយមានលក្ខខណ្ឌចែងច្បាស់លាស់។ បន្ថែមពីនេះអនុសញ្ញាអន្តរជាតិខ្លះបានចែងអំពីការចូលរួមចរចាឬសាកសួរយោបល់ពិគ្រោះជាលក្ខណៈអន្តររដ្ឋ។ ឧទាហរណ៍មាត្រា៨៤នៃអនុសញ្ញាក្រុងវីយែនស្តីពីទំនាក់ទំនងរដ្ឋនិងអង្គការអន្តរជាតិ ដែលមានលក្ខណៈសាកលក្នុងឆ្នាំ១៩៧៥ និង សន្ធិសញ្ញាជាច្រើនទៀត បានគ្រោងអំពីការចរចា ដើម្បីដោះស្រាយបញ្ហា។

ម្យ៉ាងទៀតវិធីសាស្ត្រការចរចាជាមូលដ្ឋានមានពីររបៀប។ របៀបទី(១)គឺការចរចាបែបបែងចែក (ឈ្នះ-ចាញ់)គឺ ភាគីវិវាទសន្មត់ថាមានធនធានដែលមានចំនួនជាក់លាក់មួយ ដែលពួកគេត្រូវបែងចែករវាងគ្នានិងគ្នា។ ជូនកាល គេហៅថាជាល្បែងផលសរុបស្មើសូន្យ (Zero-Sum Game)។ ប្រសិនបើភាគីម្ខាងទទួលបានកាន់តែច្រើន ភាគីម្ខាងទៀតទទួលបានកាន់តែតិច។ នៅក្នុងអំឡុងពេលចរចា ភាគីវិវាទកំណត់ពីជំហរខ្លួនឯងរៀងៗខ្លួន។ ភាគី

[26] ផល ពិសាល, មជ្ឈត្តការអន្តរជាតិ ស្ថាប័ននិងនីតិវិធី,ទំព័រ៩៩,បោះពុម្ពលើកទី១

ចុងចម្លើយដឹងអំពីចំនួនអតិបរមាដែលខ្លួនមានឆន្ទៈក្នុងការបង់ ហើយភាគីរងគ្រោះដឹងអំពីចំនួនអប្បបរមាដែលខ្លួនមានឆន្ទៈក្នុងការទទួលយក។ គោលដៅរបស់ភាគីនីមួយៗ គឺទទួលបានផលជានជាអតិបរមានៅក្នុងចន្លោះសម្រាប់តវ៉ានេះ។ របៀបទី(២) គឺការចរចាផ្អែកលើផលប្រយោជន៍មានលក្ខណៈសហការជាជាងការចរចាបែបបែងចែក។ គេត្រូវសម្មត់ថាមានផលប្រយោជន៍សំខាន់ៗដទៃទៀតដែលគេត្រូវរកឲ្យឃើញ និងតម្រូវតាមទៅវិញទៅមក។ ភាគីវិវាទអាចមានផលប្រយោជន៍មួយចំនួនរួមគ្នាឬយ៉ាងហោចណាស់ផលប្រយោជន៍មួយចំនួនដែលបំពេញបន្ថែមឲ្យគ្នា។[27]

### ១.១.៣. មុខងារនៃការចរចាដោះស្រាយជម្លោះ

ក្នុងករណីដែលភាគីកំពុងមានជម្លោះនិងគ្នា កាតព្វកិច្ចបង្ខំឲ្យចរចាត្រូវបានយកមកអនុវត្តជាដាច់ខាត ដោយហេតុថា ជម្លោះកំពុងកើតឡើងនេះគឺជាកម្រិតអប្បបរមា ដែលភាគីត្រូវតែធ្វើដើម្បីស្វែងរកដំណោះស្រាយជម្លោះរបស់ខ្លួនដោយសន្តិវិធី។ សរុបមកការអនុវត្តចរចាតាមរយៈភាគីពាក់ព័ន្ធ ត្រូវបានគេអនុវត្តនូវរាល់កាលទេសៈទាំងអស់ ទោះបីជាគ្មានអត្ថបទគតិយុត្តបញ្ជាក់ក៏ដោយ។ឧទាហរណ៍តុលាការPCIJ បានលើកឡើងថាដំណោះស្រាយជម្លោះតាមផ្លូវតុលាការគឺជាការដំណោះស្រាយផ្ទាល់ និងតាមការសម្របសម្រួលនៃវិវាទទាំងនេះរវាងភាគី។ ឧទាហរណ៍រឿងក្តីស្តីតំបន់រួចពន្ធរវាងបារាំងនិងស្វីសចុះថ្ងៃទី១៩ខែសីហាឆ្នាំ១៩២៩ក្នុងតុលាការ PCIJ ។

ការចរចា គឺជាធាតុផ្សំនៃការសន្យាដ៏ទូលំទូលាយមួយរបស់រដ្ឋ ពោលគឺជានីតិវិធីដំបូងជាចាំបាច់មុនពេលចាប់ផ្តើមនីតិវិធិស្មុគស្មាញ ករណីដូចជាមុនពេលធ្វើការដោះស្រាយជម្លោះតាមផ្លូវតុលាការមជ្ឍត្តវិនិច្ឆ័យ គេតែងតែបង្ខំឲ្យភាគីធ្វើការចរចាគ្នាសិន។ឧទាហរណ៍រឿងក្តីស្តីពីខ្ពង់រាបបាតសមុទ្រខាងជើងថ្ងៃទី២០ខែកុម្ភៈឆ្នាំ១៩៦៩។ តុលាការICJ បានបញ្ជូនសំណុំរឿងឲ្យភាគីជម្លោះត្រឡប់ទៅចរចាគ្នាវិញសិន មុននឹងតុលាការសម្រេចជាចុងក្រោយ។

### ១.១.៤. ខ្លឹមសារនៃការបង្ខំឲ្យចរចា

កាតព្វកិច្ចបង្ខំឲ្យចរចាមិនដែលមានទម្រង់ច្បាស់លាស់ឡើយ ប៉ុន្តែវិធានរបស់វាអាចបែកចែកជាដំណាក់កាលៗបាន។ ក្នុងករណីនៃកម្រិតអប្បបរមាកាតព្វកិច្ចបង្ខំឲ្យចរចា មិនត្រឹមតែបង្ខំឲ្យភាគីជម្លោះឲ្យចាប់ផ្តើមការចរចាររបស់ខ្លួនប៉ុណ្ណោះទេ តែត្រូវបង្ខំភាគីពាក់ព័ន្ធឲ្យបន្តការចរចានេះរហូតទល់តែធ្វើយ៉ាងណាឲ្យចេញជាផ្លែផ្កាបាន ដូចជាការចេញជាកិច្ចព្រមព្រៀងរវាងភាគីពាក់ព័ន្ធនោះ។ ប្រសិនបើមានការបរាជ័យក្នុងការចរចា តតិយភាគីណាមួយត្រូវធ្វើការផ្ទៀងផ្ទាត់ថា តើភាគីទាំងអស់បានគោរពកាតព្វកិច្ចខ្លួនដោយស្មោះត្រង់ហើយឬនៅ ដើម្បីជៀសវាងកុំឲ្យមានការចោទប្រកាន់លើភាគីណាមួយពីបទមិនគោរពកាតព្វកិច្ចរបស់ខ្លួន។

ចំពោះមួយករណីទៀតគឺ ក្នុងកម្រិតខ្ពស់។ មានន័យថា មានលក្ខខណ្ឌចងគឺមានការសន្យាចូលចរចា ឬ

---

[27] មេធាវី ស៊ីវិន អ៊ែម អូស្តេរមីឡឺ,ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការៈប្រទេសកម្ពុជា,ទំព័រ ១៨-១៩,បោះពុម្ពលើកទី២

អន្តរាគមន៍របស់តតិយភាគីបង្កើតបានជាកាតព្វកិច្ចមានលក្ខខណ្ឌ។ អាចបកស្រាយបានថា ភាគីមិនត្រូវមានគំនិតអាក្រក់ក្នុងការចរចាទេ ពីព្រោះអាចនាំឲ្យមានការចរចាមិនអាចមានផលសម្រេច ហើយជាពិសេសនោះភាគីអាចអនុវត្តគោលការណ៍ដែលខ្លួនអាចកេងយកចំណេញផ្ទាល់ខ្លួនបាន។ភាគីត្រូវតែធ្វើការជានាដោយធ្វើយ៉ាងណាដើម្បីឲ្យការចរចាដំណើរការបានល្អស្របតាមគោលការណ៍ច្បាប់ត្រឹមត្រូវ។

### ១.១.៥. បែបបទនៃការចរចា

បន្ថែមពីនេះការចរចាក្នុងក្របខណ្ឌរវាងរដ្ឋនិងរដ្ឋ អាចបញ្ជូននូវតស្សរជនឆ្នើមៗមានដូចជា ប្រធានាធិបតី នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស ឯកអគ្គរដ្ឋទូត និងអ្នកការទូតនៅក្នុងប្រទេសនោះឬភ្នាក់ងារជំនាញសាធារណៈ។ ក្នុងបែបបទនៃការចរចា អាចប្រព្រឹត្តឡើងជាទ្វេភាគីឬពហុភាគី ដោយអាស្រ័យទៅលើបញ្ហានោះមានការប៉ះពាល់ទៅលើភាគីជាច្រើនឬអត់។ ចំពោះជម្លោះមួយចំនួន រដ្ឋតែងតែជ្រើសរើសបុណ្ណទូតឲ្យធ្វើការចរចាណាមួយជាកំណត់។

សរុបមកការចរចាក្នុងករណីខ្លះ ទទួលបានផលល្អ និងពេលខ្លះមិនទទួលបានផលល្អ ដែលវាជាបញ្ហាមួយដែលត្រូវរកវិធានការដោះស្រាយសំរាប់ពេលអនាគត។ ដោយសារតែការចរចាផ្ទាល់រវាងរដ្ឋជាភាគីជម្លោះ មិនសូវជាទទួលបានផលល្អឡើយ ជាហេតុផលមួយដែលរដ្ឋពឹងពាក់តតិយភាគី ឬ ការយល់ព្រមអន្តរាគមន៍របស់រដ្ឋតតិយភាគីទាំងនេះ ដើម្បីស្វែងរកដោយស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។ ចំពោះការចរចាក្នុងសន្និសីទ គឺជាមធ្យោបាយដែលនាំឲ្យមានការចរចាអន្តរជាតិកើតឡើង។ ឧទាហរណ៍រឿងក្តីICJស្តីពីអាហ្វ្រិចនិរតីឆ្នាំ១៩៦២។ ការចរចាត្រូវបន្តដោយមានវត្តមាន និងការចូលរួមពីសំណាក់រដ្ឋមួយ ឬច្រើនដទៃទៀតដែលជាតតិយភាគីតែមិនមែនជាទ្វេភាគី។ ការចរចាបែបនេះត្រូវតែធ្វើឡើងនៅក្នុងក្របខណ្ឌនៃសមាជឬសន្និសិទណាមួយ។ [28]

បែបបទនៃការចរចាអាចធ្វើឡើងតាមរយៈវិធីសាស្ត្រពីរយ៉ាងគឺៈ យន្តការទី(១) គឺការចរចាដោយផ្ទាល់។ នៅពេលខ្លះការចរចាដោយផ្ទាល់មានប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ដូចជាក្តាប់បានបញ្ហាពិតៗដោយជៀសវាងបានការយល់ច្រលំគ្នា ឬការបកស្រាយមិនត្រឹមត្រូវតាមរយៈភាគីទី៣ ហើយម្យាងទៀត មានលក្ខណៈងាយនឹងឆាប់រហ័ស ក្នុងការសំរេចបាននូវដំណោះស្រាយ។យន្តការទី(២) គឺការចរចាដោយប្រយោលនេះ ក៏អាចជួយឲ្យភាគីនីមួយៗ ជៀសផុតបានពីភាពអាម៉ាស់របស់ខ្លួន នៅពេលដែលការដាក់សំណើររបស់ខ្លួនត្រូវបានបដិសេធចោលដោយភាគីណាមួយ។ ការចរចានេះតាមរយៈអន្តរការី គឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាពនិងនៅតែមានប្រជាប្រិយភាពរហូតដល់សព្វថ្ងៃនេះ។[29]

## ១.២.ដំណោះស្រាយវិវាទដោយពឹងពាក់អន្តរាគមន៍ពីតតិយភាគី

ការពឹងពាក់ភាគីទីបីចូលមកអន្តរាគមន៍ក៏អាចចាត់ទុកថាជាយន្តការត្រូវបានគេប្រើជាញឹកញាប់ផងដែរ

[28] សាស្ត្រាចារ្យ អ៊ឹង រដ្ឋា,នីតិអន្តរជាតិសាធារណៈ,ទំព័រ២៦៥-២៦៩,បោះពុម្ពលើកទី៨

[29] សាស្ត្រាចារ្យ ដុំ អ៊ឹម, ទំនាក់ទំនងអន្តរជាតិ,ទំព័រ២៥៩-២៦០,បោះពុម្ពលើកទី២

នៅពេលការចរចាមិនទទួលបានផ្លែផ្កា។ ការបញ្ចុះបញ្ចូលភាគី (Good Offices) និង សន្ទានកម្ម (Mediation) ការអង្កេត (Inquiry) និង ការផ្សះផ្សា (Conciliation) គឺត្រូវការជំនួយរបស់តតិយភាគីដែលសម្រេចបាននូវការដាក់ឲ្យអនុវត្តវិធានជាមូលដ្ឋាន ឬស្នើជូនមតិ ឬស្នើឡើងនូវដំណោះស្រាយ ឬសម្រេចបាននូវដែនអនុវត្តត្រូវបានបន្តរហូតដល់ទៅធ្វើសេចក្ដីសម្រេចអំពីជម្លោះនោះជាដើម។ សរុបមកសេចក្ដីសម្រេចពុំមានលក្ខណៈចងគូភាគីទេ។

ផ្នែកខាងក្រោមនេះនិងបកស្រាយឲ្យកាន់តែច្បាស់នូវភាពខុសគ្នា និងដាច់ដោយឡែកនៃវិធីសាស្ត្រនីមួយៗ៖

### ១.២.១. ការបញ្ចុះបញ្ចូលភាគី (Good Offices) និង សន្ទានកម្ម (Mediation)

វិធានទាំងពីរនេះគឺមានលក្ខណៈដោះស្រាយជម្លោះ តាមរយៈពឹងពាក់អន្តរាគមន៍របស់តតិយភាគី ដើម្បីឲ្យជួយដោះស្រាយជម្លោះ ដែលមានប្រភពពីទំនៀមទម្លាប់ ហើយត្រូវបានគេយកមកចក្រងនៅក្នុងអនុសញ្ញាក្រុងឡាអេ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៨៩៩ និងចុះថ្ងៃទី១៨ខែតុលាឆ្នាំ១៩០៧។

ជាទូទៅតួអង្គសំខាន់ៗក្នុងទំនាក់ទំនងការទូតមានដូចជា បុគ្គលទី(១) គឺប្រមុខរដ្ឋឬនាយករដ្ឋមន្ត្រី បុគ្គលទី(២) គឺរដ្ឋមន្ត្រីការបរទេស បុគ្គលទី(៣) គឺភ្នាក់ងារទូត បុគ្គលទី(៤) គឺភ្នាក់ងារកុងស៊ុល (ភ្នាក់ងារកុងស៊ុល គឺជាមន្ត្រីរាជការមានអភ័យឯកសិទ្ធិ រីឯកុងស៊ុលផ្នែកជំនួញ គឺគ្មានអភ័យឯកសិទ្ធិទេ)។[30] មួយវិញទៀត បុគ្គលដែលអាចក្លាយជាតតិយភាគីមានដូចជា រដ្ឋឬឥស្សរជនជាន់ខ្ពស់ណាមួយ រួមមានព្រះមហាក្សត្រនៃប្រទេសណាមួយ ឬអគ្គលេខាធិការអង្គការសហប្រជាជាតិ ឬអគ្គលេខាធិការនៃអង្គការអន្តរជាតិតាមតំបន់ផ្សេងៗជាក់ស្តែងក្នុងក្របខណ្ឌអាស៊ាន។

ការបញ្ចុះបញ្ចូលភាគីនិងសន្ទានកម្មខុសគ្នាសំខាន់ត្រង់ចំណុចដែលថា គេប្រគល់ភារកិច្ចឲ្យទៅសន្ទានការី ក្នុងការតាមដាននិងដឹកនាំការចរចារហូតដល់គោលដៅ។ ដូចនេះសន្ទានកម្មក៏មាននីតិវិធីការបញ្ចុះបញ្ចូលភាគីដែរ។

#### ១.២.១.១. ការបញ្ចុះបញ្ចូលភាគី (Good Offices)

ការបញ្ចុះបញ្ចូលភាគី គឺការធ្វើឡើងតាមរយៈអន្តរការីដែលជាទូទៅជាតួអង្គនយោបាយដែលមានឥទ្ធិពលហើយគាត់ដើរតួយ៉ាងសំខាន់ក្នុងការជំរុញឲ្យមានការចចាឲ្យទទួលបានផ្លែផ្កាដើម្បីជ្រៀសវាងនៃវិវាទ។

ការបញ្ចុះបញ្ចូលភាគី គឺរដ្ឋតតិយភាគីដើរតួនាទីនាំឲ្យមានទំនាក់ទំនងឡើងវិញ រវាងភាគីជម្លោះ ហើយជាគោលការណ៍រដ្ឋតតិយភាគី មិនចូលរួមផ្ទាល់ក្នុងការជជែកពិភាក្សាទេ គឺគាត់ទុកឲ្យរដ្ឋភាគីជម្លោះដោះស្រាយដោយខ្លួនឯងផ្ទាល់តែម្តង។ ភារកិច្ចរបស់តតិយភាគីត្រូវចប់សព្វគ្រប់ នៅពេលដែលភាគីជម្លោះស្ម័គ្រចិត្តជួបជុំគ្នាហើយចាប់ផ្តើមការចរចារបស់ខ្លួន។ឧទាហរណ៍ការបញ្ចុះបញ្ចូលភាគីរបស់សហរដ្ឋអាមេរិចក្នុងរឿងជម្លោះព្រំដែនរវាងបារាំង ដែលជាអាណាព្យាបាលរបស់កម្ពុជាជាមួយនឹងថៃនៅឆ្នាំ១៩៤៦។

---

[30] សាស្ត្រាចារ្យ ជុំ អ៊ីម, ទំនាក់ទំនងអន្តរជាតិ,ទំព័រ២៦៦,បោះពុម្ពលើកទី២

#### ១.២.១.២. សន្ធានកម្ម (Mediation)

ចំពោះវិធាននេះ អាចធ្វើឡើងតាមរយៈការស្នើសុំពីសំណាក់ភាគីជម្លោះ ឬការស្ម័គ្រចិត្តរបស់តតិយភាគី ប៉ុន្តែវាមានភាពខុសគ្នាបន្តិចនិងការបញ្ចុះបញ្ចូលភាគីផងដែរ ត្រង់ចំណុចដែលសន្ធានការីអាចមានសមត្ថកិច្ចក្នុងការផ្តល់ជាគន្លឹះ នឹងអនុសាសន៍ផ្សេងៗនៃដំណោះស្រាយដែលគូភាគីមានសិទ្ធិទទួលយកឬបដិសេធ ពោលគឺពុំមានការចងជាកាតព្វកិច្ចអន្តរជាតិនោះទេ។

សន្ធានកម្ម អាចធ្វើឡើងតាមការស្នើរសុំពីសំណាក់គូភាគីជម្លោះ ឬអាចធ្វើឡើងតាមការស្ម័គ្រចិត្តរបស់តតិយភាគី សំដៅធ្វើយ៉ាងណាឲ្យភាគីជម្លោះជួបជុំគ្នាសិន។ ប៉ុន្តែគ្រាន់តែថា សន្ធានកម្មមិនបញ្ចប់ត្រឹមតែភាគីស្ម័គ្រចិត្តជួបជុំគ្នាធ្វើការចរចាប៉ុណ្ណោះទេ គឺវាទៅឆ្ងាយជាងការបញ្ចុះបញ្ចូលភាគីត្រង់ចំណុចដែលថា សន្ធានការីអាចស្នើឲ្យមានមូលដ្ឋាននៃការចរចាបាន និងធ្វើអន្តរាគមន៍នៅក្នុងដំណើរការនៃការចរចា ដើម្បីសម្រួលឲ្យខិតជិតគ្នារវាងទស្សនៈភាគីទាំងសងខាង។ប៉ុន្តែចំនុចដែលត្រូវកាត់សម្គាល់គឺ សន្ធានការីមិនព្យាយាមស្វែងរកធ្វើយ៉ាងណាបង្ខំភាគីជម្លោះឲ្យត្រូវតែមានដំណោះស្រាយនោះទេ។ ឧទាហរណ៍សន្ធានកម្មរបស់ប្រទេសអង់គ្លេសនៅឆ្នាំ១៨៦៧ក្នុងរឿងវិវាទបារាំងនិងអាណាចក្រព្រួស (Prussia Empire)ស្តីពីប្រទេសលុចសំបួរ (Luxembourg)។

ក្នុងគោលការណ៍ជាមូលដ្ឋានសន្ធានកម្មមានប្រាំមួយដំណាក់ការមានដូចជា៖ ដំណាក់កាលទី(១)គឺការជួបគ្នាជាលើកដំបូងរវាងសន្ធានការីនិងភាគីទាំងពីរ។ ដំណាក់កាលទី(២) គឺការចូលរួមរបស់សន្ធានការីនៅក្នុងជម្លោះ និងការកំណត់វិធានជាមូលដ្ឋាននៃដំណើរការស្វែងរកដំណោះស្រាយ។ ដំណាក់កាលទី(៣) គឺការប្រមូលពត៌មានពីភាគីជម្លោះ និងការកំណត់អត្តសញ្ញាណនៃបញ្ហា ដែលត្រូវដោះស្រាយនិងការកំណត់របៀបវារៈ។ ដំណាក់កាលទី(៤) គឺបង្កើតដំណោះស្រាយសំរាប់បញ្ហាកំពុងកើតមានឡើង។ ដំណាក់កាលទី(៥)គឺធ្វើការវាយតម្លៃលើជំរើសនៃដំណោះស្រាយ ហើយបៀបធៀបជំរើសទាំងនោះទៅនឹងជំរើសដោះស្រាយជម្លោះដទៃទៀតរបស់ភាគី និងចុងក្រោយទី(៦)គឺបង្កើតកិច្ចព្រមព្រៀងពេញលេញឬមួយផ្នែកលើបញ្ហានៃជម្លោះ ឬសម្រេចថាមិនអាចមានកិច្ចព្រមព្រៀងបានឡើយ។[31]

### ១.២.២. ការអង្កេត ( Inquiry ) និង ការផ្សះផ្សា ( Conciliation )

យន្តការនៃការដោះស្រាយទាំងពីរនេះ(ការអង្កេតនិងការផ្សះផ្សា) ត្រូវមានការយល់ព្រមពីភាគីទាំងពីរសិន ហើយយន្តការនេះដែរត្រូវបានបង្កើតដោយកិច្ចព្រមព្រៀងរវាងភាគីជម្លោះ ទើបបង្កើតបានមនុស្សមួយក្រុមនៃស្ថាប័នណាមួយ ឬគណៈកម្មការណាមួយ។ របាយការណ៍ឬសេចក្តីសំរេចរបស់គណៈកម្មការមិនមានលក្ខណៈបង្ខំទេ ពោលគឺពុំមានការចងជាកាតព្វកិច្ច និងបន្តមានសេរីភាពពេញលេញក្នុងការទទួលស្គាល់ ឬមិនទទួលស្គាល់របស់គូភាគីជម្លោះ។

#### ១.២.២.១. ការអង្កេត ( Inquiry )

[31] មូលនិធិអាស៊ី,ដំណោះស្រាយជម្លោះក្រៅតុលាការ,ទំព័រ៨-៩,បោះពុម្ពឆ្នាំ២០០១

បន្ថែមពីនេះការអង្កេតមានលក្ខណៈខុសគ្នាបន្តិចពីការផ្សះផ្សា ត្រង់ចំណុចថា យន្តការនេះ មានវត្ថុបំណងក្នុងការស្វែងរកការពិតនៃអង្គហេតុ ដែលគូភាគីមានការខ្វែងគំនិតគ្នា។ គូភាគីនៃជម្លោះបានសម្រេចបង្កើតគណៈកម្មការមួយតាមរយៈនៃការបង្កើតគណៈកម្មការអង្កេត ដែលមានសមត្ថកិច្ចក្នុងការផ្តល់អនុសាសន៍ និងគន្លឹះដើម្បីស្វែងយល់អំពីកម្មវត្ថុចម្បងនៃជម្លោះ។ អ្នកធ្វើអង្កេតផ្តល់របាយការណ៍ជូនភាគីជម្លោះ។កិច្ចការអ្នកធ្វើអង្កេតនេះជាទូទៅច្រើនតែប្រគល់ទៅឲ្យគណៈកម្មការណាមួយ ដែលកើតចេញពីកិច្ចព្រមព្រៀងរវាងភាគីជម្លោះ។ កិច្ចព្រមព្រៀងនេះចង្អុលបង្ហាញនូវស្ថានការណ៍ ដែលត្រូវពិនិត្យពិច័យបែបបទនៃសមាសភាព និងរយៈពេលនៃការបង្កើត និងវិសាលភាពនៃអំណាចរបស់គណៈកម្មការអង្កេត។

របាយការណ៍របស់គណៈកម្មការអង្កេតគ្មានលក្ខណៈបង្ខំទេ ពោលគឺភាគីនៅតែមានសេរីភាពពេញលេញក្នុងការកំណត់ថា យកតាមរបាយការណ៍នេះឬអត់។ លើសពីនេះទៀតគណៈកម្មការអង្កេតត្រូវធ្វើការប្រមូលផ្តុំព្រឹត្តការណ៍ដោយត្រង់ៗ ដោយមិនចាំបាច់ធ្វើសេចក្តីសន្និដ្ឋានទេ ទោះបីជាមានសេចក្តីសន្និដ្ឋាននេះក៏ដោយ ប៉ុន្តែវាត្រូវទាញចេញពីព្រឹត្តការណ៍ដែលកើតឡើង។ ប៉ុន្តែនៅពេលរបាយការណ៍នេះបានសំរេច ភាគីច្រើនតែយកធ្វើជាមូលដ្ឋាននៃដំណោះស្រាយជម្លោះរបស់ខ្លួនដោយមិនមានការប្រកែកអ្វីទេ។ វិធីសាស្ត្រទាំងនេះបញ្ជាក់ថា បើរំពឹងតែលើការអង្កេតមិនគ្រប់គ្រាន់ទេ តែវាគ្រាន់តែជាមធ្យោបាយជំនួយបន្ថែមលើនីតិវិធីដោះស្រាយជម្លោះតែប៉ុណ្ណោះ។

### **១.២.២.២. ការផ្សះផ្សា** ( Conciliation )

រីឯការផ្សះផ្សា មានអត្ថន័យធំជាងគេក្នុងចំណោមវិធីសាស្ត្រដូចដែលបានលើកឡើងខាងលើ (ការបញ្ចុះបញ្ចូលភាគី សន្ទានកម្ម ការអង្កេត)។ គឺថាគណៈកម្មការផ្សះផ្សាចាប់ផ្តើមការងាររបស់ខ្លួន លើការពិនិត្យការអង្កេតស្តីពីហេតុការណ៍ដែលបានកើតឡើងនាំឲ្យមានជម្លោះជាមុនសិន ហើយបន្ទាប់មកដោយឈរលើមូលដ្ឋាននៃហេតុការណ៍នេះ គណៈកម្មការផ្សះផ្សាអាចធ្វើការស្នើឲ្យមានដំណោះស្រាយមួយ (គឺកិច្ចព្រមព្រៀងរវាងភាគី) ដែលមិនមានលក្ខណៈបង្ខំចំពោះភាគីណាមួយឡើយ។ ការផ្សះផ្សាមានតួនាទី នាំឲ្យជម្លោះមួយត្រូវបានពិនិត្យពិច័យដោយអង្គការមួយដែលអាចត្រូវបង្កើតឡើងទុកជាមុនស្រេចបន្ទាប់ពីភាគីបានយល់ព្រមគ្នាធ្វើបែបនេះហើយ។ នៅពេលមានជម្លោះកើតឡើង អង្គការនេះក៏និងធ្វើសំណើឲ្យមានដំណោះស្រាយជម្លោះ ដាក់ជូន ភាគីជម្លោះសម្រេចភ្លាម។ ជាចំនុចកំណត់សំគាល់របស់គណៈកម្មការអង្កេត ធ្វើការស្វែងរកហេតុការណ៍ដើម្បីយកមកបង្ហាញចំពោះភាគី ចំណែកគណៈកម្មការផ្សះផ្សាវិញ យកហេតុការណ៍ទាំងនោះមកពិនិត្យពិច័យហើយធ្វើការសិក្សាឲ្យបានគ្រប់ជ្រុងជ្រោយទាំងអស់នៃវិវាទ ក្នុងន័យដើម្បីទាញចេញនូវដំណោះស្រាយមួយ។ នៅពេលសម្រេចបានកិច្ចព្រមព្រៀងដំណោះស្រាយជម្លោះ គឺឈរលើមូលដ្ឋាននៃការព្រមព្រៀងគ្នារវាងភាគីដដែល បានន័យថាកិច្ចព្រមព្រៀងដែលសម្រេចបាននេះ នៅតែគ្មានលក្ខណៈបង្ខំទៅលើភាគីជម្លោះ។[32] ប្រសិនក្នុងករណីភាគីជម្លោះអនុវត្តតាមជារឿងប្រសើរ។

[32] សាស្ត្រាចារ្យ អ៊ឹង រដ្ឋា,នីតិអន្តរជាតិសាធារណៈ,ទំព័រ២៧២-២៧៤,បោះពុម្ពលើកទី៨

យោងតាមវិទ្យាស្ថាននៃនីតិអន្តរជាតិបានកំណត់ថា ការផ្សះផ្សាគឺជាយន្តការនៃការដោះស្រាយជម្លោះតាមរយៈតតិយជនឬអន្តរការីដែលជាគណៈកម្មការពហុភាគីបង្កើតឡើង ដោយភាគីវិវាទជាលក្ខណៈអចិន្ត្រៃយ៍ក្តីឬមិនអចិន្ត្រៃយ៍ក្តី ដើម្បីកំណត់អំពីកម្មវត្ថុនៃជម្លោះ និងដើម្បីទទួលភារកិច្ចធ្វើការសន្និដ្ឋានដែលមានលក្ខណៈអព្យាក្រឹតដែលគូភាគីអាចយកធ្វើជាមូលដ្ឋានក្នុងការចុះកិច្ចព្រមព្រៀមបិទបញ្ចប់វិវាទ។[33]

## ផ្នែកទី២ ដំណោះស្រាយជម្លោះតាមផ្លូវតុលាការ

ដំណោះស្រាយជម្លោះតាមផ្លូវតុលាការនាំឲ្យមានការធ្វើអន្តរាគមន៍ របស់អង្គការឯករាជ្យដែលចេញសេចក្តីសម្រេចមានលក្ខណៈបង្ខំទៅលើភាគីជម្លោះបាន។ ក៏ប៉ុន្តែគួររំលឹកថាដោយគោរពគោលការណ៍អធិបតេយ្យរដ្ឋរដ្ឋជាប់ពាក់ព័ន្ធនៅតែមានសេរីភាពអាចប្រកែកមិនទទួលយកសមត្ថកិច្ចរបស់អង្គការនេះបានដែរ។ ដូចនេះបានជាគេសម្គាល់ឃើញថា នៅមានភាពចាំបាច់ដដែលនៃការយល់ព្រមមុនរបស់រដ្ឋនៃភាគីជម្លោះ។ដំណោះស្រាយតាមផ្លូវតុលាការអាចធ្វើឡើងតាមពីររបៀបគឺតាមផ្លូវតុលាការមជ្ឈត្តវិនិច្ឆ័យ និងមួយទៀតតាមផ្លូវតុលាការយុត្តិធម៌អន្តរជាតិ។

### ២.១ .ដំណោះស្រាយតាមផ្លូវតុលាការមជ្ឈត្តវិនិច្ឆ័យ

ដំណោះស្រាយតាមផ្លូវតុលាការមជ្ឈត្តវិនិច្ឆ័យមានប្រវត្តិដើមវែងឆ្ងាយហើយវាត្រូវអនុវត្តឡើង ដោយគោរពគោលការអធិបតេយ្យរដ្ឋជាធំ។ មជ្ឈត្តវិនិច្ឆ័យជាដំណោះស្រាយជម្លោះដោយភាគីជាអ្នកជ្រើសរើសចៅក្រមឲ្យមកកាត់ក្តីរបស់ខ្លួន។

#### ២.១.១. ប្រភពដើមនៃតុលាការមជ្ឈតិវិនិច្ឆ័យ

មជ្ឈតិវិនិច្ឆ័យជារបៀបដោះស្រាយជម្លោះ តាមផ្លូវតុលាការដែលមានវ័យចំណាស់ជាងគេបង្អស់។ជាក់ស្តែងយុត្តាធិការអន្តរជាតិទើបតែត្រូវបង្កើតនាពេលថ្មីៗប៉ុណ្ណោះហើយមជ្ឈត្តវិនិច្ឆ័យជារបៀបដោះស្រាយមួយ ដែលមានការគោរពអធិបតេយ្យរដ្ឋបានប្រសើរបំផុត។ គឺតុលាការមជ្ឈតិវិនិច្ឆ័យក្នុងរឿងក្តីអាឡាបាម៉ារវាងសហ រដ្ឋអាមេរិចនិងប្រទេសអង់គ្លេសនៅឆ្នាំ១៨៧២ បានបញ្ជាក់ពីការចាប់ផ្តើមមជ្ឈតិវិនិច្ឆ័យទំនើបមុនគេ។ចំណែកឯអង្គការសហប្រជាជាតិវិញបានទទួលបរាជ័យក្នុងការ អនុម័តអនុសញ្ញាស្តីពីមជ្ឈតិវិនិច្ឆ័យ តែនៅឆ្នាំ១៩៥៨ គាត់អនុញ្ញាតឲ្យមានការតាក់តែងវិធានគំរូមួយស្តីពីនីតិវិធីមជ្ឈតិវិនិច្ឆ័យ។[34]

#### ២.១.២ រចនាសម្ព័ន្ធ

##### ២.១.២.១ ក្រុមប្រឹក្សារដ្ឋបាល

ក្រុមប្រឹក្សារដ្ឋបាល(ជាផ្លូវការ ក្រុមប្រឹក្សារដ្ឋបាលអចិន្ត្រៃយ៍ ) គឺជាស្ថាប័នមួយដែលមានសមាសភាពអ្នកតំណាងការទូតទាំងអស់នៃរដ្ឋជាសមាជិកដែលត្រូវបានទទួលស្គាល់នៅហូឡង់។ វាត្រូវបានដឹកនាំដោយរដ្ឋមន្ត្រី

[33] ផល ពិសាល, មជ្ឈត្តការអន្តរជាតិ ស្ថាប័ននិងនីតិវិធី,ទំព័រ៦០,បោះពុម្ពលើកទី១

[34] សាស្ត្រាចារ្យ អ៊ុំង រដ្ឋា,នីតិអន្តរជាតិសាធារណៈ,ទំព័រ២៩៥-២៩៦,បោះពុម្ពលើកទី៨

ក្រសួងការបរទេសហូឡង់ដែលជាសមាជិកផងដែរ។ វាទទួលខុសត្រូវចំពោះ "ទិសដៅនិងការគ្រប់គ្រង"នៃការិយាល័យអន្តរជាតិដឹកនាំថវិការបស់អង្គការនិងរបាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួន។

### ២.១.២.២ ការិយាល័យអន្តរជាតិ

ការិយាល័យអន្តរជាតិ គឺជាលេខាធិការដ្ឋាននៃ PCA និងដឹកនាំដោយអគ្គលេខាធិការ។ វាផ្តល់នូវការស្រាវជ្រាវ ការគាំទ្រផ្នែករដ្ឋបាល ដល់តុលាការអាជ្ញាកណ្តាល PCA។ ចៅក្រមឬអាជ្ញាកណ្តាលដែលស្តាប់រឿងក្តីត្រូវបានគេហៅថា សមាជិកតុលាការ ។ រដ្ឋជាសមាជិកនីមួយៗអាចចាត់តាំងនូវសមត្ថភាពបួនយ៉ាងនៃសំណួរដែលទាក់ទងទៅនឹង ច្បាប់អន្តរជាតិអំពីកេរ្តិ៍ឈ្មោះខាងសីលធម៌ខ្ពស់និងប្តេជ្ញាទទួលយកភារកិច្ចរបស់អាជ្ញាកណ្តាល" សម្រាប់រយៈពេល ៦ ឆ្នាំបន្ត។ សមាជិកនៃរដ្ឋជាសមាជិកនីមួយៗរួមគ្នាបង្កើតជា" ក្រុមជាតិ"។ សមាជិកអាចត្រូវបានជ្រើសរើសនៅក្នុងករណីអាជ្ញាកណ្តាលដែល PCAផ្តល់ការគាំទ្រ។ ក្រុមជាតិអាចស្នើសុំបេក្ខជនសម្រាប់សមាជិក តុលាការយុត្តិធម៌អន្តរជាតិ។

## ២.១.៣.ការបង្កើត និងសមត្ថកិច្ចរបស់តុលាការមជ្ឈត្តវិនិច្ឆ័យ

រដ្ឋគឺជាអ្នកសម្រេចលើការកំណត់សមាសភាពតុលាការមជ្ឈត្តវិនិច្ឆ័យ។ ជួនកាលអាចមានមជ្ឈត្តវិនិច្ឆ័យដែលធ្វើឡើងប្រមុខរដ្ឋបរទេសណាមួយ តែករណីនេះលែងសូវមានគេអនុវត្តទៀតហើយនាពេលបច្ចុប្បន្ន។ បើកាលណាគេប្រើបច្ចេកទេសនៃមជ្ឈត្តករតែមួយរូបនោះគេច្រើនតែជ្រើសរើសយកអ្នកច្បាប់ជា ពិសេសសាស្ត្រាចារ្យនីតិអន្តរជាតិដែលមកពីបណ្តាលពីប្រទេសជឿនលឿនអ្នកការទូតឬឥស្សរជនពិសេសៗ ក្នុងករណីដូចជាអគ្គលេខាធិការអង្គការសហប្រជាជាតិជាដើម។ មជ្ឈត្តវិនិច្ឆ័យត្រូវរៀបចំជាគណៈកម្មការមជ្ឈត្តវិនិច្ឆ័យវិញ គឺវាត្រូវមានសមាភាពតំណាងមកពីរដ្ឋភាគីជម្លោះចូលរួមក្នុងគណៈកម្មការនេះ។

បច្ចុប្បន្នច្រើនតែជាតុលាការមជ្ឈត្តវិនិច្ឆ័យដែលមានសមាសភាពជាសមាជិកអព្យាក្រឹតបីរូបនិងពីររូបជាសមាជិកដែលមកពីរដ្ឋភាគីជម្លោះឬជួនកាលសមាជិកអព្យាក្រឹតមួយរូប និងសមាជិករដ្ឋភាគីជម្លោះចំនួនពីររូប។ សមត្ថកិច្ចរបស់តុលាការមជ្ឈត្តវិនិច្ឆ័យត្រូវបានកំណត់ជាបឋមក្នុងកិច្ចព្រមព្រៀងមជ្ឈត្តវិនិច្ឆ័យតែតុលាការអាចធ្វើការបកស្រាយកិច្ចព្រមព្រៀងនេះហើយសម្រេចលើសមត្ថកិច្ចផ្ទាល់របស់ខ្លួនដោយឈរលើមូលដ្ឋាននៃអត្ថបទរបស់កិច្ចព្រមព្រៀងមជ្ឈត្តវិនិច្ឆ័យ។ផ្ទុយទៅវិញប្រសិនបើ មានការរំលោភសមត្ថកិច្ចក្នុងការដោះស្រាយឬ មានការអនុវត្តលើសសេចក្តីសម្រេចរបស់តុលាការនេះនឹងត្រូវធ្វើជាកម្មវត្ថុនៃការដកហូតតម្លៃគតិយុត្តទាំងអស់ពីវាហើយមិនអាចបង្ខំទៅលើរដ្ឋបានទេ។

### ២.១.៣.១ នីតិវិធីអាជ្ញាកណ្តាល

នៅក្នុងមាត្រា ៣០ដល់៥៧ នៃអនុសញ្ញាទីក្រុងឡាអេឆ្នាំ ១៨៩៩ វិធាននៃនីតិវិធីអាជ្ញាកណ្តាលត្រូវបានគូសបញ្ជាក់។ ច្បាប់ទាំងនេះគឺជាកំណែថ្មីនៃសន្ធិសញ្ញាដែលមានស្រាប់ក្នុងចំណោមរដ្ឋនានា។ ពួកគេត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ១៩០៧ ការបង្កើតនីតិវិធីសង្ខេបសម្រាប់ករណីសាមញ្ញៗដែលជាការផ្លាស់ប្តូរដែលមានភាព

ច្របូកច្របល់បំផុតហើយមានជាប់ទាក់ទងនៅក្នុងការបង្កើតវិធាន ១៩២០ សម្រាប់តុលាការយុត្តិធម៌អន្តរជាតិ។

សកម្មភាពដំបូងរបស់ភាគីនានាមុនពេល PCA គឺជាការដាក់ស្នើនូវអ្វីដែលហៅថា"ការសម្របសម្រួល" ដោយបញ្ជាក់អំពីបញ្ហានិងសមត្ថកិច្ចរបស់អាជ្ញាកណ្ដាល។ ដំណើរការនីតិវិធីត្រូវបានធ្វើឡើងជាពីរដំណាក់កាលគឺការស្នើសុំជាលាយលក្ខណ៍អក្សរនិងការពិភាក្សាផ្ទាល់មាត់។ រីឯដំណាក់កាលទី២ គឺតុលាការនឹងចូលនិវត្តន៍នៅពេលដែលការជជែកដេញដោលចប់ដើម្បីពិភាក្សានិងបញ្ចប់រឿងក្តីដោយសម្លេងភាគច្រើនធម្មតា(៥០%+១)។

ការសម្រេចចិត្តត្រូវបានបោះពុម្ពផ្សាយជាការសរសេរ រួមជាមួយនឹងមតិជំទាស់ណាមួយ។ ការសម្រេចចិត្តរបស់តុលាការនៅដំណាក់កាលដំបូងត្រូវបានដាក់ដោយអាជ្ញាកណ្ដាលដោយខ្លួនឯង។ប៉ុន្តែនៅឆ្នាំ ១៩០៧ ការទទួលខុសត្រូវនេះត្រូវបានប្រគល់ជូនប្រធាននិងលេខាធិការ (PCA)។ សំណេរនេះត្រូវបានអានដល់អង្គប្រជុំជាសាធារណៈមួយនៅចំពោះមុខភ្នាក់ងារនិង មេធាវីរបស់ភាគីនានាក្នុងរឿងក្តីនេះ។ សេចក្តីសម្រេចនេះមានកាតព្វកិច្ចចំពោះភាគីនានាហើយមិនមានយន្តការណាមួយសម្រាប់ប្តឹងឧទ្ធរណ៍ឡើយ។

### ២.១.៣.២ ថវិកានិងថ្លៃឈ្នួល

ចន្លោះពីឆ្នាំ ២០០៧ ដល់ ២០០៨ ថវិកាមានចំនួន ១,៨ លានអឺរ៉ូ។ ថវិការបស់ PCAបានមកពីការចូលរួមចំណែករបស់សមាជិកនិងប្រាក់ចំណូលរបស់ខ្លួនតាមរយៈរឿងក្តីអាជ្ញាកណ្តាល។ ការបែងចែកចំនួនទឹកប្រាក់ដែលត្រូវបង់ដោយរដ្ឋជាសមាជិកនីមួយៗ គឺផ្អែកលើប្រព័ន្ធដែលប្រើប្រាស់ដោយសហភាពប្រៃសណីយ៍សាកល។

ភាគីវិវាទត្រូវចំណាយលើការចំណាយរបស់តុលាការអាជ្ញាកណ្ដាល ដែលត្រូវបានបង្កើតឡើងដើម្បីបើកសវនាការរួមទាំងប្រាក់ខែរបស់អាជ្ញាកណ្ដាល ការចុះឈ្មោះ និងមុខងាររដ្ឋបាលប៉ុន្តែមិនរាប់បញ្ចូលទាំងប្រធានអង្គការទេ។ ថ្លៃដើមនៃមជ្ឈត្តការខុសគ្នាពីករណីមួយទៅករណីមួយហើយការពិភាក្សាអាចត្រូវបានធ្វើឡើងរវាង PCA និងភាគីនានាជុំវិញការរៀបចំថ្លៃសេវា។[35]

### ២.១.៤ សេចក្តីសម្រេចតុលាការមជ្ឈត្តវិនិច្ឆ័យ

សេចក្តីសម្រេចរបស់តុលាការមជ្ឈត្តវិនិច្ឆ័យ មានលក្ខណៈបង្ខំចំពោះរដ្ឋដែលបានស្ម័គ្រចិត្តយល់ព្រមដាក់រឿងក្តីរបស់ខ្លួនជូនតុលាការវិនិច្ឆ័យ។ ប៉ុន្តែវាមានលក្ខណៈមិនដាច់ខាតទេសម្រាប់រឿងក្តីវិនិច្ឆ័យរួចពីព្រោះថាវាអនុវត្តតែចំពោះរដ្ឋដែលជាភាគីជម្លោះ ហើយបានតែចំពោះរឿងវិវាទហ្នឹងតែប៉ុណ្ណោះ។ សេចក្តីសម្រេចមិនមានលក្ខណៈបង្ខំឲ្យអនុវត្តបានន័យថារដ្ឋត្រូវធានាការអនុវត្តសេចក្តីសម្រេចនេះដោយខ្លួនឯងនិងដោយស្មោះត្រង់។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏វាតែមានផ្លូវបណ្ដឹងដទៃទៀតដែរដូចជាបណ្ដឹងឲ្យបកស្រាយសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ។ តែបណ្ដឹងស្តែងនូវភាពស្មុគស្មាញព្រោះថាគណៈកម្មការមជ្ឈត្តវិនិច្ឆ័យ ដែលបានវិនិច្ឆ័យរឿងក្តីត្រូវបានរំលាយចោល នៅពេលដែលតួនាទីរបស់គាត់ត្រូវបានបំពេញចប់សព្វគ្រប់។

---

[35] https://en.wikipedia.org/wiki/Permanent_Court_of_Arbitration ,ចូលទស្សនាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

## ២.២.ដំណោះស្រាយជម្លោះតាមផ្លូវតុលាការយុត្តធម៌អន្តរជាតិ

ICJ គឺជាអ្នកស្នងរាជ្យនៃតុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិ (PCIJ) ដែលត្រូវបានបង្កើតឡើងដោយសង្គមប្រជាជាតិក្នុងឆ្នាំ១៩២០។ បន្ទាប់ពីសង្គ្រាមលោកលើកទី២ទាំងសង្គមប្រជាជាតិនិងPCIJ ត្រូវបានជំនួសដោយអង្គការសហប្រជាជាតិនិងលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ទាក់ទាញបានយ៉ាងខ្លាំងពីអ្នកកាន់តំណែងមុនហើយការសម្រេចចិត្តចុងក្រោយនៅតែមានសុពលភាពដដែល។ សមាជិកនៅក្នុងតុលាការICJទាំងអស់នៃអង្គការសហប្រជាជាតិគឺ ជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ។

តុលាការយុត្តិធម៌អន្តរជាតិមានក្រុមប្រឹក្សាចៅក្រមចំនួន ១៥រូបដែលត្រូវបានជ្រើសតាំងដោយមហាសន្និបាទនិងក្រុមប្រឹក្សាសន្តិសុខរយៈពេល ៩ ឆ្នាំ។ តុលាការនេះត្រូវបានអង្គុយនៅក្នុងវិមានសន្តិភាពក្នុងទីក្រុងឡាអេ ប្រទេសហូឡង់ដែលធ្វើឱ្យអង្គការនេះជា អង្គការសហប្រជាជាតិតែមួយគត់ដែលមិនមានទីតាំងនៅទីក្រុងញូវយ៉ក។ ភាសាធ្វើការផ្លូវការរបស់វាគឺភាសាអង់គ្លេសនិងបារាំង។

### ២.២.១ ការរៀបចំតុលាការ ICJ

#### ២.២.១.១ ការបង្កើតតុលាការយុត្តិធម៌អន្តរជាតិ

ការផ្ទុះសង្គ្រាមនៅខែកញ្ញាឆ្នាំ ១៩៣៩ ជៀសមិនរួចមានផលវិបាកធ្ងន់ធ្ងរសំរាប់ PCIJ ដែលអស់រយៈពេលជាច្រើនឆ្នាំកំពុងប្រឈមនឹងការធ្លាក់ចុះនៃសកម្មភាពរបស់ខ្លួន។ បន្ទាប់ពីការអង្គុយជាសាធារណៈចុងក្រោយនៅថ្ងៃទី ៤ ខែធ្នូឆ្នាំ ១៩៣៩ និងដីកាចុងក្រោយរបស់ខ្លួននៅថ្ងៃទី ២៦ ខែកុម្ភៈឆ្នាំ ១៩៤០ តុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិ។

តាមពិតមិនទាក់ទងនឹងជំនួញតុលាការទៀតទេហើយគ្មានការបោះឆ្នោតជ្រើសរើសចៅក្រមទេ។ នៅឆ្នាំ ១៩៤០តុលាការបានផ្លាស់ប្តូរទីលំនៅទៅ ទីក្រុងហ្សឺណែវដោយទុកឱ្យចៅក្រមម្នាក់នៅទីក្រុងឡាអេរួមគ្នាជាមួយមន្ត្រីចុះបញ្ជីមួយចំនួននៃសញ្ជាតិហូឡង់។ ទោះបីមានសង្គ្រាមក៏ដោយការពិចារណាចាំបាច់ត្រូវផ្តល់ដល់អនាគត់នៃតុលាការនិងការបង្កើតសណ្តាប់ធ្នាប់នយោបាយអន្តរជាតិថ្មី។

នៅឆ្នាំ ១៩៤២ រដ្ឋលេខាធិការសហរដ្ឋអាមេរិចនិងរដ្ឋមន្ត្រីការបរទេសចក្រភពអង់គ្លេសបានប្រកាសខ្លួនឯងក្នុងការគាំទ្រដល់ការបង្កើតតុលាការអន្តរជាតិឡើងវិញ បន្ទាប់ពីសង្គ្រាមហើយគណៈកម្មាធិការអ្នកច្បាប់អន្តរទ្វីបអាមេរិកបានផ្តល់អនុសាសន៍ថាយុត្តាធិការរបស់ PCIJ គួរតែត្រូវបានពង្រីក។ នៅដើមឆ្នាំ ១៩៤៣ រដ្ឋាភិបាលចក្រភពអង់គ្លេសបានផ្តួចផ្តើមគំនិតក្នុង ការអញ្ជើញអ្នកជំនាញមួយចំនួនទៅទីក្រុងឡុងដើម្បីបង្កើតគណៈកម្មាធិការអន្តរក្រៅសម្ព័ន្ធមិត្តដើម្បីពិនិត្យលើបញ្ហានេះ។ គណៈកម្មាធិការនោះក្រោមអធិបតីភាពរបស់លោកវីល្លៀមម៉ាល់ឡិន (ចក្រភពអង់គ្លេស) បានបើកកិច្ចប្រជុំចំនួន ១៩លើក ដែលមានការចូលរួមពីសំណាក់អ្នកច្បាប់មកពី ១១ ប្រទេស។ នៅក្នុងរបាយការណ៍របស់ខ្លួនដែលត្រូវបានបោះពុម្ពផ្សាយនៅថ្ងៃទី ១០ ខែកុម្ភៈឆ្នាំ ១៩៤៤ បានផ្តល់អនុសាសន៍ថា៖

- លក្ខន្តិកៈរបស់តុលាការអន្តរជាតិថ្មីគួរតែផ្អែកលើតុលាការយុត្តិធម៌អចិន្ត្រៃយ៍។

- តុលាការថ្មីគួរតែរក្សាយុត្តាធិការប្រឹក្សា។
- ថាការទទួលយកយុត្តាធិការរបស់តុលាការថ្មីមិនគួរជាកាតព្វកិច្ចឡើយ។
- តុលាការមិនគួរមានយុត្តាធិការដើម្បីដោះស្រាយបញ្ហានយោបាយសំខាន់ៗទេ។

ទន្ទឹមនឹងនេះដែរនៅថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៤៣ បន្ទាប់ពីសន្និសីទមួយប្រទេសចិន រុស្ស៊ី ចក្រភពអង់គ្លេសនិងសហរដ្ឋអាមេរិចបាន ចេញសេចក្តីប្រកាសរួមមួយដោយទទួលស្គាល់នូវភាពចាំបាច់ "នៃការបង្កើតនៅកាលបរិច្ឆេទអនុវត្តដំបូងបំផុតជាអង្គការអន្តរជាតិ ជាទូទៅដោយឈរលើគោលការណ៍អធិបតេយ្យ។ ភាពស្មើគ្នានៃរដ្ឋដែលស្រឡាញ់សន្តិភាពទាំងអស់និង បើកចំហដល់សមាជិកភាពដោយរដ្ឋទាំងអស់ទាំងតូចទាំងធំសម្រាប់ការថែរក្សាសន្តិភាពនិងសន្តិសុខអន្តរជាតិ" ។

លទ្ធផលក្នុងការបោះពុម្ពផ្សាយនៅថ្ងៃទី ៩ ខែតុលាឆ្នាំ ១៩៤៤ នៃសំណើសម្រាប់ការបង្កើតអង្គការអន្តរជាតិ ដើម្បីរួមបញ្ចូលតុលាការយុត្តិធម៌អន្តរជាតិ។ ការប្រជុំមួយត្រូវបានកោះប្រជុំជាបន្តបន្ទាប់នៅទីក្រុងវ៉ាស៊ីនតោនក្នុងខែមេសាឆ្នាំ ១៩៤៥ នៃគណៈកម្មាធិការអ្នកច្បាប់តំណាងអោយរដ្ឋចំនួន ៤៤ ។ គណៈកម្មាធិការនេះក្រោមអធិបតីភាព GH Hackworth (សហរដ្ឋអាមេរិច) ត្រូវបានប្រគល់ឱ្យរៀបចំសេចក្តីព្រាងលក្ខន្តិកៈសម្រាប់តុលាការយុត្តិធម៌អន្តរជាតិនាពេលអនាគតសម្រាប់ការបញ្ជូន ទៅសន្និសីទសាន់ហ្វ្រាន់ស៊ីស្កូដែលកំពុងប្រជុំចាប់ពីខែមេសាដល់ខែមិថុនាឆ្នាំ ១៩៤៥ ដើម្បីបង្កើតធម្មនុញ្ញអង្គការសហប្រជាជាតិ។ សេចក្តីព្រាងលក្ខន្តិកៈដែលរៀបចំដោយគណៈកម្មាធិការគឺផ្អែកលើលក្ខន្តិកៈរបស់ PCIJ ។ ហើយដូច្នេះមិនមែនជាអត្ថបទថ្មីទាំងស្រុងទេ ទោះយ៉ាងណាគណៈកម្មាធិការមានអារម្មណ៍ ថាមានកាតព្វកិច្ចទុកសំណួរមួយចំនួនដែលខ្លួនគិតថាសន្និសិទគួរតែសម្រេចថាតើគួរតែបង្កើតតុលាការថ្មីទេ? តើបេសកកម្មរបស់តុលាការជាស្ថាប័នតុលាការចំបងរបស់អង្គការសហប្រជាជាតិគួរត្រូវបានចែងយ៉ាងដូចម្តេច? យុត្តាធិការរបស់តុលាការគួរតែជាកាតព្វកិច្ចហើយបើដូច្នេះតើមានកំរិតណា? តើចៅក្រមគួរត្រូវបានជ្រើសរើសយ៉ាងដូចម្តេច? ការសម្រេចចិត្តចុងក្រោយលើចំណុចទាំងនោះនិងលើទម្រង់ជាក់លាក់ នៃលក្ខន្តិកៈត្រូវបានធ្វើឡើងនៅក្នុងសន្និសិទសាន់ហ្វ្រាន់ស៊ីស្កូដែលក្នុងនោះរដ្ឋចំនួន ៥០ ចូលរួម។ អង្គសន្និបាតបានសម្រេចប្រឆាំងនឹងយុត្តាធិការកាតព្វកិច្ចនិងក្នុងការគាំទ្រដល់ការបង្កើតតុលាការថ្មីទាំងស្រុងដែលនឹងក្លាយជាអង្គដ៏សំខាន់មួយ របស់អង្គការសហប្រជាជាតិដោយឈរលើទិសដៅតែមួយដូចជាមហាសន្និបាតក្រុមប្រឹក្សាសន្តិសុខ ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច។ ក្រុមប្រឹក្សានិងលេខាធិការដ្ឋានហើយលក្ខន្តិកៈរបស់ពួកគេនឹង ត្រូវបញ្ចូលក្នុងធម្មនុញ្ញបង្កើតជាផ្នែកសំខាន់មួយនៃធម្មនុញ្ញ។ មូលហេតុចំបងដែលនាំឱ្យសន្និសីទសម្រេចចិត្តបង្កើតតុលាការថ្មីមានដូចខាងក្រោមៈ

- ដោយសារតែតុលាការគឺជាអង្គជំនុំជម្រះតុលាការដំបូង របស់អង្គការសហប្រជាជាតិវាមិនសមហេតុផលទេដែលតួនាទីនេះត្រូវបំពេញដោយតុលាការអចិន្ត្រៃយ៍នៃយុត្តិធម៌អន្តរជាតិជាមួយនឹងការភ្ជាប់ទៅនឹងសម្ព័ន្ធប្រជាជាតិដែលខ្លួនវាស្ថិតនៅលើចំណុចនៃការរំលាយ។
- រដ្ឋមួយចំនួនដែលជាភាគីនៃលក្ខន្តិកៈរបស់ PCIJ មិនត្រូវបានតំណាងនៅក្នុងសន្និសិទសាន់ហ្វ្រាន់ស៊ីស្កូ

ហើយផ្ទុយទៅវិញរដ្ឋមួយចំនួនដែលតំណាងនៅក្នុងសន្និសិទមិនមែនជាភាគីនៃលក្ខន្តិកៈទេ។

- នៅក្នុងត្រីមាសខ្លះដែលថា PCIJ បានបង្កើតផ្នែកមួយនៃបទបញ្ញាចាស់ដែលក្នុងនោះរដ្ឋអឺរ៉ុបបានត្រួតត្រាកិច្ចការនយោបាយនិងច្បាប់របស់សហគមន៍អន្តរជាតិហើយការបង្កើតតុលាការថ្មី នឹងបង្កភាពងាយស្រួលដល់រដ្ឋនៅខាងក្រៅអឺរ៉ុប។ ដើរតួនាទីកាន់តែមានឥទ្ធិពល នេះបានបង្ហាញការពិត សមាជិកភាពរបស់អង្គការសហប្រជាជាតិបានកើនឡើងពី ៥១ នាក់ក្នុងឆ្នាំ ១៩៤៥ ដល់ ១៩៣ នៅឆ្នាំ ២០២០។

ទោះយ៉ាងណាសន្និសីទសាន់ហ្វ្រាន់ស៊ីស្កូបានចាត់ទុក ថាកម្រិតនៃការបន្តគួរតែត្រូវបានរក្សាជាពិសេសចាប់តាំងពីលក្ខន្តិកៈរបស់ PCIJ បានបង្កើតខ្លួនដោយផ្អែកលើបទពិសោធកន្លងមកហើយហាក់ដូចជាដំណើរការល្អ។ ដូច្នេះធម្មនុញ្ញបានបញ្ជាក់យ៉ាងច្បាស់ថាលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិផ្អែកលើរដ្ឋលេខាធិការដ្ឋាន PCIJ ក្នុងពេលជាមួយគ្នានេះវិធានការចាំបាច់ត្រូវបានធ្វើឡើងដើម្បីផ្ទេរដែនសមត្ថកិច្ចរបស់ PCIJ ឱ្យបានច្រើនតាមតែអាចធ្វើទៅបានទៅតុលាការយុត្តិធម៌អន្តរជាតិ។ ក្នុងករណីណាក៏ដោយការសម្រេចបង្កើតតុលាការថ្មីចាំបាច់ពាក់ព័ន្ធនឹងការរំលាយអ្នកកាន់តំណែងមុនរបស់ខ្លួន។ PCIJ បានជួបគ្នាជាលើកចុងក្រោយនៅក្នុងខែតុលាឆ្នាំ ១៩៤៥ ហើយបានសម្រេចចិត្តផ្ទេរបណ្ណសារនិងផលប៉ះពាល់របស់ខ្លួនទៅតុលាការយុត្តិធម៌អន្តរជាតិថ្មីដែលដូចគ្នានឹងអ្នកកាន់តំណែងមុនដែរគឺមានអាសនៈរបស់ខ្លួននៅវិមានសន្តិភាព។ ចៅក្រមនៃ PCIJ ទាំងអស់បានលាឈប់ពីតំណែងនៅថ្ងៃទី ៣១ ខែមករាឆ្នាំ ១៩៤៦ ហើយការបោះឆ្នោតជ្រើសតាំងសមាជិកដំបូងនៃតុលាការយុត្តិធម៌អន្តរជាតិបានធ្វើឡើងនៅថ្ងៃទី ៦ ខែកុម្ភៈឆ្នាំ ១៩៤៦ ក្នុងសម័យប្រជុំលើកដំបូងនៃមហាសន្និបាតអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខ។

នៅខែមេសាឆ្នាំ ១៩៤៦ PCIJ ត្រូវបានរំលាយជាផ្លូវការហើយតុលាការយុត្តិធម៌អន្តរជាតិបានប្រជុំជាលើកដំបូងដែលត្រូវបានបោះឆ្នោត ជ្រើសរើសជាប្រធានចៅក្រមរបស់ខ្លួនគឺលោកJosé Gustavo Guerrero (អែលសាវ៉ាឌ័រ) ដែលជាប្រធានចុងក្រោយរបស់ PCIJ ។ តុលាការបានតែងតាំងសមាជិកនៃការចុះឈ្មោះរបស់ខ្លួន (ភាគច្រើនមកពីអតីតមន្ត្រីPCIJ) និងបានបើកការអង្គុយជាសាធារណៈដំបូងនៅថ្ងៃទី ១៨ នៃខែនោះ។ ករណីដំបូងត្រូវបានបញ្ជូននៅខែឧសភាឆ្នាំ ១៩៤៧។ ហើយការបោះឆ្នោតជ្រើសរើសសមាជិកដំបូងនៃតុលាការយុត្តិធម៌អន្តរជាតិបានប្រព្រឹត្តទៅនៅថ្ងៃទី ៦ ខែកុម្ភៈឆ្នាំ ១៩៤៦ ក្នុងសម័យប្រជុំលើកដំបូងនៃមហាសន្និបាតអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខ។

### ២.២.១.២ សមាសភាពតុលាការ ICJ

#### ក.ចៅក្រមនៃតុលាការ

តុលាការយុត្តិធម៌អន្តរជាតិមានចៅក្រមចំនួន ១៥ រូបដែលត្រូវបានជ្រើសតាំងឱ្យចូលកាន់តំណែងរយៈពេល ៩ ឆ្នាំដោយមហាសន្និបាតអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខ។[36] សរីរាង្គទាំងនេះបោះឆ្នោតក្នុងពេលដំណាលគ្នាប៉ុន្តែដាច់ដោយឡែកពីគ្នា។ដើម្បីជាប់ឆ្នោតបេក្ខជនត្រូវទទួលបានសំឡេងភាគច្រើនដាច់ខាតនៅ

[36] មាត្រា ៣ (កថាខណ្ឌទី១-៤) នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ

ក្នុងស្ថាប័នទាំងពីរ។

ពេលខ្លះនេះធ្វើឱ្យវាចាំបាច់សម្រាប់ការបោះឆ្នោតជុំមួយចំនួន។[37]

ដើម្បីធានាបាននូវកម្រិតនៃការបន្តមួយភាគបីនៃតុលាការត្រូវបានជ្រើសរើសរៀងរាល់បីឆ្នាំម្តង។ចៅក្រមមានសិទ្ធិបោះឆ្នោតឡើងវិញ។ ប្រសិនបើចៅក្រមស្លាប់ឬលាលែង ពីតំណែងក្នុងអាណត្តិរបស់គាត់ការបោះឆ្នោតពិសេសត្រូវបានធ្វើឡើងឆាប់ៗតាមដែលអាចធ្វើទៅបាន ដើម្បីជ្រើសរើសចៅក្រមដើម្បីបំពេញផ្នែកដែលមិនទាន់បានផុតកំណត់នៃពាក្យ។

ការបោះឆ្នោតត្រូវបានធ្វើឡើងនៅទីក្រុងញូវយ៉ក (សហរដ្ឋអាមេរិក) ក្នុងអំឡុងពេលប្រជុំរដូវស្លឹកឈើជ្រុះប្រចាំឆ្នាំនៃមហាសន្និបាត។ ចៅក្រមដែលបានបោះឆ្នោតជ្រើសរើសបីឆ្នាំចាប់ផ្តើមអាណត្តិរបស់ខ្លួននៅថ្ងៃទី ៦ ខែកុម្ភៈនៃឆ្នាំបន្ទាប់បន្ទាប់មកតុលាការកាន់សន្លឹកឆ្នោត សំងាត់ដើម្បីជ្រើសរើសប្រធាននិងអនុប្រធានដើម្បីកាន់តំណែងរយៈពេល ៣ ឆ្នាំ។

រដ្ឋភាគីទាំងអស់នៃលក្ខន្តិកៈរបស់តុលាការមានសិទ្ធិស្នើសុំបេក្ខជន។ សំណើបែបនេះមិនមែនធ្វើឡើងដោយរដ្ឋាភិបាលនៃរដ្ឋពាក់ព័ន្ធនោះទេប៉ុន្តែដោយក្រុមមួយ ដែលមានសមាជិកនៃតុលាការអាជ្ញាកណ្តាលអចិន្ត្រៃយ៍ ដែលកំណត់ដោយរដ្ឋនោះពោលគឺដោយអ្នកច្បាប់ទាំងបួនក្រុមដែលអាចត្រូវបានកោះហៅឱ្យធ្វើជាសមាជិកក្នុងករណីដែលបណ្តាប្រទេសមិនចូលរួមក្នុងតុលាការអចិន្ត្រៃយ៍នៃអាជ្ញាកណ្តាលការតែងតាំងត្រូវបានធ្វើឡើងដោយក្រុមដែលបង្កើតឡើងតាមរបៀបដូចគ្នា។ ក្រុមនីមួយៗអាចស្នើសុំបេក្ខជនរហូតដល់ទៅ ៤ នាក់ដែលមិនមានមនុស្សពីរនាក់ក្នុងចំណោមពួកគេអាចមានសញ្ជាតិរបស់ខ្លួន ខណៈដែលក្រុមផ្សេងទៀតអាចមកពីប្រទេសណាមួយដោយមិនគិតពីថាតើវាជាភាគីនៃលក្ខន្តិកៈឬបានប្រកាសថាទទួលយកជាកាតព្វកិច្ច យុត្តាធិការរបស់ICJ។ ឈ្មោះបេក្ខជនត្រូវតែទាក់ទងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិក្នុងរយៈពេលកំណត់នៃការជ្រើសរើសរបស់គាត់។

ចៅក្រមត្រូវតែត្រូវបានជ្រើសរើសចេញពី ក្នុងចំណោមបុគ្គលដែលមានចរិតលក្ខណៈ **សម្បត្តិរៀងៗខ្លួនប៉ុណ្ណោះទេប៉ុន្តែថែមទាំងនៅក្នុងខ្លួនទាំងមូលផងដែរ នូវការតំណាងនៃទម្រង់សំខាន់ៗនៃអរិយធម៌និងប្រព័ន្ធច្បាប់ចំបងៗ នៃពិភពលោកគួរតែត្រូវបានធានា។**[38]

នៅពេលបោះឆ្នោតជ្រើសរើសសមាជិកនៃតុលាការគឺ ជាប្រតិភូទាំងរដ្ឋាភិបាលនៃប្រទេសរបស់គាត់ក៏មិនមែនរដ្ឋណាផ្សេងទៀតដែរ។ មិនដូចសរីរាង្គដទៃទៀតនៃអង្គការអន្តរជាតិទេ តុលាការមិនត្រូវបានផ្សំឡើងដោយតំណាងរដ្ឋាភិបាលទេ។ សមាជិកនៃតុលាការគឺជាចៅក្រមឯករាជ្យ ដែលភារកិច្ចដំបូងរបស់ខ្លួនមុនពេលទទួលភារកិច្ចរបស់ពួកគេគឺត្រូវធ្វើការប្រកាសយ៉ាងឱឡារិកនៅក្នុងតុលាការ បើកចំហថាពួកគេនឹងអនុវត្តអំណាចរបស់ពួកគេ

[37] មាត្រា ១០ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ

[38] មាត្រា ៥ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ

ដោយមិនលំអៀងនិងមនសិការ។

**ខ. ចៅក្រមបណ្ដោះអាសន្ន** (Ah hoc)

យោងតាមមាត្រា ៣១ កថាខណ្ឌទី ២ និងទី ៣ នៃលក្ខន្តិកៈរបស់តុលាការរដ្ឋភាគីនៃរឿងក្ដីមួយនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិដែលមិនមានចៅក្រមនៃសញ្ជាតិរបស់ខ្លួននៅលើ Bench អាចជ្រើសរើសមនុស្សម្នាក់មកអង្គុយជាចៅក្រម អាដហុក។ ក្នុងករណីជាក់លាក់នោះក្រោមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៣៥ ដល់ ៣៧ នៃវិធានរបស់តុលាការ។ មុនពេលទទួលយកភារកិច្ចរបស់ពួកគេចៅក្រមត្រូវបានប្រកាសជាឧឡារិកថាជាសមាជិកជាប់ឆ្នោតរបស់តុលាការ។ ពួកគេមិនចាំបាច់ជា (ហើយជាញឹកញាប់មិនមាន) ជនជាតិនៃរដ្ឋដែលកំណត់ពួកគេ។

ចៅក្រមអាចចូលរួមក្នុងសេចក្ដីសម្រេចណាមួយទាក់ទង នឹងរឿងក្ដីទាក់ទងនឹងភាពស្មើគ្នាពេញលេញជាមួយសហសេវិករបស់ពួកគេហើយទទួលបាន ប្រាក់កម្រៃសម្រាប់រាល់ថ្ងៃដែលពួកគេបំពេញកាតព្វកិច្ចរបស់ពួកគេពោលគឺរាល់ថ្ងៃបានចំណាយនៅទីក្រុងឡាអេដើម្បីចូលរួម ការងាររបស់តុលាការបូករួមទាំងរាល់ថ្ងៃផ្ដោតលើការពិចារណាលើករណីនៅខាងក្រៅទីក្រុងឡាអេ។

ភាគីណាមួយត្រូវតែប្រកាសឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បំណងរបស់ខ្លួនក្នុងការជ្រើសរើសចៅក្រម។ ក្នុងករណីដែលមានច្រើនជាងពីរភាគីនៃវិវាទនេះដែលមិនមែនជាការកើតឡើងមិនសមរម្យវិធាននេះ គឺថាភាគីដែលធ្វើសកម្មភាពដូចគ្នាត្រូវបានរឹតត្បិតចំពោះចៅក្រមតែមួយ ដែលមានរវាងពួកគេហើយ ក្នុងករណីមួយក្នុងចំណោមពួកគេមាន ចៅក្រមនៃសញ្ជាតិរបស់ខ្លួននៅលើ Benchនេះ ពួកគេមិនមានសិទ្ធិក្នុងការជ្រើសរើស អាដហុក ចៅក្រមទាំងអស់។ ដូច្នេះមានលទ្ធភាពផ្សេងៗគ្នាដូចខាងក្រោមដែលពិតជាបានកើតឡើងនៅក្នុងការអនុវត្តជាក់ស្ដែង ចៅក្រមធម្មតាពីររូបមានសញ្ជាតិនៃភាគី។ ចៅក្រមពីររូប ចៅក្រមទៀងទាត់នៃសញ្ជាតិនៃភាគីមួយនិងជាចៅក្រម អាដហុក មិនមានចៅក្រមធម្មតាដែលមានសញ្ជាតិនៃភាគីណាមួយហើយក៏មិនមែនជាចៅក្រមដែរ។

ដែលថាសមាសភាពនៃតុលាការយុត្តិធម៌អន្តរជាតិនឹង ខុសគ្នាពីរឿងក្ដីមួយទៅករណីមួយទៀតហើយចំនួនចៅក្រមដែលអង្គុយនៅក្នុងរឿងក្ដីនឹងមិនចាំបាច់មានចំនួន ១៥ ទេ។ វាអាចមានតិចជាងនេះប្រសិនបើចៅក្រមដែលបានជាប់ឆ្នោតមួយឬច្រើនមិនអង្គុយ ឬច្រើនដល់ ១៦ ឬ ១៧ ប្រសិនបើមានចៅក្រម អាដហុក តាមទ្រឹស្ដីវាអាចមានចៅក្រមច្រើនជាង ១៧ នាក់នៅលើ Bench ប្រសិនបើមានភាគីជាច្រើនចំពោះរឿងក្ដីដែលមិនធ្វើសកម្មភាពដូចគ្នា។ សមាសភាពនៃតុលាការ ពេលខ្លះក៏អាចខុសគ្នាពីដំណាក់កាលមួយនៃរឿងក្ដីមួយទៅពាក្យមួយផ្សេងទៀត សមាសភាពមិនចាំបាច់ដូចគ្នាសម្រាប់វិធានការបណ្ដោះអាសន្នការជំទាស់និងគុណសម្បត្តិ។[39] ទោះយ៉ាងណាក៏ដោយនៅពេលដែលតុលាការ ត្រូវបានបង្កើតឡើងជាចុងក្រោយសម្រាប់ដំណាក់កាលមួយនៃករណីពោលគឺចាប់ពី ការបើកកិច្ចដំណើរការនីតិវិធីផ្ទាល់មាត់នៅលើដំណាក់កាលនោះរហូតដល់ការចេញសាល

[39] https://www.icj-cij.org/en/judges-ad-hoc

ក្រមទាក់ទងនឹងវាសមាសធាតុរបស់វានឹងមិនផ្លាស់ប្តូរទេ។

### ២.២.១.៣ វិសមិតភាព

ចំពោះឥស្សរៈជនដែលត្រូវបានជ្រើសរើសធ្វើជាចៅក្រមហើយ នៅពេលកំពុងបំពេញមុខងារពួកគេពុំ អាចទៅធ្វើការងារផ្សេងទៀត ដូចជាការងារនយោបាយ ឬធ្វើការឲ្យរដ្ឋាភិបាលណាមួយបានទេហើយក៏មិនអាច កាន់កាប់កន្លែងណាមួយដែលមានលក្ខណៈវិជ្ជាជីវៈដែរ។ មួយវិញទៀត ចៅក្រមនៅ ក្នុងមុខងារត្រូវបានហាម ឃាត់មិនឲ្យធ្វើជាភ្នាក់ងារ ក្រុមប្រឹក្សា ឬមេធាវីក្នុងរឿងក្តីណាមួយឡើយ។ ក្នុងករណីមានការពាក់ព័ន្ធរឿងរ៉ាវទាំង អស់នោះ តុលាការអន្តរជាតិនឹងធ្វើការប្រជុំសម្រេច ព្រោះថាចៅក្រមដែលជាប់ឆ្នោតមានលក្ខណៈឯករាជ្យដោយ មិនចំណុះឲ្យរដ្ឋរបស់ខ្លួនឡើយ។

### ២.២.២. នីតិវិធី

មានតែរដ្ឋទេ (សមាជិករដ្ឋនៃអង្គការសហប្រជាជាតិនិងរដ្ឋដទៃទៀតដែលបានក្លាយជាភាគីនៃលក្ខន្តិកៈ របស់តុលាការឬដែលបានទទួលយកយុត្តាធិការរបស់ខ្លួននៅក្រោមលក្ខខណ្ឌជាក់លាក់)អាចជាភាគីនៃករណីវិវាទ។ តុលាការមានសមត្ថភាពដោះស្រាយវិវាទបានលុះត្រាតែរដ្ឋដែលពាក់ព័ន្ធបានទទួលយកយុត្តាធិការរបស់ខ្លួន តាមមធ្យោបាយមួយឬច្រើនដូចខាងក្រោមៈ

- ដោយចូលទៅក្នុងកិច្ចព្រមព្រៀងពិសេសដើម្បីបញ្ជូនវិវាទនេះទៅតុលាការ។
- ដោយគុណវុត្តិនៃយុត្តាធិការឧទាហរណ៍នៅពេលដែលពួកគេជាភាគីនៃសន្ធិសញ្ញាដែលមានបទប្បញ្ញត្តិ ដែលក្នុងករណីមានជម្លោះនៃប្រភេទណាមួយ ឬការមិនចុះសម្រុងគ្នាលើការបកស្រាយឬការអនុវត្តន៍សន្ធិសញ្ញាមួយក្នុងចំណោមពួកគេអាចយោងទៅលើឯកសារយោង។
- តាមរយៈប្រសិទ្ធិភាពនៃការប្រកាសដែលធ្វើឡើងដោយ ពួកគេយោងតាមលក្ខន្តិកៈដែលម្នាក់ៗបាន ទទួលយកយុត្តាធិការរបស់តុលាការជាកាតព្វកិច្ចក្នុង ករណីមានជម្លោះជាមួយរដ្ឋផ្សេងទៀតដែលបានធ្វើ សេចក្តីប្រកាសស្រដៀងគ្នា។ សេចក្តីប្រកាសមួយចំនួនដែល ត្រូវដាក់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិមានការកក់ទុកដោយមិនរាប់បញ្ចូលប្រភេទជាក់លាក់នៃជម្លោះ។

រដ្ឋនានាមិនមានតំណាងអចិន្ត្រៃយ៍ដែលត្រូវបានទទួលស្គាល់នៅតុលាការទេ។ ជាធម្មតាពួកគេប្រាស្រ័យ ទាក់ទងជាមួយមន្ត្រីអគ្រានុកូលដ្ឋានតាមរយៈ រដ្ឋមន្ត្រីក្រសួងការបរទេសឬឯកអគ្គរដ្ឋទូតរបស់ពួកគេដែលបាន ទទួលស្គាល់នៅហូឡង់។ នៅពេលពួកគេជាភាគីនៃរឿងក្តីនៅចំពោះមុខ តុលាការពួកគេត្រូវបានតំណាងដោយ ភ្នាក់ងារ។ ភ្នាក់ងារមួយដើរតួនាទីដូចគ្នានិងមានសិទ្ធិនិង កាតព្វកិច្ចដូចគ្នាក្នុងនាមជាអ្នកសុំ នៅក្នុងតុលាការជាតិ។ ទោះយ៉ាងណាដោយសារទំនាក់ទំនងអន្តរជាតិស្ថិតក្នុង ភាពប្រថុយប្រថានភ្នាក់ងារក៏ជាប្រធានបេសកកម្មការទូតពិសេសដែលមានអំណាចធ្វើរដ្ឋអធិបតេយ្យមួយដែរ។ គាត់ទទួលបានការប្រាស្រ័យទាក់ទងពីមន្ត្រី អគ្រានុកូលដ្ឋានទាក់ទងនឹងករណីនេះនិងបញ្ជូនរាល់ការឆ្លើយឆ្លងនិង ការអធ្យាស្រ័យដែលចុះហត្ថលេខាឬ

បញ្ជាក់អោយគាត់។ នៅក្នុងសវនាការសាធារណៈ ភ្នាក់ងារបើកការជជែកវែកញែកក្នុងនាមរដ្ឋាភិបាលដែលខ្លួនជាតំណាងនិងដាក់ការដាក់ជូន។ ជាទូទៅនៅពេលណា ដែលមានសកម្មភាពជាផ្លូវការដែលត្រូវធ្វើដោយរដ្ឋាភិបាលតំណាងនោះវាត្រូវបានធ្វើឡើងដោយភ្នាក់ងារ។ ភ្នាក់ងារពេលខ្លះត្រូវបានជួយដោយភ្នាក់ងារ ភ្នាក់ងាររងឬភ្នាក់ងារជំនួយការហើយតែងតែមានអ្នកប្រឹក្សាឬអ្នកតស៊ូមតិដែលពួកគេធ្វើការសម្របសម្រួលដើម្បីជួយពួកគេក្នុងការរៀបចំនៃការស្នើរសុំនិងការផ្តល់អំណះអំណាងផ្ទាល់មាត់។ ដោយសារមិនមានតុលាការយុត្តិធម៌អន្តរជាតិពិសេសគ្មានលក្ខខណ្ឌណាដែលត្រូវបំពេញដោយមេធាវី ឬ អ្នកតស៊ូមតិដើម្បីទទួលបានសិទ្ធិក្នុងការស្នើរសុំនៅចំពោះមុខតុលាការលើកលែងតែករណីដែលពួកគេត្រូវបានតែងតាំងដោយរដ្ឋាភិបាលដើម្បីធ្វើដូច្នេះ។

កិច្ចដំណើរការនីតិវិធីអាចត្រូវបានបង្កើតឡើងតាមវិធីមួយក្នុងចំណោមវិធីពីរយ៉ាង៖

- តាមរយៈការជូនដំណឹងអំពីកិច្ចព្រមព្រៀងពិសេសមួយ គឺឯកសារនេះដែលមានលក្ខណៈទ្វេភាគីអាចត្រូវបានដាក់ទៅតុលាការដោយទាំងរដ្ឋភាគីទាំងសងខាងក្នុងកិច្ចដំណើរការនីតិវិធី។ កិច្ចព្រមព្រៀងពិសេសត្រូវចង្អុលបង្ហាញប្រធានបទនៃជម្លោះនិងភាគីនានា។ ដោយសារមិនមានរដ្ឋ" អ្នកដាក់ពាក្យសុំ" និងរដ្ឋ" អ្នកឆ្លើយតប" នៅក្នុងការបោះពុម្ពផ្សាយរបស់តុលាការឈ្មោះរបស់ពួកគេត្រូវបានបំបែកដោយ an oblique stroke នៅចុងបញ្ចប់នៃចំណងជើងផ្លូវការនៃករណីនេះឧទាហរណ៍បេនីន នីហ្សេរីយ៉ា។
- តាមរយៈពាក្យសុំពាក្យសុំដែលជាលក្ខណៈ គឺឯកតោភាគីត្រូវបានដាក់ស្នើដោយរដ្ឋអ្នកដាក់ពាក្យប្រឆាំងនឹងរដ្ឋឆ្លើយតប។ វាត្រូវបានបម្រុងទុកសម្រាប់ការប្រាស្រ័យទាក់ទងទៅរដ្ឋចុងក្រោយនិងវិធាននៃតុលាការមានតម្រូវការតឹងរ៉ឹងទាក់ទងនឹងខ្លឹមសាររបស់វា។ បន្ថែមលើឈ្មោះភាគីដែលបណ្តឹងទាមទារនិងប្រធានបទនៃវិវាទនេះ អ្នកដាក់ពាក្យស្នើសុំត្រូវចង្អុល បង្ហាញយ៉ាងខ្លីតាមមូលដ្ឋានដែលអាចធ្វើទៅបានសន្និសញ្ញាឬការប្រកាសអំពីការទទួលយកយុត្តាធិការកាតព្វកិច្ច វាអះអាងថាតុលាការមានយុត្តាធិការហើយត្រូវតែបញ្ជាក់ការពិតនិង មូលដ្ឋានដែលផ្អែកលើពាក្យបណ្តឹងរបស់ខ្លួន។ នៅចុងបញ្ចប់នៃ ចំណងជើងផ្លូវការនៃករណីនេះឈ្មោះ របស់ភាគីទាំងពីរត្រូវបានបំបែកដោយអក្សរកាត់ V (សម្រាប់ឡាតាំង) ឧទាហរណ៍ នីការ៉ាហ្គួ V កូឡុំប៊ី ។

កាលបរិច្ឆេទនៃស្ថាប័ននៃដំណើរការនីតិវិធីដែល ជាការទទួលបានដោយមន្ត្រីអគ្រានុកូលដ្ឋាននៃកិច្ចព្រមព្រៀងពិសេសឬពាក្យសុំគឺជាការបើកកិច្ចដំណើរការនីតិវិធីនៅចំពោះមុខតុលាការ។ កិច្ចដំណើរការនីតិវិធីដែលមានលក្ខណៈវិវាទរួមមាន៖

### ២.២.២.១ ដំណាក់កាលនីតិវិធីជាលាយលក្ខណ៍អក្សរ

ដំណាក់កាលជាលាយលក្ខអក្សរ គឺជាដំណាក់កាលដំបូងដោយភាគីនីមួយៗដាក់ជូនតុលាការនូវ សេចក្តីសំអាង រួមមានការរៀបចំអង្គហេតុនិងអង្គច្បាប់ដែលភាគីម្ខាងទាញយកមកសំអាងព្រមទាំងឆ្លើយតប ទៅនឹងចំណោទចោតសួររបស់ភាគីម្ខាងទៀត។ ភាគីម្ខាងៗមានសិទ្ធិជ្រើរើសដោយសេរីនៅទំរង់បែបបទនៃការជូនសេច

ក្តីសំអាងឯកសារពាក់ព័ន្ធទាំងឡាយអាចយកមកបន្ថែម។ កិច្ចដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរជាការប្រាស្រ័យទាក់ទងទៅនឹងតុលាការនិងភាគីនៃគូរបក្សដេបក្ស ដោយមានការឆ្លើយតបរួមទាំងការដាក់ក្រដាសឯកសារទាំងអស់ក្នុងការសំអាង ។

ការប្រាស្រ័យទាក់ទងទាំងនេះត្រូវធ្វើឡើងតាមរយៈ មន្ត្រីអគ្រានុកូលដ្ឋានទៅតាមលំដាប់លំដោយនិងក្នុងរយៈពេលដែលកំណត់ដោយតុលាការ។ឯកសារថតចម្លងដែលមានការបញ្ជាក់ពីឯកសារនីមួយៗដែលធ្វើដោយភាគីម្ខាងត្រូវផ្ញើទៅឱ្យភាគីម្ខាងទៀត។ តុលាការអាចស្នើសុំពីភាគីនូវឯកសារផ្សេងៗ ក្នុងពេលបណ្តឹងជាលាយលក្ខអក្សរ។[40]

### ២.២.២.២ ដំណាក់កាលផ្ទាល់មាត់

ជាគោលការណ៍នីតិវិធីផ្ទាល់មាត់ត្រូវធ្វើឡើងក្នុងរយៈពេល ២ឬ៣ខែ ក្រោយពីការបញ្ចប់នីតិវិធីជាលាយលក្ខអក្សរ។កាលបរិច្ឆេទនេះត្រូវសម្រេចដោយតុលាការ ដើម្បីផ្តល់ភាពងាយស្រួលដល់ភាគីទាំងឡាយដែលចង់បានពេលវេលាដ៏សមរម្យមួយ។ រាល់សវនាការរបស់កិច្ចដំណើរការនីតិវិធីផ្ទាល់មាត់នឹងមានសវនាការរបស់តុលាការយុត្តិធម៌អន្តរជាតិ ត្រូវធ្វើឡើងជាសាធារណៈ។

### ២.២.២.៣ នីតិវិធីថៃដន្យឬជំទាស់បឋម

នីតិវិធីដែលបានពិពណ៌នាខាងលើគឺជានីតិវិធីធម្មតា។ ទោះយ៉ាងណាក៏ដោយ នីតិវិធីអាចត្រូវបានកែប្រែដោយនីតិវិធីថៃដន្យ។ កិច្ចដំណើរការនីតិវិធីដែលកើតឡើងដោយថៃដន្យបំផុតគឺការជំទាស់បឋមដែលត្រូវបានលើកឡើងដើម្បីប្រឆាំងនឹងសមត្ថកិច្ចរបស់តុលាការក្នុងការសម្រេចលើអង្គហេតុនៃរឿងក្តី (រដ្ឋឆ្លើយសំណួរអាចជំទាស់ឧទាហរណ៍ថាតុលាការខ្វះយុត្តាធិការឬពាក្យសុំមិនអាចទទួលយកបាន)។ បញ្ហាគឺជារឿងមួយដែលតុលាការខ្លួនឯងជាអ្នកសម្រេច។

### ២.២.២.៤ វិធានការបណ្តោះអាសន្ន

បន្ទាប់មកមានវិធានការបណ្តោះអាសន្នដែលអាចត្រូវបានស្នើសុំដោយ រដ្ឋអ្នកដាក់ពាក្យប្រសិនបើវាចាត់ទុកថាសិទ្ធិដែលបង្កើតជាប្រធានបទនៃពាក្យសុំរបស់ខ្លួនស្ថិតនៅក្នុងគ្រោះថ្នាក់ភ្លាមៗ។ លទ្ធភាពទីបីគឺថារដ្ឋអាចស្នើសុំការអនុញ្ញាតឱ្យ ធ្វើអន្តរាគមន៍ក្នុងជម្លោះមួយដែលពាក់ព័ន្ធនឹងរដ្ឋផ្សេងទៀតប្រសិនបើខ្លួនគិតថាខ្លួនមានផលប្រយោជន៍នៃរឿងក្តីស្របច្បាប់ដែលអាច ត្រូវបានប៉ះពាល់ដោយការសម្រេចចិត្តដែលបានធ្វើ។ រហូតដល់មានសេចក្តីសម្រេចចុងក្រោយ តុលាការមានសមត្ថកិច្ចបញ្ជាឱ្យមានវិធានការណ៍បណ្តោះអាសន្នដើម្បីការពារសិទ្ធិរបស់ភាគីវិវាទ។ ភាគីមួយឬទាំងសងខាងនៃវិវាទអាចអនុវត្ត ICJ សម្រាប់ការចេញវិធានការបណ្តោះអាសន្ន។ នៅក្នុងសំណុំរឿងជម្លោះ ព្រំដែនភាគីទាំងពីរនៃជម្លោះគឺបួគីណាហ្វាសូនិងម៉ាលី បានដាក់ពាក្យស្នើសុំទៅតុលាការដើម្បី ចង្អុលបង្ហាញពីវិធានការណ៍បណ្តោះអាសន្ន។ ដែនសមត្ថកិច្ចថៃដន្យរបស់តុលាការកើតចេញពីមាត្រា ៤១

[40]មាត្រា ៤៣ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ

នៃលក្ខន្តិកៈរបស់វា។ ដូចជាសាលក្រមចុងក្រោយការបញ្ហាអោយមានវិធានការបណ្តោះអាសន្នរបស់តុលាការកំពុងតែចងភ្ជាប់ទៅនឹងរដ្ឋភាគីនៃជម្លោះនេះ។ តុលាការយុត្តិធម៌អន្តរជាតិមានសមត្ថភាពចង្អុលបង្ហាញពី វិធានការណ៍បណ្តោះអាសន្នលុះត្រាតែយុត្តាធិការរងត្រូវបានពេញចិត្ត។

### ២.២.២.៥ ការមិនបង្ហាញខ្លួន

លក្ខន្តិកៈក៏ចែងផងដែរសម្រាប់ករណីនានានៅពេល ដែលរដ្ឋឆ្លើយសំណួរខកខានមិនបានបង្ហាញខ្លួននៅចំពោះមុខតុលាការនេះពីព្រោះវាបដិសេធទាំងស្រុងនូវយុត្តាធិការរបស់តុលាការឬដោយហេតុផលណាមួយ។ ការខកខានមិនបានចូលរួមដោយភាគីណាមួយមិនបានរារាំងដំណើរការនីតិវិធីពីដំណើរការរបស់ពួកគេទេ ទោះបីជាតុលាការត្រូវតែបំពេញដោយខ្លួនវាថាវាមានយុត្តាធិការ។ ជាចុងក្រោយប្រសិនបើតុលាការយល់ឃើញថាភាគីដែលបំបែក កិច្ចដំណើរការនីតិវិធី កំពុងដាក់អំណះអំណាងនិងសេចក្តីសន្និដ្ឋានដដែលៗប្រឆាំងនឹងគូប្រជែងទូទៅដែលទាក់ទងនឹងបញ្ហាតែមួយវាអាចបញ្ហាឱ្យដំណើរការនីតិវិធីត្រូវបានចូលរួម។

### ២.២.២.៦ កិច្ចដំណើរការនីតិវិធីប្រឹក្សា

កិច្ចដំណើរការនីតិវិធីប្រឹក្សានៅចំពោះមុខតុលាការគឺបើកបានតែអង្គការចំនួន ៥ របស់អង្គការសហប្រជាជាតិនិងទីភ្នាក់ងារជំនាញចំនួន ១៦ នៃក្រុមគ្រួសារអង្គការសហប្រជាជាតិឬអង្គការដែលពាក់ព័ន្ធ។ មហាសន្និបាតអង្គការសហប្រជាជាតិនិង ក្រុមប្រឹក្សាសន្តិសុខអាចស្នើសុំយោបល់លើ"សំណួរណាមួយដែលស្របច្បាប់"។ អង្គការនិងទីភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ ផ្សេងទៀតដែលត្រូវបានអនុញ្ញាតឱ្យស្វែងរកយោបល់ប្រឹក្សាអាចធ្វើបានតែទាក់ទងនឹង" សំណួរផ្លូវច្បាប់ដែលកើតឡើងនៅក្នុងវិសាលភាពនៃសកម្មភាពរបស់ពួកគេ"។ នៅពេលដែលទទួលបានការស្នើសុំយោបល់ក្រុមប្រឹក្សាតុលាការត្រូវតែប្រមូលអង្គហេតុទាំងអស់ហើយ ដូច្នេះត្រូវបានផ្តល់អំណាចឱ្យធ្វើកិច្ចដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរនិងផ្ទាល់មាត់ស្រដៀងនឹងករណីដែលមាន ជម្លោះ។ តាមទ្រឹស្តីតុលាការអាចធ្វើដោយ គ្មាននីតិវិធីបែបនេះប៉ុន្តែតុលាការមិនដែលបានចែកចាយជាមួយពួកគេទាំងស្រុងទេ។ រដ្ឋទាំងនេះមិនមានជំហរដូចភាគីក្នុងដំណើរវិវាទដែលមានលក្ខណៈ ចម្រូងចម្រាសនោះទេ។ អ្នកតំណាងរបស់ពួកគេនៅចំពោះមុខតុលាការមិនត្រូវបានគេស្គាល់ថាជាភ្នាក់ងារទេហើយ ការចូលរួមរបស់ពួកគេនៅក្នុងដំណើរការប្រឹក្សាយោបល់មិនបានបង្ហាញពីគំនិតរបស់តុលាការ ដែលជាប់ទាក់ទងនឹងពួកគេឡើយ។ ជាធម្មតារដ្ឋដែលបានចុះបញ្ជីគឺជារដ្ឋសមាជិកនៃអង្គការដែលស្នើសុំយោបល់។ រដ្ឋណាមួយដែលមិនត្រូវបានពិភាក្សាដោយតុលាការអាចស្នើសុំ។

ទោះយ៉ាងណាក៏ដោយវាកម្រណាស់សម្រាប់ ICJ ក្នុងការអនុញ្ញាតឱ្យអង្គការអន្តរជាតិក្រៅពីអង្គការដែលស្នើសុំឱ្យមានមតិចូលរួមក្នុងដំណើរការនីតិវិធីប្រឹក្សា។ អង្គការអន្តរជាតិមិនមែនរដ្ឋាភិបាលតែមួយគត់ដែលត្រូវបានអនុញ្ញាតដោយ ICJ ដើម្បីផ្គត់ផ្គង់ព័ត៌មានមិនបានដល់ទីបញ្ចប់ទេ ( ឋានៈអន្តរជាតិនៃអាហ្វ្រិកខាងត្បូង ) ។ តុលាការបានច្រានចោលរាល់សំណើបែបនេះរបស់ភាគីឯកជន។

កិច្ចដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរគឺខ្លីជាង នៅក្នុងកិច្ចដំណើរការនីតិវិធីដែលមានភាពចម្រូងចម្រាសរវាងរដ្ឋហើយច្បាប់គ្រប់គ្រងពួកគេមានភាពបត់បែន។ អ្នកចូលរួមអាចដាក់សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលពេលខ្លះបង្កើត ជាកម្មវត្ថុនៃមតិយោបល់សរសេរដោយអ្នកចូលរួមផ្សេងទៀត។ សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរនិងមតិយោបល់ត្រូវ បានចាត់ទុកថាជាការសម្ងាត់ប៉ុន្តែជាទូទៅត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅដើមនៃនីតិវិធីផ្ទាល់មាត់។ រដ្ឋជាធម្មតាត្រូវបានគេអញ្ជើញឱ្យធ្វើសេចក្តីថ្លែងផ្ទាល់មាត់នៅកន្លែងអង្គុយសាធារណៈ។ដំណើរការប្រឹក្សាយោបល់បញ្ចប់ដោយការផ្តល់មតិយោបល់នៅឯកន្លែងអង្គុយសាធាណៈ។

យោបល់បែបនេះគឺជាការផ្តល់យោបល់ជាអត្ថបទ និយាយម្យ៉ាងទៀតមិនដូចសាលក្រមរបស់តុលាការទេពួកគេមិនជាប់កាតព្វកិច្ចទេ។ ស្ថាប័នទីភ្នាក់ងារឬអង្គការដែលស្នើសុំនៅតែមានសេរីភាពក្នុងការបញ្ចេញមតិដូចដែលវាមើលឃើញថាសមឬមិនធ្វើដូច្នោះទាល់តែសោះ។ ទោះយ៉ាងណាក៏ដោយឧបករណ៍ឬបទបញ្ញត្តិជាក់លាក់មួយចំនួនផ្តល់នូវការផ្តល់យោបល់ពីតុលាការពិតជាមានកម្លាំងចង (ឧទាហរណ៍អនុសញ្ញាស្តីពីសិទ្ធិនិងអភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិ) ។

ទោះយ៉ាងណាការផ្តល់យោបល់របស់តុលាការពាក់ព័ន្ធនឹងសិទ្ធិអំណាចនិងកិត្យានុភាពរបស់ខ្លួនហើយសេចក្តីសម្រេចរបស់អង្គការឬទីភ្នាក់ងារដែលពាក់ព័ន្ធក្នុងការផ្តល់មតិនេះ គឺដូចដែលវាត្រូវបានអនុម័តដោយច្បាប់អន្តរជាតិ។[41]

### ២.២.៣ សេចក្តីសម្រេច

ការវិនិច្ឆ័យរបស់តុលាការយុត្តិធម៌អន្តរជាតិ គឺបិទផ្លូវតវ៉ា សាលក្រមជាចុងក្រោយដែលចងភ្ជាប់ទៅនឹងភាគីនៃរឿងក្តីនិងដោយគ្មានបណ្តឹងឧទ្ធរណ៍ (ភាគច្រើនវាអាចជាកម្មវត្ថុនៃការបកស្រាយឬនៅពេលរកឃើញអង្គហេតុថ្មីការកែប្រែ)។ ចៅក្រមណាម្នាក់ដែលមានបំណងធ្វើដូច្នេះអាចផ្តល់ជាយោបល់ដល់សាលក្រម។ តាមរយៈការចុះហត្ថលេខាលើធម្មនុញ្ញរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិ ប្តេជ្ញាអនុវត្តតាមការសម្រេចរបស់ តុលាការក្នុងករណីណាក៏ដោយដែលជាភាគី។ លើសពីនេះទៅទៀតករណីមួយ អាចត្រូវបានបញ្ជូនទៅតុលាការហើយសម្រេចដោយវាប្រសិនបើ ភាគីមានវិធីមួយឬមួយផ្សេងទៀតបានយល់ស្របនឹងយុត្តាធិការរបស់ខ្លួនលើករណីនេះវាជាការកម្រណាស់ដែលសេចក្តីសម្រេចមួយដែលមិនត្រូវបានអនុវត្ត។ រដ្ឋមួយដែលគិតថាភាគីម្ខាងទៀតមិនបានអនុវត្តកាតព្វកិច្ចដែលខ្លួនកំពុងស្ថិតនៅក្រោម សាលក្រមដែលបានបង្ហាញដោយតុលាការអាចនាំបញ្ហានេះទៅក្រុមប្រឹក្សាសន្តិសុខដែលត្រូវបានផ្តល់អំណាច ឱ្យផ្តល់យោបល់ឬសម្រេចចិត្ត លើវិធានការណ៍ដែលត្រូវអនុវត្តដើម្បីមានប្រសិទ្ធិភាពការវិនិច្ឆ័យ។[42]

---

[41] https://www.icj-cij.org/en/how-the-court-works, ចូលទស្សនាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០

[42] មាត្រា ៩៤ ធម្មនុញ្ញអង្គការសហប្រជាជាតិ

### ២.២.៣.១.ការបកស្រាយសាលក្រម

ក្នុងករណីមានវិវាទទាក់ទងទៅនឹងអត្ថន័យឬវិសាលភាពនៃសាលក្រមតុលាការអាចសម្រេចតាមការស្នើសុំរបស់ភាគីណាមួយ។ ការសុំអាចធ្វើទៅបានលុះត្រាតែ មានសំណើសុំការបកស្រាយរបស់ខ្លួន មិនថានីតិវិធីដំបូងត្រូវបានចាប់ផ្តើមដោយពាក្យសុំ ឬដោយការជូនដំណឹងអំពីកិច្ចព្រមព្រៀងពិសេស។ សំណើរសុំការបកស្រាយសាលក្រមអាច ត្រូវបានធ្វើឡើងដោយការដាក់ពាក្យសុំ ឬដោយការជូនដំណឹងអំពីកិច្ចព្រមព្រៀងពិសេសចំពោះផលប៉ះពាល់រវាងគូភាគី។ ក្នុងកាលដែលមានចំណុចច្បាស់លាស់នៃជម្លោះទាក់ទងនឹងអត្ថន័យឬវិសាលភាពនៃសាលក្រមត្រូវបានបង្ហាញ។ ប្រសិនបើការស្នើសុំឱ្យមានការបកស្រាយត្រូវបានធ្វើឡើងដោយពាក្យសុំការជំទាស់របស់ភាគីស្នើសុំនឹង ត្រូវបានកំណត់នៅក្នុងនោះហើយភាគីផ្សេងទៀតនឹងមានសិទ្ធិដាក់សេចក្តីសង្កេតជាលាយលក្ខណ៍អក្សរនៅ ក្នុងដែនកំណត់ពេលវេលាដែលកំណត់ដោយតុលាការឬដោយប្រធានតុលាការប្រសិនបើតុលាការមិនអង្គុយទេ។ ទោះជាសំណើរត្រូវបានធ្វើឡើងដោយពាក្យសុំឬដោយការជូនដំណឹងអំពីកិច្ចព្រមព្រៀងពិសេសតុលាការអាចផ្តល់លទ្ធភាពឱ្យភាគីនូវការពន្យល់បន្ថែមជាលាយលក្ខណ៍អក្សរឬផ្ទាល់មាត់បាន។[43]

[43] មាត្រា ៩៨ នៃវិធានតុលាការយុត្តិធម៌អន្តរជាតិ

# ជំពូកទី៣

# ករណីសិក្សាស្តីពីដំណោះស្រាយវិវាទតាមរយៈតុលាការយុត្តិធម៌អន្តរជាតិ

## ផ្នែកទី១ ៖ រឿងក្តីស្តីពីប្រាសាទព្រះវិហារ ឆ្នាំ២០០៨-២០១៣

### ទីតាំងភូមិសាស្ត្រ៖

ប្រាសាទព្រះវិហារ ស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា ក្នុងភូមិសាស្ត្រ ភូមិធម្មជាតិ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងពីអតីតកាលមានទីតាំងក្នុងភូមិគ១ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ចំណែកពីអតីតកាលស្រុកជាំក្សាន្តស្ថិតនៅក្នុងខេត្តកំពុងធំ ។ ប្រាសាទព្រះវិហារជាប្រាសាទភ្នំដែលកសាងនៅលើកំពូលភ្នំព្រះវិហារនៃជួរភ្នំដងរែក ដែលមានរយៈកម្ពស់ ៦២៥ម៉ែត្រ ធៀបទៅនិងទឹកសមុទ្រ។ សិលាចារឹកប្រាសាទខ្មា បានហៅភ្នំដងរែកថា ភ្នំកំផែង ឬភ្នំជញ្ជាំង។ ប្រជាជនថៃហៅភ្នំដងរែកថា ភ្នំវែង ចំណែកប្រជាជនឡាវហៅថា ភ្នំដេនមឿង។ ប្រាសាទព្រះវិហារស្ថិតនៅជាប់នឹងព្រំប្រទល់ខេត្តស៊ីសាកេត នៃប្រទេសថៃ ។ ប្រាសាទព្រះវិហារមានចម្ងាយប្រមាណ ៥៥គីឡូម៉ែត្រពីសាលាស្រុកជាំក្សាន្ត ១០០គីឡូម៉ែត្រពីទីរួមខេត្តព្រះវិហារជាង ១៥០គីឡូម៉ែត្រពីទីរួមខេត្តសៀមរាប និងចម្ងាយប្រមាណ ៤០០គីឡូម៉ែត្រពី រាជធានីភ្នំពេញ ។ ជួរភ្នំដងរែកជាខណ្ឌសីមាព្រំប្រទល់ធម្មជាតិអន្តរជាតិរវាងប្រទេសកម្ពុជា និងប្រទេសថៃ ។ ប្រាសាទព្រះវិហារស្ថិតនៅលើចំណុចខ្សែស្របប១៤.២៤ ទៅ១៨នៃរយៈទទឹងខាងកើត និងចំណុចខ្សែស្របប១០៤ ទៅ៤១.០២នៃរយៈបណ្តោយខាងជើង។ ប្រាសាទព្រះវិហារមានទីតាំងស្ថិតនៅលើខ្នងភ្នំព្រះវិហារ ស្ថិតនៅលើផ្ទៃដីទំហំ៨០០ គុណនឹង ៤០០ ម៉ែត្រការ៉េ។ ភ្នំប្រាសាទព្រះវិហារនេះមានលក្ខណៈចោទខ្លាំងពីខាងប្រទេសកម្ពុជា និងជម្រាលពីខាងប្រទេសថៃ។ [44]

### អង្គហេតុ៖

ទោះបីជាយ៉ាងណាក៏ដោយមានការរាំងខ្ទប់ដ៏តានតឹងនិងមានការតវ៉ាពីភាគីថៃក្តី ការខិតខំយ៉ាងសស្រាក់សស្រាំងពីរដ្ឋាភិបាលកម្ពុជាដែលនៅពេលនោះដឹកនាំដោយឧបនាយករដ្ឋមន្ត្រី សុខអាន នៅទីបំផុត ប្រាសាទព្រះវិហារត្រូវបានចុះជាបេតិកភណ្ឌពិភពលោក នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ នៅក្រុងហ្កេបិក ប្រទេសកាណាដា។ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៨ តាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក លេខ 32com8B.102 បានដាក់បញ្ចូលប្រាសាទព្រះវិហារតាមលក្ខណៈសម្បត្តិវប្បធម៌តែមួយចំណុចប៉ុណ្ណោះនៃចំណុចទាំង៣[45] ដែលកម្ពុជាបានស្នើឲ្យដាក់បញ្ចូល។ ចំណុចនោះគឺលក្ខណៈសម្បត្តិទី១ ដែលចាត់ទុកថា ប្រាសាទព្រះវិហារជាស្នាដៃលេចធ្លោនៃស្ថាបត្យកម្មខ្មែរ។ ប្រាសាទនេះមានលក្ខណៈ "បរិសុទ្ធ" ទាំងប្លង់ និងក្បាច់សម្មិតនៃការលម្អ។ ការបញ្ចូលប្រាសាទព្រះវិហារជាបេតិកភណ្ឌជាតិនៅឆ្នាំនោះ ដោយការគោះញួរអនុម័តពី

[44] https://km.wikipedia.org/wiki/ ,ប្រាសាទព្រះវិហារ(ទាក់ទងនឹងទីតាំងភូមិសាស្ត្រប្រាសាទព្រះវិហារ) ,ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០

[45] លក្ខណៈសម្បត្តិទី១គឺ ជាស្នាដៃលេចធ្លោនៃស្ថាបត្យកម្មខ្មែរ **ទី២**គឺបង្ហាញពីអន្តរបម្រែបម្រួលនៃតម្លៃមនុស្ស ការវិវត្តនៃសិល្បៈ ស្ថាបត្យកម្ម ការរំលេចប្លង់ និងទិដ្ឋភាព **ទី៣**គឺ បង្គុំស្ថាបត្យកម្មមានលក្ខណៈពិសេសក្នុងការលាតត្រដាងនូវរវេខាគណិតក៏។

លោកស្រី Dr. Christina Cameron (កាណាដា) ដែលជាប្រធានប្តូរវេននៃគណៈកម្មាធិការយូណេស្កូ។ រីឯរដ្ឋមន្ត្រីការបរទេសថៃ លោក ណុបប៉ាដុន ប៉ាតាម៉ា បានថ្លែងពីការជំទាស់ និងបានរំលឹក និងបញ្ជាក់ពីបំណងនៃកិច្ចសហការរួមជាមួយថៃក្នុងការដាក់បញ្ចូលប្រាសាទព្រះវិហារ។

មួយសប្តាហ៍ក្រោយ ថៃបានបញ្ជូនទាហានចូលឈ្លានពានទឹកដីជុំវិញប្រាសាទព្រះវិហារជាទ្រង់ទ្រាយធំ និងពីរលើកបន្ទាប់មកទៀត។ រីឯច្រកទ្វារចូលទស្សនាប្រាសាទព្រះវិហារត្រូវបានបិទតាំងពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៨ បន្ទាប់មកថៃបានបញ្ជូនទាហានឈុតខ្មៅប្រមាណជាង៥០នាក់មកកាន់វត្តកែវសិក្ខារគីរីស្វារៈ។ នៅឯប្រទេសថៃមានសភាពរំជើបរំជួលរហូតឈានដល់បង្ខំចិត្តលាលែងពីមុខតំណែងរដ្ឋមន្ត្រីការបរទេសថៃ លោក ណុបប៉ាដុន ប៉ាតាម៉ា ក្នុងបំណងបន្ថយភាពតានតឹងនៅថៃ។[46]

កងទ័ពទាំងពី(កម្ពុជានិងថៃ) បានបញ្ជូនកងទ័ពទៅជួរ មុខនិងកាន់កាប់ប្រាសាទតូចៗផ្សេងទៀតនៅក្នុងតំបន់នោះ។ ទាហានថៃបានកាន់កាប់វត្តកែវសិក្ខាគីរីស្វារៈជាប់នឹងប្រាសាទព្រះវិហារនិងក្នុងផ្ទៃដី ៤,៦ គីឡូម៉ែត្រក្រឡា។ ក្រុមអ្នកតវ៉ាជាតិនិយមថៃដែលដើរដង្ហែទៅកាន់ប្រាសាទបាន ប៉ះទង្គិចគ្នាជាមួយអ្នកស្រុកដែលអាក់អន់ស្រពន់ចិត្តថាការធ្វើនយោបាយបានបិទច្រកចូល សាធារណៈជនទៅកាន់ប្រាសាទព្រះវិហារដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ។ កាលពីខែសីហាទាហានថៃបានកាន់កាប់ប្រាសាទតាមាន់ដែលមានចម្ងាយប្រហែល ១៥០ គីឡូម៉ែត្រទៅទិសខាងលិចដោយសាងសង់របងបណ្តោះអាសន្ននៅជុំវិញប្រាសាទហិណ្ឌូ។

ប្រទេសកម្ពុជាបានឆ្លើយតបដោយកាន់កាប់ប្រាសាទតាក្របីដែលមានចម្ងាយប្រហែល ១៣ គីឡូម៉ែត្រខាងកើតនៃតាម៉ាន់ដោយបានបញ្ជូនទាហានចំនួន ៧០ នាក់ទៅកាន់ទីតាំងដែលមិនមានយោធា។ ជាលទ្ធផលប្រទេសថៃបានបញ្ជូនអនុរក្សចំនួន ៣៥ នាក់ទៅកាន់តំបន់នោះ។ នៅសប្តាហ៍ក្រោយមានការប្រឈមមុខគ្នាកម្រិតទាបរវាងការល្បាតទោះបីយ៉ាងណាកងទ័ពបានដកទ័ពថយក្រោយ។ កងទ័ពថៃបានចោទប្រកាន់ទាហានកម្ពុជាថាបានព្យាយាមបង្កហេតុដើម្បីលើកកម្ពស់ទម្រង់វិវាទនេះបន្ទាប់ពីទី ក្រុងភ្នំពេញបានបរាជ័យកាលពីខែកក្កដាដើម្បីឱ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិអន្តរាគមន៍។ នៅពេលនេះមិនមានការប្រយុទ្ធគ្នានៅជុំវិញប្រាសាទទាំងនេះទេ។

ការប៉ះទង្គិចលើកដំបូងបន្ទាប់ពីការចុះបញ្ជីបានកើតឡើងនៅថ្ងៃទី៣ ខែតុលាជាមួយការដោះដូរកាំភ្លើងនិងរ៉ុក្កែតដែលបានធ្វើអោយទាហានខ្មែរម្នាក់និងថៃពីរនាក់បានរងរបួស។ ១៥ តុលាកងទ័ពទាំងពីរបានផ្លាស់ប្តូរគ្រាប់បែកដៃនិងកាំភ្លើងត្បាល់ព្រមទាំងកាំភ្លើងយន្តនិងកាំភ្លើងតូចៗផ្សេងទៀតជុំវិញការយល់ច្រឡំជាក់ស្តែងអំពីការបង្វិលកងទ័ពថៃ។ ពួកមេបញ្ជាការព្រំដែនបានស្ងប់ចិត្តភ្លាមៗដល់អ្នកក្រោមបង្គាប់ជួរមុខរបស់ពួកគេហើយបានយល់ព្រមអោយមានការល្បាតរួមគ្នាបន្ថែមទៀត។ នៅចុងខែតុលា ២០០៨ យោធាថៃជឿថាកម្ពុជាមានកងទ័ពប្រមាណ ២.៨០០ នាក់នៅជុំវិញប្រាសាទព្រះវិហារដែលប្រឈមនឹង ៦០០ នាក់។

[46] យោងចាន់ សុភារ,ពីភ្នំពេញទៅកាន់ក្រុងញូវយ៉ក តើគេធ្វើអ្វីខ្លះនៅអង្គការសហប្រជាជាតិ ,ទំព័រ៦២-៦៤,បោះពុម្ពលើកទី១

នៅចុងខែមីនានិងដើមខែមេសាឆ្នាំ ២០០៩ មន្ត្រីយូណេស្កូបានបំពេញបេសកកម្មត្រួតពិនិត្យបំពេញបន្ថែមដល់ប្រាសាទព្រះវិហារដែលជាផ្នែកមួយនៃការត្រួតពិនិត្យជាទៀងទាត់នៃ តំបន់បេតិកភណ្ឌពិភពលោក ។ វាបានរកឃើញថាខូចខាតប្រាសាទពីអគ្គីភ័យថ្ងៃទី ១៥ ខែតុលាឆ្នាំ ២០០៨ មានតិចតួចប៉ុន្តែថា" វត្តមានបន្តរបស់កងទ័ពនៅជុំវិញទ្រព្យសម្បត្តិបង្កហានិភ័យនៃឧប្បត្តិហេតុដែលអាចកើតមានបន្តទៀត" ។ នៅថ្ងៃទី ៣ ខែមេសាភ្លាមៗបន្ទាប់ពីក្រុមបានចាកចេញការប្រយុទ្ធគ្នាបានផ្ទុះ ឡើងនៅវាលតន្ត្រីដែលជាទីតាំងដូចគ្នានឹងការប៉ះទង្គិចខែតុលាដែរបន្ទាប់ពីមានការខ្វែងគំនិតគ្នារវាងកងទ័ពជុំវិញការចូលទៅកាន់តំបន់មានជម្លោះ។អាវុធដែលមានសមត្ថភាពខ្ពស់ត្រូវបានគេប្រើរួមទាំងការផ្លាស់ប្តូរកាំភ្លើងធំកាំភ្លើងត្បាល់ និងគ្រាប់បែកដៃ ហើយចំនួនអ្នកស្លាប់និងរបួសបានកើនឡើងជាលំដាប់ដោយយ៉ាងហោចណាស់ទាហានថៃនិងខ្មែរពីរនាក់បានស្លាប់។[47]

លើការដោះស្រាយផ្នែកការទូត និងផ្នែកច្បាប់ដែលកម្ពុជាបានតស៊ូយ៉ាងស្វិតស្វាញ។ ផ្នែកការទូតថ្នាក់តំបន់អាស៊ាន គឺឥណ្ឌូនេស៊ីជាអ្នកចេញមុខធ្វើជាអ្នកសម្របសម្រួល។ ចំណែកផ្នែកការទូតថ្នាក់អន្តរជាតិវិញ កម្ពុជាបានដាក់ពាក្យប្តឹងទៅកាន់ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ ស្នើឲ្យដោះស្រាយជម្លោះ។ ការស្មគ្រចិត្តពីប្រទេសឥណ្ឌូនេស៊ី ធ្វើជាអ្នកសម្របសម្រួលដោយមានដំណោះស្រាយតាមរយៈការដាក់ពង្រាយទ័ពឥណ្ឌូនេស៊ីនៅតំបន់ជម្លោះ ដើម្បីថែរក្សាសន្តិភាពតំបន់ក៏ដូចជាថែរក្សាមុខមាត់អាស៊ានផងដែរ។ ចំពោះកម្ពុជាបានឯកភាពទៅលើគ្រប់សំណើរបស់ឥណ្ឌូនេស៊ី ប៉ុន្តែថៃតែងជំទាស់ និងមិនអើពើនឹងដំណើរការទាំងនេះដោយថៃចង់បានការចរចាទ្វេភាគី។ នាខែមេសា ឆ្នាំ២០១១ លោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង ដែលជារដ្ឋមន្ត្រីការបរទេសកម្ពុជាពេលនោះបានដាក់សំណើរទៅតុលាការអន្តរជាតិឲ្យធ្វើការបកស្រាយអំពីសាលដីកាតុលាការដែលបានកាត់ក្តីឲ្យកម្ពុជាឈ្នះក្តីនៅខែមិថុនា ឆ្នាំ១៩៦២។ រហូតដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ទើបតុលាការអន្តរជាតិបានចេញវិធានការបណ្តោះអាសន្នឲ្យភាគីទាំងពីរដកចេញជាបន្ទាន់នូវបុគ្គលិកយោធា នៅក្នុងតំបន់គ្មានយោធានៃតំបន់ជម្លោះ ទម្រាំដល់តុលាការចេញសេចក្តីសម្រេចអំពីការបកស្រាយថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣។[48]

<u>**ការទាមទារចំបងរបស់ប្រទេសកម្ពុជា**</u>៖ ប្រទេសកម្ពុជាទាមទារអធិបតេយ្យរបស់ខ្លួនដោយផ្អែកលើការបកស្រាយរបស់ខ្លួនដូចខាងក្រោម៖

- កម្ពុជាបានអះអាងថា នៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៅក្នុងសាលក្រមមានទំនាក់ទំនងគ្នា (Symbiotically Linked) ។
- ការអះអាងរបស់កម្ពុជាបានទាមទារតម្រូវឲ្យដក កងទ័ពដែលបានបញ្ជាក់ក្នុងកថាខណ្ឌទី២។ក្នុងន័យនេះ ប្រទេសថៃគួរតែដកកងកម្លាំងទ័ពចេញពីប្រាសាទ និងដែនដីនៅតំបន់ក្បែរប្រាសាទនៃប្រទេស កម្ពុជា។

[47] https://casebook.icrc.org/case-study/cambodiathailand-border-conflict-around-temple-preah-vihear,ចូលទស្សនាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០
[48] យោងចាន់ សុភារ,ពីភ្នំពេញទៅកាន់ក្រុងញូវយ៉ក តើគេធ្វើអ្វីខ្លះនៅអង្គការសហប្រជាជាតិ ,ទំព័រ៦៥,បោះពុម្ពលើកទី១

- កាតព្វកិច្ច ការដកទ័ពក្នុងន័យនេះចង់សំដៅទៅលើការតម្រូវឲ្យថៃដកកងកម្លាំងទ័ពហើយនិង មិនតម្រូវឲ្យត្រឡប់មកវិញនៅពេលអនាគតទៅលើទឹកដីកម្ពុជា ដែលបានចែងក្នុងសាលក្រមឆ្នាំ១៩៦២។
- តំបន់នៃទឹកដីដែលតុលាការបានយកមកប្រើប្រាស់នៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២តម្រូវឲ្យភាគីថៃដកទ័ពឲ្យផុតឆ្ងាយពីតំបន់ប្រាសាទនិង មូលដ្ឋានទ័ពថៃដែលបានដាក់។ ក្នុងន័យគឺឲ្យផុតឆ្ងាយពីតំបន់ជម្លោះយោងតាមផែនទីឧបសម្ព័ន្ធទី១។
- កម្ពុជាបានចាត់ទុកនិង រាប់បញ្ចូលតំបន់ដែលស្ថិតនៅកំពូល ភ្នំព្រះវិហារនិងកំពូលភ្នំត្រាប ទៅទិសខាងជើងដូចដែលបានកំណត់នៅក្នុងផែនទីឧបសម្ព័ន្ធទី១។

**<u>ការទាមទារចំបងរបស់ប្រទេសថៃ</u>៖** ប្រទេសថៃទាមទារអធិបតេយ្យរបស់ខ្លួនដោយផ្អែកលើការបកស្រាយរបស់ខ្លួនដូចខាងក្រោម៖

- ថៃបានអះអាងថាផែនទីឧបសម្ព័ន្ធទី១កើតមានឡើងច្រើនទម្រង់ ហើយទម្រង់ទាំងនោះមានភាពខ្វះខាតមិនមានភាពច្បាស់លាស់នៃ ទីតាំងភូមិសាស្ត្រ(Topographical Error) និង ការកំណត់ខុសទីតាំង((Posittoning Error) ក្នុងសន្ធិសញ្ញា ឆ្នាំ១៩០៤។
- ផែនទីឧបសម្ព័ន្ធទី២ ត្រូវបានប្រើប្រាស់ ជាហេតុការណ៍មួយដ៏សំខាន់ ក្នុងការធ្វើសេចក្តីសម្រេចសាលដីកា ឆ្នាំ១៩៦២ ដោយតុលាការបានសម្គាល់ថា ព្រះអង្គម្ចាស់ថៃ Damroug បានយាងទៅកាន់ ប្រាសាទព្រះវិហារដែលតុលាការបានកំណត់ថាជារឿងសំខាន់ ។
- ប្រទេសថៃសន្និដ្ឋានថា សាលដីកាឆ្នាំ ១៩៦២ គ្រាន់តែសម្រេចថាកម្ពុជាមានអធិបតេយ្យទៅលើផ្នែកដីតូចមួយដែលស្ថិតលើប្រាសាទដែលបាក់បែក។ តំបន់នោះបានបង្ហាញនៅក្នុងផែនទី (Resolution 1962) ដំណោះស្រាយគណៈរដ្ឋមន្ត្រីថៃ។
- យោងតាមភាគីថៃ សាលដីកាមិនបានដោះស្រាយដែនអធិបតេយ្យនៅសេសសល់ក្រៅពីកំពូលភ្នំព្រះវិហារ និងកំពូលភ្នំត្រាប។

**<u>សេចក្តីសម្រេច</u>៖** តុលាការសម្រេចលើបកស្រាយសាលដីកាឆ្នាំ១៩៦២ ដូចខាងក្រោមដោយពិចារណានិងយោងតាមអំណះអំណាង៖

- តុលាការចាត់ទុកថាអត្ថន័យនៃកថាខណ្ឌទី១(សាលដីកាឆ្នាំ១៩៦២) គឺមានភាពច្បាស់លាស់។ នៅក្នុងកថាខណ្ឌនេះ តុលាការបានគាំទ្រលើការអះអាងដ៏សំខាន់របស់ប្រទេសកម្ពុជាដោយរកឃើញថា ប្រាសាទព្រះវិហារស្ថិតនៅលើទឹកដីនិងក្រោមអធិបតេយ្យភាពនៃប្រទេសកម្ពុជា។
- ក្នុងកថាខណ្ឌទី២ តុលាការបានកំណត់ថាដែនដីកម្ពុជារាប់ចាប់ពីកំពូលភ្នំនៃប្រាសាទព្រះវិហារ បញ្ចាប់ត្រង់ជើងភ្នំត្រាប។ មានន័យថា ដែនអធិបតេយ្យកម្ពុជារាប់ពីដីរាបស្មើរ រហូតដល់ភ្នំ។
- តុលាការពិចារណាថាក្នុងកថាខណ្ឌទី២ តម្រូវឱ្យប្រទេសថៃដកកម្លាំងទ័ពឬកងថៃរក្សារបស់ខ្លួនចេញទាំង

អស់ពីទឹកដីទាំងមូលនៃកំពូលភ្នំនៅទឹកដីកម្ពុជា។

- តុលាការពិចារណាថាពាក្យ "ក្នុងតំបន់ក្បែរប្រាសាទព្រះវិហារ" ដែលស្ថិតលើទឹកដីកម្ពុជា នៅក្នុងកថាខណ្ឌទី ២ និង "តំបន់ប្រាសាទ" នៅក្នុងកថាខណ្ឌទី ៣ សំដៅទៅលើដីតែមួយចំណែកតូចនៃទឹកដីនោះ។ កាតព្វកិច្ចដែលតុលាការបានកំណត់ទាក់ទងនឹងដីតែមួយចំណែកតូចនៃទឹកដី ត្រូវបានដកស្រង់ចេញពីកថាខណ្ឌទី ១។
- កាតព្វកិច្ចដែលបានកំណត់ក្នុងកថាខណ្ឌទី ២ និងទី ៣ មានទទ្បីករណ៍សមស្របដែលដកស្រង់ចេញពីកថាខណ្ឌទី១នៃការស្វែងរកអធិបតេយ្យភាព។ មានន័យថាទឹកដីប្រាសាទព្រះវិហារអាចកំនត់បានក្នុងកថាខណ្ឌទី ២នឹងទី ៣មានទំនាក់ទំនងគ្នាទៅវិញទៅមក លុះត្រាមានការដកស្រង់ចេញពីកថាខណ្ឌទី១។
- ក្នុងកាលទេសៈទាំងនេះតុលាការមិនចាំបាច់ពិចារណាបន្ថែមទៀតទេ ដើម្បីឆ្លើយសំណួរថាតើសាលដីកាឆ្នាំ ១៩៦២ កំណត់ថាមានអនុភាពគតិយុត្តទៅលើខ្សែបន្ទាត់ព្រំដែនរវាងកម្ពុជានឹងថៃដែរឬទេ។ទាំនេះជាបញ្ហាដែលមានវិវាទកើតឡើងកន្លងមកក្នុងឆ្នាំ១៩៦២ ហើយដែលតុលាការចាត់ទុកថាជាចំណុចសំខាន់នៃជម្លោះបច្ចុប្បន្នជុំវិញការបកស្រាយសាលដីកាឆ្នាំ ១៩៦២ ។
- ក្នុងជម្លោះមួយដែលពាក់ព័ន្ធតែនឹងអធិបតេយ្យភាពលើកំពូលភ្នំព្រះវិហារ តុលាការបានសន្និដ្ឋានថាកំពូលភ្នំមានព្រំប្រទល់ដែលលាតសន្ធឹងនៅខាងជើងទៅខ្សែផែនទីឧបសម្ព័ន្ធទី១។ ប៉ុន្តែវាមិនអាចលើសពីខ្សែផែនទីឧបសម្ព័ន្ធទី១បានទេ។ [49]

**ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៣** តុលាការយុត្តិធម៌អន្តរជាតិបានប្រកាសជាឯកច្ឆន្ទថា តុលាការមានយុត្តាធិការក្នុង ការបកស្រាយសេចក្តីសម្រេចនាឆ្នាំ១៩៦២ នៃរឿងក្តីប្រាសាទព្រះវិហារ។ តុលាការបានឯកភាពជាឯកច្ឆន្ទដោយ ចៅក្រម១៥ រូប President Tomka; Vice-President Sepúlveda-Amor; Judges Owada, Abraham, Keith, Bennouna, Skotnikov, Cançado Trindade, Yusuf, Greenwood, Xue, Donoghue, Gaja, Sebutinde, Bhandari; Judges ad hoc Guillaume, Cot ; Registrar Couvreur ដោយបានវិនិច្ឆ័យថា៖ "**កម្ពុជាមានអធិបតេយ្យលើទឹកដីទាំង មូលនៃជ្រោយខ្ពស់នៃប្រាសាទព្រះវិហារ ដូចដែលបាន កំណត់ក្នុងកថាខណ្ឌទី៩៨នៃសេចក្តីសម្រេចវិនិច្ឆ័យបច្ចុប្បន្ន និងសម្រេចថាប្រទេសថៃ ត្រូវមានកាតព្វកិច្ចកដ ចេញនៅកម្លាំងយោធានគរបាលឆ្នាំ ឬអ្នកយាមឯទៀតដែលបានបោះតង់នៅទីនោះ។**"

## ផ្នែកទី២ ៖ រឿងក្តីស្តីពីដែនដីកោះលីហ្គីតាន់ (Ligitan) នឹងកោះស៊ីប៉ាដាន់ (Sipadan)ឆ្នាំ ២០០២

**ទីតាំងភូមិសាស្ត្រ៖**

[49] https://www.icj-cij.org/en/case/151 ,ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០

កោះស៊ីប៉ាដាន់ (Sipadan) នឹងកោះលីហ្គីតាន់ (Ligitan) ទាំងពីរស្ថិតនៅក្នុងសមុទ្រស៊ីលីបី (Celebes Sea) នៅទិសឦសាន (North-East) នៃឆ្នេរសមុទ្ររបស់កោះបូណេអូ (Borneo) ដែលមានប្រវែង ១៥.៥ nautical miles។

កោះលីហ្គីតាន់ គឺជាកោះតូចមួយ ដែលមានទំហំ ៧.៩ hectare លាតសន្ធឹង ទៅដល់ទិសអគ្នេយ៍(Southern) នៃឆ្នេរសមុទ្រខាងត្បូងនៃ Sabah ប្រទេសម៉ាឡេស៊ី។ កោះនេះមានកូអរដោនេ 4° 09’ North Latitude (រយៈបណ្តោយភាគខាងជើង) និង 118° 53’ East Longitude (រយៈទទឹងភាគខាងកើត)។ វាស្ថិតប្រហែល ២១ nautical miles ពីTanjunng Tutop លើឧបទ្វីបSamporna ក្នុងSabah និង៥៧.៦ nautical miles ពីកោះSebatik របស់ប្រទេសឥណ្ឌូនេស៊ី។ កោះនេះមានសណ្ឋានដីខ្ពស់ជាងរយៈកំពស់ទឹកសមុទ្រនិងសំបូរទៅដោយដីខ្សាច់។ ប៉ុន្តែវាជាកោះមួយដែលដីមិនមានជីវៈជាតិសំរាប់ដំណាំនិងមិនមានព្រៃឈើច្រើនទេ ហើយកោះនេះពុំមានអ្នករស់នៅអចិន្ត្រៃយ៍ទេ។

រីឯកោះស៊ីប៉ាដាន់ ដែលមានទំហាធំជាង កោះលីហ្គីតាន់មានផ្ទៃដីប្រហែល 10.4 hectare និងមានកូអរដោនេ 4° 06’ North Latitude (រយៈបណ្តោយភាគខាងជើង) និង 118° 37’ East Longitude (រយៈទទឹងភាគខាងកើត)។ វាស្ថិតនៅចំងាយ ១៥ nautical miles ពី Tanjung tutop Sabah នឹង ៤២ nautical miles ពីព្រំដែនដីរវាងម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ភាគខាងកើតនៃឆ្នេរសមុទ្រកោះ Sebatik (ពាក់កណ្តាលនៃកោះSebatik ជាកម្មសិទ្ធិរបស់ឥណ្ឌូនេស៊ី)។ កោះនេះមានលក្ខណៈគ្រប់ដណ្តប់ដោយព្រៃឈើ និងមានភ្នំភ្លើង។

យ៉ាងណាមិញកោះទាំងពីរនេះត្រូវបានទុកចោលរហូតដល់ឆ្នាំ១៩៨០។ បច្ចុប្បន្នកោះទាំងពីរនេះត្រូវបានប្រទេសម៉ាឡេស៊ីយកមកប្រើប្រាស់ជាតំបន់ទេសចរណ៍។[50]

**<u>អង្គហេតុ៖</u>**

ប្រទេសទាំងពីរមិនបានយកចិត្តទុកដាក់នឹងប្រកាសទទួលស្គាល់នៅកោះទាំងនោះទេ រហូតដល់ចុងឆ្នាំ១៩៦០។ យ៉ាងណាមិញកោះទាំងពីរនេះស្ថិតនៅជិតឆ្នេរសមុទ្រប្រទេសម៉ាឡេស៊ីជាងឆ្នេរសមុទ្រប្រទេសឥណ្ឌូនេស៊ី។ នៅក្នុងការចរចា កំណត់ដែនដីខ្ពង់រាបបាតសមុទ្រ (Delimitation of the Continental Shelf Boundaries) រវាងភាគីទាំងពីរក្នុងឆ្នាំ១៩៦៩ ភាគីទាំងពីរមិនបានបន្តការពិភាក្សាលើបញ្ហានេះទេ ដោយសារគេយល់ថា វាជាបញ្ហាបច្ចេកទេស "Technical Matters" ទៅលើការកំណត់ដែនដីខ្ពង់រាបបាតសមុទ្រ។ មួយវិញទៀតពួកគេគ្មានអំណាចដើម្បីសំរេចលើ អធិបតេយ្យឬយុត្តាធិការសម្រេចទៅលើបញ្ហា ឬការគ្រប់គ្រងកោះនោះឡើយ។

ការផ្ទុះឡើងនូវជម្លោះកើតឡើងជាថ្មីម្តងទៀតទៅលើអធិបតេយ្យលើការគ្រប់គ្រងកោះទាំងពីរនេះ។ ជាការពិតវិវាទនេះធ្វើឲ្យប៉ះពាល់លើទំនាក់ទំនងទ្វេភាគីដ៏សិទ្ធិម្ចត់ដែលធ្លាប់មានពីមុនមក ក្លាយជាការមើលមុខគ្នាមិនចំដោយមូលហេតុអំពីការបកស្រាយខុសគ្នារវាងប្រទេសទាំងពីរលើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង រវាងប្រទេសហូឡង់

[50] John G.Butcher, The International Court of Justice and the Territorial Dispute between Indonesia and Malaysia in the Sulawesi Sea, page237-238, 2013

និងចក្រភពអង់គ្លេសក្នុងឆ្នាំ១៨៩១ (the Provisions of the 1891 Agreement between the Dutch and the Great Britain) ដែលជាអាណាព្យាបាលរបស់ពួកគេ។ ដូច្នេះប្រទេសទាំងពីរចាប់ផ្តើមជំរុញការស្រាវជ្រាវ នឹងរុករកនៅវត្ថុឬស្លាក់ស្លាមដែលនៅសល់ ជាពិសេសនៅជំនាន់អាណានិគម។ អាស្រ័យហេតុនេះ ការអះអាងរបស់ភាគីជម្លោះក៏ចាប់ផ្តើមកើតឡើងជាបន្តបន្ទាប់។

ជាបឋមប្រទេសទាំងពីរបានសម្រេចធ្វើការចរចាដោយផ្ទាល់ដើម្បីស្វែងរកដំណោះស្រាយ។ ប៉ុន្តែអស់រយៈពេលជាច្រើនឆ្នាំ មិនទទួលបានផលអ្វីឡើយ។ ដោយសារតែបញ្ហាជាប់គាំងនយោបាយ ប្រទេសឥណ្ឌូនេស៊ីបានស្វែងរកដោះស្រាយតាមរយៈយន្តការ "Third Party" តតីយភាគី។ ឥណ្ឌូនេស៊ីបានណែនាំយន្តការ ការបញ្ចុះបញ្ចូលភាគី "Good offices" របស់ ASEAN High Council ដែលបានកំណត់ក្នុងសន្ធិសញ្ញាស្តីពីកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) បង្កើតឡើងក្នុងថ្ងៃទី២៤ខែកុម្ភៈឆ្នាំ១៩៧៦។ យោងតាមមាត្រា១៥ បានកំណត់ថា "ប្រសិនវិវាទមិនអាចដោះស្រាយតាមរយៈការចរចាដោយផ្ទាល់រវាងភាគីជម្លោះ។ The High Council ដែលមានសមាជិកតំណាងមកពីថ្នាក់រដ្ឋមន្ត្រីនៃសមាជិកASEANនីមួយៗគឺជាអ្នកផ្តល់អនុសាសន៍ឲ្យភាគីជ្រើសរើសដំណោះស្រាយត្រឹមត្រូវមួយតាមរយៈ ការបញ្ចុះបញ្ចូលភាគី(Good Offices) សន្ធានកម្ម (Mediation) កិច្ចការអង្កេត (Inquiry) ឬកិច្ចការផ្សះផ្សា (Conciliation)។ ក្នុងករណីចាំបាច់ The High Council គួរផ្តល់នូវអនុសាសន៍ទៅលើយន្តការសមស្របដើម្បីការពារ វិវាទកុំឲ្យធ្ងន់ធ្ងរ។"

យ៉ាងណាមិញម៉ាឡេស៊ីមិនគាំទ្រសំណើរនេះទេ ដោយសារបញ្ហាទំនាស់ព្រំដែនទ្វេភាគីជាមួយបណ្តាប្រទេសអាស៊ានជាច្រើននៅពេលនោះ ហើយមានមទិលសង្ស័យលើ The High Council មិនមានភាពយុត្តិធម៌ក្នុងដំណើរការនៃនីតិវិធី។ ដូចនេះវិវាទការទូតត្រូវបានជាប់គាំងម្តងទៀត។ បន្ទាប់មកប្រទេសម៉ាឡេស៊ីបានផ្តួចផ្តើមគំនិតដោះស្រាយជម្លោះជាមួយប្រទេសឥណ្ឌូនេស៊ីទៅកាន់តុលាការICJ ដោយហេតុថាសេចក្តីសម្រេចរបស់តុលាការមានបុរេនិច្ឆ័យ។ ប៉ុន្តែប្រទេសឥណ្ឌូនេស៊ីបានជំទាស់ ដោយចង់ដោះស្រាយតាមរយៈយន្តការតំបន់ ASEAN ដូចជាការបញ្ចុះបញ្ចូលភាគី(Good Offices) ឬសន្ធានកម្ម (Mediation)ជាដើម។ ដូច្នេះវិវាទនយោបាយបានជាប់គាំងម្តងទៀត។

ជំនួបក្រៅផ្លូវការក្នុងគោលបំណងស្វែងរកដំណោះស្រាយបញ្ចប់នូវវិវាទតាមរយៈការបញ្ជូនប្រេសិតពិសេស "Special Envoys" ពីភាគីឥណ្ឌូនេស៊ីនិងម៉ាឡេស៊ីត្រូវបានធ្វើឡើង។ ភាគីឥណ្ឌូនេស៊ីបានជ្រើសតាំងរដ្ឋលេខាធិការលោក Murdiyono អមដោយនាយកកិច្ចការច្បាប់នៃក្រសួងការបរទេស រីឯប្រទេសម៉ាឡេស៊ីវិញ បានជ្រើសតាំងឧបនាយករដ្ឋមន្ត្រីលោក Anwar Ibrahim អមដោយ មេធាវីមកពីក្រសួងការបរទេស។ ជំនួបកិច្ចប្រជុំក្រៅផ្លូវការជាច្រើនដង រហូតប្រែក្លាយជាផ្លែផ្កានៅខែតុលាឆ្នាំ១៩៩៦ នៅពេលប្រធានាធិបតីនៃប្រទេសឥណ្ឌូនេស៊ី លោក Soeharto បានសំរេចជាចុងក្រោយបំពេញទស្សនកិច្ចផ្លូវការ ទៅកាន់ទីក្រុងKuala Lumpur ប្រទេសម៉ាឡេស៊ី គឺក្នុងគោលបំណងដោយស្រាយជម្លោះតាមផ្លូវតុលាការតាមរយៈតុលាការយុត្តិធម៌អន្តរជាតិនៅទីក្រុងឡាអេ។ ចាប់តាំង

ពីឆ្នាំ១៩៩៧រហូតដល់ឆ្នាំ១៩៩៨ ប្រទេសទាំងពីរបានបង្កើតសេចក្តីព្រាងលើការព្រមព្រៀងគ្នាប្តឹងទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ ដោយសំរេចបាននូវកិច្ចព្រមព្រៀងពិសេស "Special Agreement" ដាក់ទៅកាន់តុលាការICJនៅថ្ងៃទី២ ខែវិច្ឆិកាឆ្នាំ១៩៩៨ បន្ទាប់ពីការចរចាជាច្រើនលើកមក។[51] មាត្រា២នៃកិច្ចព្រមព្រៀងបានបញ្ជាក់ថា តុលាការត្រូវបានស្នើរសុំដើម្បីសំរេចនូវសន្ធិសញ្ញា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលបានផ្តល់ដោយភាគី និងកំណត់អធិបតេយ្យភាពទៅលើកោះលីហ្គីតាន់ និងកោះស៊ីប៉ាដាន់ ថាតើគួរបានទៅលើប្រទេសឥណ្ឌូនេស៊ីឬម៉ាឡេស៊ី។

បន្ទាប់មកភាគីទាំងពីរបានរបៀបចំនូវអង្គហេតុ និងអង្គច្បាប់ និងវិធីសាស្ត្រគតិយុត្ត ព្រមទាំងជួលមេធាវីអន្តរជាតិដើម្បីសំរួលដល់ការបកស្រាយចំពោះមុខតុលាការក្នុងសវនាការ ទើបដល់ថ្ងៃទី១៧ខែធ្នូឆ្នាំ២០០២ តុលាការICJ បានចេញសេចក្តីសំរេចអធិបតយ្យនៃកោះទាំងពីរនេះ។

**<u>ការទាមទារចំបងៗរបស់ភាគីឥណ្ឌូនេស៊ី៖</u>** ប្រទេសឥណ្ឌូនេស៊ីទាមទារកោះទាំងពីរដោយផ្អែកលើការបកស្រាយរបស់ខ្លួនដូចខាងក្រោម៖

- បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងរវាងប្រទេសហូឡង់និងចក្រភពអង់គ្លេសក្នុងឆ្នាំ១៨៩១ (The Provisions of the 1891 Agreement between the Dutch and the Great Britain)
  ក្នុងថ្ងៃទី២០ ខែមិថុនាឆ្នាំ១៨៩១ ដែលបែងចែកទឹកដីនៅក្នុងតំបន់នោះ។ កិច្ចព្រមព្រៀងនេះបង្កើតបាន 4°10’ North Parallel of Latitude ដែលបែងចែកខ្សែព្រំដែនរវាងការគ្រប់គ្រងយ៉ាងច្បាស់រវាងចក្រភពអង់គ្លេសនិងប្រទេសហូឡង់នៅក្នុងតំបន់នោះ។យោងតាមខ្លឹមសារមាត្រាIVនៃកិច្ចព្រមព្រៀង ការបែងចែកខ្សែបន្ទាត់ព្រំដែននៃកោះបូណេអូគឺ "ពី4°10’North Latitude (រយៈបណ្តោយភាគខាងជើង)ទៅទិសខាងកើតនៃឆ្នេរការកំណត់ខ្សែបន្ទាត់ត្រូវតែបន្តទិសខាងកើតបន្ថែមទៀតរហូតដល់ស្របទៅនឹងកោះ Sebatik (កោះតូចមួយនៃផ្នែកឆ្នេរBorneo)។ ផ្នែកមួយនៃកោះដែលស្របស្ថិតនៅទិសខាងជើង គឺស្ថិតការគ្រប់គ្រង់របស់British North Borneo Company និងផ្នែកមួយនៃកោះដែលស្របស្ថិតនៅត្បូងគឺស្ថិតទៅប្រទេសហូឡង់។
- យោងតាមអត្ថន័យនៃមាត្រាIV ចំពោះប្រទេសឥណ្ឌូនេស៊ីយល់ឃើញថា ទឹកដីដែលឆ្លងកោះ Sebatik គួរតែបន្តទិសខាងកើតបន្តទៀតរហូតដល់សមុទ្រ។ ការកំណត់នេះត្រូវតែក្នុង Allocation Line ដែលដែនដីកោះទាំងពីរស្ថិតនៅ4°10’North Latitude (រយៈបណ្តោយភាគខាងជើង) ។ដូចនេះ ទិសខាងជើងនៃ 4°10’ North Latitude ជាកម្មសិទ្ធិរបស់ចក្រភពអង់គ្លេស ដូច្នេះវាក៏ជាកម្មសិទ្ធិរបស់ប្រទេសម៉ាឡេស៊ី។ រីឯទិសខាងត្បូងនៃ 4°10’ North Latitude ជាកម្មសិទ្ធិរបស់ប្រទេសហូឡង់ឬប្រទេសឥណ្ឌូនេស៊ី។
- ក្នុងករណីតុលាការបដិសេធយោងតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងរវាងប្រទេសហូឡង់និងចក្រភពអង់

[51] Hasjim Djalal, Dispute between Indonesia and Malaysia on the Sovereignty over Sipadan and Ligitan Islands, page 10-14, 2013

គ្លេសក្នុងឆ្នាំ១៨៩១ (The Provisions of the 1891 Agreement between the Dutch and the Great Britain) ។ ការទាមទារអធិបតេយ្យភាពនៃកោះទាំងពីរនៅតែបានតាមរយៈ សន្តតិកម្ម(Successor) ពីស្តេច the Sultan of Bulungan ដែលបានចុះកិច្ចសន្យាជាមួយប្រទេសហូឡង់ដែលបង្កើតបានជាលិខិតកម្មសិទ្ធិ (Title)។

- ឥណ្ឌូនេស៊ីបានអះអាងថាខ្លួនបានប្រព្រឹត្តសកម្មភាពនៅក្នុងកោះនោះមានដូចជា ការយាមល្បាតក្នុងតំបន់នោះតាមរយៈនាវារបស់ The Dutch Royal Navy និងសកម្មភាពរបស់កងទ័ពជើងទឹករបស់ប្រទេសឥណ្ឌូនេស៊ីនិងសកម្មភាពរបស់អ្នកនេសាទត្រីឥណ្ឌូនេស៊ី ។

**<u>ការទាមទារចំបងៗរបស់ភាគីម៉ាឡេស៊ី៖</u>** ភាគីប្រទេសម៉ាឡេស៊ីក៏មានការអះអាងរបស់ខ្លួនដើម្បីទាមទារកោះទាំងពីរនេះដែរ ដោយយោងលើសំអាងហេតុមួយចំនួនដូចខាងក្រោម៖

- ការកំណត់ខ្សែព្រំដែន នៃ4°10’ North Latitude បញ្ចប់នៅ Eastern Coast of Sebatik Island និងមិនអាចបន្តខ្សែព្រំដែនទៅទិសខាងកើតនៃសមុទ្រទៀតទេ ដោយសារតែការកំណត់នៃព្រំដែនសមុទ្រ នៅពេលនោះត្រឹមតែ ៣ Miles។ មួយវិញទៀតមិនអាចយកជាការអះអាងបានទេពីព្រោះវាស្ថិតនៅ សមុទ្រអន្តរជាតិ(High Sea)។ដូច្នេះប្រទេសហូឡង់និងចក្រភពអង់គ្លេស មិនបានកំណត់បន្ថែមខ្សែព្រំដែននៅពេលនោះទៀតទេ។
- យោងតាមខ្លឹមសារមាត្រាIV ពាក្យ"ការកំណត់ខ្សែបន្ទាត់ត្រូវតែបន្តទិសកើតបន្ថែមទៀត" បង្ហាញអំពីខ្សែបន្ទាត់ដែលឆ្លងកោះSebatikពីទិសខាងលិចនៃឆ្នេរទៅទិសខាងកើតនៃឆ្នេរប៉ុន្តែមិនអាចបន្តទៅមុខទៀតឡើយ។
- ការគ្រប់គ្រងអធិបតេយ្យនៃកោះទាំងពីរនេះបានមកពីការបន្តនៃលិខិតកម្មសិទ្ធិ(Title) ដែលគ្រប់គ្រងដោយអតីតស្តេច The Sultan of Sulu តាមរយៈសកម្មភាពសន្តតិកម្មរបស់រដ្ឋ (Successive Acts of State)។ ការទទួលបន្តនូវសិទ្ធិនិងករណីយកិច្ចនេះតាមរយៈ ព្រះអង្គ Sultan of Sulu ទៅប្រទេស អេស្ប៉ាញ បន្តទៅប្រទេសអាមេរិក និង បន្តទៅចក្រភពអង់គ្លេសក្នុងនាម The state of North Borneo និងជាចុងក្រោយ ទៅប្រទេសម៉ាឡេស៊ី។ ជាការពិតណាស់ប្រទេសអង់គ្លេសបានគ្រប់គ្រងអធិបតេយ្យនៃកោះទាំងពីរ មុន

ប្រទេសម៉ាឡេស៊ីទទួលបានឯករាជ្យភាព។ មានន័យថា British North Borneo បានគ្រប់គ្រងកោះទាំងពីរបន្តពីស្តេច Sultan of Sulu។

- បន្ថែមពីនេះលិខិតកម្មសិទ្ធិ(Title) បានយោងតាមលិខិតតូបករ(Legal Instruments) ផ្សេងៗដែលបានបញ្ជាក់ពីសកម្មភាពមួយចំនួនលើការកាន់កាប់ជាក់ស្តែង (Effectivités) លើកោះទាំងពីរនេះ។ សកម្មភាពទាំងនោះមានដូចជា ការគ្រប់គ្រងលើការយកអណ្តើកនិងប្រមូលស៊ុតអណ្តើកដែលជាសកម្មភាពសេដ្ឋកិច្ចដ៏សំខាន់នៅក្នុងកោះស៊ីប៉ាដាន់ ជាច្រើនជាឆ្នាំមក ការបង្កើតតំបន់សត្វស្លាប (Bird Sanctuary)ក្នុងកោះស៊ី

ប៉ាដាន់ ក្នុងឆ្នាំ១៩៣៣ និងអាជ្ញាធរនៃអាណានិគម British North Borneo បានសាងសង់បង្គោលភ្លើងហ្វារជាច្រើន(Light Houses) ក្នុងកោះទាំងពីរនៅក្នុងដើមឆ្នាំ១៩៦០ និងសំណង់ទាំងនោះបានសល់រហូតដល់ពេលបច្ចុប្បន្ន និងបានបន្តគ្រប់គ្រងដោយអាជ្ញាធរម៉ាឡេស៊ី។

**<u>សេចក្តីសម្រេចរបស់តុលាការ៖</u>** តុលាការICJ ជឿជាក់ថា មុនឆ្នាំ១៩៦៩ គឺជាពេលវេលាយ៉ាងសំខាន់។ ដូច្នេះសេចក្តីសម្រេចរបស់តុលាការយោងតាមអំណះអំណាងទាក់ទងខ្លឹមសារដែលបានបកស្រាយដោយភាគីទាំងពីរអាស្រ័យលើហេតុផលមួយចំនួនគឺ៖

- យោងតាមខ្លឹមសារមាត្រា IV នៃកិច្ចព្រមព្រៀងរវាងប្រទេសហូឡង់និងចក្រភពអង់គ្លេសក្នុងឆ្នាំ១៨៩១ (The Provisions of the 1891 Agreement between the Dutch and the Great Britain)ក្នុងថ្ងៃទី២០ ខែមិថុនាឆ្នាំ១៨៩១ ពាក្យ "ការកំណត់ខ្សែបន្ទាត់ត្រូវតែបន្តទិសកើតបន្ថែមទៀត"។ តុលាការយល់ឃើញថា តាមរយៈអត្ថន័យនិងគោលបំណងរបស់វា មិនអាចបកស្រាយនៃការបង្កើតនៃ Allocation Line ដែលកំណត់អធិបតេយ្យភាពនៃកោះទាំងនោះបន្តទៅសមុទ្រ និងទៅទិសកើតនៃកោះSebatik បន្តបានទេ ដោយអាស្រ័យតាមរយៈ Travaux Préparatoires[52]មិនគ្រប់គ្រាន់ ។
- ការទាមទារអធិបតេយ្យភាពនៃកោះទាំងពីររបស់ឥណ្ឌូនេស៊ី តាមរយៈសន្តតិកម្ម(Successor) ពីស្តេច The Sultan of Bulungan ដែលបានចុះកិច្ចសន្យាជាមួយប្រទេសហូឡង់គឺសំរេចបដិសេធ។ ដោយសារកិច្ចសន្យាមិនបានកំណត់ឈ្មោះកោះជម្លោះ(កោះលីហ្គីតាន់និងស៊ីប៉ាដាន់)ប៉ុន្តែលើកឈ្មោះកោះចំនួនបីផ្សេងទៅវិញគឺ កោះTerekkan [Tarakan] កោះNanoekan [Nanukan] កោះSebittikh [Sebatik]។
- ចក្រភពអង់គ្លេស បានគ្រប់គ្រងអធិបតេយ្យនៅក្នុងកោះនោះ យ៉ាងមានប្រសិទ្ធិភាពជាង(More Effectively) តាមរយៈសកម្មភាពអធិបតេយ្យដែលមានការអះអាងមួយចំនួន។ សកម្មភាពការកំណត់និងគ្រប់គ្រងប្រមូលស៊ុតអណ្តើក និងការបង្កើតនូវទីតាំងការពារសត្វស្លាប ចាត់ទុកជាការគ្រប់គ្រងរដ្ឋបាលដោយមានប្រសិទ្ធិភាពទៅលើកោះទាំងនោះហើយបានកំណត់ឈ្មោះយ៉ាងច្បាស់លាស់។រីឯការសាងសង់និងគ្រប់គ្រងលើបង្គោលភ្លើងហ្វារជាច្រើន(Light Houses) និងសម្ភារជំនួយនាវាចរណ៍ចាត់ទុកជាទឡ្ហីករណ៍សមស្របនិងគាំទ្រលើការអះអាង។
- ការគ្រប់គ្រងអចិន្ត្រៃយ៍ជាជាងការគ្រប់គ្រងម្តងម្កាល (Sporadic Actions) ឬការគ្រប់គ្រងមិនជាប់លាប់ឬការធ្វើដំណើរទៅជិតនឹងកោះទាំងនោះពីអភិបាលហូឡង់ឬប្រទេសឥណ្ឌូនេស៊ី មិនអាចចាត់ទុកជាអង្គហេតុរឹងមាំដើម្បីទាមទារអធិបតេយ្យភាពកោះទាំងនោះទេ។ ចំពោះសកម្មភាពឯកជនតាមរយៈ អ្នកនេសាទត្រីឥណ្ឌូនេស៊ី មិនអាចកំណត់ថាការកាន់កាប់ជាក់ស្តែងទេ (Effectivités) ប្រសិនពួកគេបាន ស្នើសុំសេចក្តីសម្រេចពីអាជ្ញាធរឬរាជរដ្ឋាភិបាលមានអំណាច។មួយវិញទៀតមិនបានផ្តល់ទឡ្ហីករណ៍គ្រប់គ្រាន់ដែលថា

---

[52] គឺការពិពណ៌នាអំពីឯកសារភស្តុតាងនៃការចរចាការពិភាក្សានិងសេចក្តីព្រាងនៃសន្ធិសញ្ញាចុងក្រោយ

រដ្ឋាភិបាលបានគ្រប់គ្រងដែនសមត្ថកិច្ចនៅលើកោះដោយខ្លួនឯង។

- សកម្មភាពដែលកំពុងកើតឡើងនៅពេលនោះ ទាំងប្រទេសហូឡង់និងប្រទេសឥណ្ឌូនេស៊ី មិនបានបានបង្ហាញការមិនយល់ព្រមឬប្រឆាំងឡើយ។ ក្នុងន័យនេះ ក្នុងឆ្នាំ១៩៦២ និង១៩៦៣ អាជ្ញាធរឥណ្ឌូនេស៊ីមិនបានជំទាស់ការសាងសង់បង្គោលភ្លើងហ្វារ(Light House) នៅពេលនោះទៅកាន់អាជ្ញាធរនៃអាណានិគម North Borneo ឬ ប្រទេសម៉ាឡេស៊ីបន្ទាប់ពីទទួលបានឯករាជ្យ។ ទោះបីជាការអះអាងថាការបង្កើតបង្គោលភ្លើងហ្វារ(Light House) ក្នុងគោលបំណងគ្រាន់តែបង្កើតសុវត្ថភាពដល់នាវាចរនៅក្នុងតំបន់នោះឬ សំរាប់នាវាចរលើសមុទ្រ North Borneo ក៏ដោយការអះអាងបែបនេះមិនចាត់ទុកជាទឡ្ហីករណ៍បានឡើយ។
- តុលាការយុត្តិធម៌អន្តរជាតិបានសំរេច ថាការគ្រប់គ្រងពេញទីត្រូវបានកាន់កាប់ដោយប្រទេសអង់គ្លេស និងម៉ាឡេស៊ី ដែលមានការគ្រប់គ្រងអធិបតេយ្យទៅលើកោះពីរនេះ រីឯប្រទេសហូឡង់ឬឥណ្ឌូនេស៊ីមិនបានទាមទារទេហូតដល់ឆ្នាំ១៩៦៩។

យោងតាមខ្លឹមសារខាងលើនេះ សាលដីការបស់តុលាការយុត្តិធម៌អន្តរជាតិបានបោះឆ្នោត នឹង សំរេចថាប្រទេសម៉ាឡេស៊ីមានអធិបតេយ្យនៃកោះទាំងពីរនេះដោយមានសំឡេង ១៦ ទល់និង ១។ មានចៅក្រមគាំទ្រ ១៦រូប (President Guillaume; Vice-president Shi; Judges Oda, Ranjeva, Herczegh, Fleischhauer, Koroma, Vereshchetin, Higgins, Parra-Aranguren, Kooijmans, Rezek, Al-Khasawneh, Buergenthal, Elaraby; Judge ad hoc Weeramantry) នឹងមិនគាំទ្រមួយរូបគឺចៅក្រម Judge ad hoc Franck។[53]

[53] https://www.icj-cij.org/en/case/102 ,ចូលទស្សនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទាក់ទងប្រធានបទស្តីពី "យន្តការនៃការដោះស្រាយវិវាទដោយសន្តិវិធីក្នុងក្របខណ្ឌអន្តរជាតិ" រួចមកយើងសង្កេតឃើញថា វិវាទនៅក្នុងក្របខណ្ឌអន្តរជាតិថ្វីត្បិតតែអង្គការសហប្រជាជាតិដែលបានបង្កើតឡើងដើម្បីថែរក្សា សន្តិភាព និងសណ្តាប់ធ្នាប់ពិភពលោក ស្ថានភាពនៅក្នុងទំនាក់ទំនងអន្តរជាតិមានភាពតានតឹងនៅឡើយ ដោយសារការឈរលើផលប្រយោជន៍របស់រដ្ឋនីមួយៗ។ប៉ុន្តែដំណោះស្រាយនៅតែមាន លុះត្រាតែភាគីជម្លោះនីមួយៗមានឆន្ទៈផងដែរ។ប្រសិនបើភាគីមិនចាប់អារម្មណ៍ទៅនឹងដំណោះស្រាយ វិវាទអាចបន្តមានភាពស្មុគស្មាញដដែល។

យ៉ាងណាមិញដំណោះស្រាយដែលរដ្ឋអធិបតេយ្យគួរពិចារណាគឺតាមរយៈផ្លូវតុលាការនៅក្នុងដំណាក់កាលចុងក្រោយគេបង្អស់ដែលត្រូវដោះស្រាយដោយសន្តិវិធីនៅក្នុងជម្លោះណាទាំងអស់។ យ៉ាងណាមិញយន្តការដែលល្អនិងពេញនិយមបំផុតតាមរយៈផ្នែកការទូតគឺ រដ្ឋត្រូវរត់រកការដោះស្រាយដោយ ការចរចារវាងភាគីជម្លោះដោយផ្ទាល់កាន់ឆាប់តែល្អ។ បន្ទាប់មកពឹងពាក់តតិយភាគីក្នុងករណីការជាប់គាំងការទូត តាមរយៈការបញ្ចុះបញ្ចូលភាគី (Good Offices) ឬសន្ធានកម្ម (Mediation)ឬ ការអង្កេត (Inquiry) ឬការផ្សះផ្សា (Conciliation) ឬ យន្តការក្នុងតំបន់ ដូចជាអាស៊ានជាដើម។ជាក់ស្តែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ក្នុងមាត្រា៣៣.(១) បានបកស្រាយពីតួនាទីរបស់ភាគីជម្លោះគួរតែដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការជាមុនសិន ជាជាងស្វែងរកយន្តការតុលាការ។

ក្នុងករណីដែលយន្តការទាំងនោះមិនចេញជាសញ្ញាណល្អហើយវិវាទកាន់តែបន្តនោះ ភាគីជម្លោះអាចដោះស្រាយជម្លោះតាមផ្លូវតុលាការមានពីររបៀបគឺ ការដោះស្រាយជម្លោះតាមផ្លូវតុលាការតាមរយៈមជ្ឈត្តវិនិច្ឆ័យ និងតាមផ្លូវតុលាការយុត្តិធម៌អន្តរជាតិ។ ចំពោះតុលាការមជ្ឈត្តវិនិច្ឆ័យគឺ ជាការដោះស្រាយដោយគោរពគោលការអធិបតេយ្យរដ្ឋជាធំ។ រដ្ឋជាអ្នកកំណត់សមភាពរបស់តុលាការ និង ជាអ្នកជ្រើសរើសចៅក្រមឲ្យមកកាត់ក្តីរបស់ខ្លួន។ សមត្ថកិច្ចរបស់តុលាការត្រូវបានកំណត់ជា បឋមក្នុងកិច្ចព្រមព្រៀងវិនិច្ឆ័យ ប្រសិនបើមាន ការរំលោភសមត្ថកិច្ចក្នុងការអនុវត្តលើសេចក្តីសម្រេចនោះ សេចក្តីសម្រេចគ្មានតម្លៃគតិយុតិឡើយ ហើយមិនអាចបង្ខំទៅលើរដ្ឋបានឡើយ។

រីឯការដោះស្រាយក្នុងតុលាការយុត្តិធម៌អន្តរជាតិគឺ មានតែរដ្ឋនៃសមាជិកខ្លួនដែលអាចដោះស្រាយបាន។ ក្នុងន័យនេះសំដៅលើសមាជិករដ្ឋនៃអង្គការសហប្រជាជាតិនិងរដ្ឋដទៃទៀតដែលបានក្លាយជាភាគីនៃលក្ខន្តិកៈរបស់តុលាការអាចទទួលយកយុត្តាធិការរបស់ខ្លួននៅក្រោមលក្ខខណ្ឌជាក់លាក់។ តុលាការមានសមត្ថភាពដោះស្រាយ វិវាទបានលុះត្រា តែរដ្ឋដែលពាក់ព័ន្ធបានទទួលយកយុត្តាធិការរបស់ខ្លួនតាមមធ្យោបាយមួយឬច្រើនដូចខាងក្រោម៖

- ដោយចូលទៅក្នុងកិច្ចព្រមព្រៀងពិសេសដើម្បីបញ្ជូនវិវាទនេះទៅតុលាការ។

- ដោយគុណវុឌ្ឍិនៃយុត្តាធិការឧទាហរណ៍នៅពេលដែលពួកគេជាភាគីនៃសន្ធិសញ្ញាដែលមានបទប្បញ្ញត្តិដែលក្នុងករណីមានជម្លោះនៃប្រភេទណាមួយ ឬការមិនចុះសម្រុងគ្នាលើការបកស្រាយឬការអនុវត្តន៍សន្ធិសញ្ញាមួយក្នុងចំណោមពួកគេអាចយោងទៅលើឯកសារយោង។
- តាមរយៈប្រសិទ្ធិភាពនៃការប្រកាសដែលធ្វើឡើងដោយ ពួកគេយោងតាមលក្ខន្តិកៈដែលម្នាក់ៗបានទទួលយកយុត្តាធិការរបស់តុលាការជាកាតព្វកិច្ចក្នុង ករណីមានជម្លោះជាមួយរដ្ឋផ្សេងទៀតដែលបានធ្វើសេចក្តីប្រកាសស្រដៀងគ្នា។ សេចក្តីប្រកាសមួយចំនួនដែល ត្រូវដាក់ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិមានការកក់ទុកដោយមិនរាប់បញ្ចូលប្រភេទជាក់លាក់នៃជម្លោះ។

កិច្ចដំណើរការនីតិវិធីអាចត្រូវបានបង្កើតឡើងតាមវិធីមួយក្នុងចំណោមវិធីពីរយ៉ាង៖តាមរយៈការជូនដំណឹងអំពីកិច្ចព្រមព្រៀងពិសេសមួយ។មួយវិញទៀតតាមរយៈពាក្យសុំ៖ពាក្យសុំដែលជាលក្ខណៈឯកតោភាគី។ ការវិនិច្ឆ័យរបស់តុលាការយុត្តិធម៌អន្តរជាតិ គឺបិទផ្លូវតវ៉ារដ្ឋមួយដែលគិតថាភាគីម្ខាងទៀតមិនបានអនុវត្តកាតព្វកិច្ចដែលខ្លួនកំពុងស្ថិតនៅក្រោមសាលក្រមដែលបាន បង្ហាញដោយតុលាការអាចនាំបញ្ហានេះទៅក្រុមប្រឹក្សាសន្តិសុខដែលត្រូវបានផ្តល់អំណាច ឱ្យផ្តល់យោបល់ឬសម្រេចចិត្ត លើវិធានការណ៍ដែលត្រូវអនុវត្តដើម្បីមានប្រសិទ្ធិភាព ការវិនិច្ឆ័យ។

ឧទាហរណ៍រឿងក្តីស្តីពីប្រាសាទព្រះវិហារក្នុងឆ្នាំ២០១៣ និង រឿងក្តីស្តីពីដែនដីកោះលីហ្គីតាន់ នឹងកោះស៊ីប៉ាដាន់ក្នុងឆ្នាំ២០០២ បានបង្ហាញឲ្យឃើញថា រដ្ឋភាគីជម្លោះទំរាំស្វែងរកដំណោះស្រាយតាមផ្លូវតុលាការ ពួកគាត់បានចំណាយពេលជាច្រើនឆ្នាំក្នុងការប្រើប្រាស់យន្តការក្រៅប្រព័ន្ធតុលាការមកដោះស្រាយ ដូចជាការចរចាជាច្រើនលើក។ ដូច្នេះបញ្ជាក់ឲ្យឃើញថាភាគីជម្លោះសុទ្ធតែមានឆន្ទះដោះស្រាយតាមរយៈការទូតឬក្រៅប្រព័ន្ធតុលាការ មុននឹងស្វែងរកអំណាចយុត្តាធិការអន្តរជាតិមកប្រើប្រាស់ដែលស្របទៅនឹងគោលបំណងនៃធម្មនុញ្ញអង្គការសហប្រជាជាតិក្នុងមាត្រា៣៣.(១)។

យោងតាមការបកស្រាយខាងលើ វិវាទកំពុងកើតឡើងត្រូវតែដោះស្រាយដោយសន្តិវិធីជាបន្ទាន់ ។ដូច្នេះសភាពការណ៍ពិភពលោកត្រូវបានធានានឹងរក្សាការពារសន្តិភាព ស្ថិរភាព និងសហប្រតិបត្តិការរវាងរដ្ឋភាគីដែលជាលក្ខខណ្ឌមិនអាចខ្វះបានក្នុងការអភិវឌ្ឍប្រទេសជាតិ។ ការអូសបន្លាយដ៏យូរអង្វែងនៃវិវាទអាចនាំទៅស្ថានការណ៍ជម្លោះកាន់តែមើលមុខគ្នាមិនចំ ដែលធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងការទូត៕

# អនុសាសន៍

នៅទីបញ្ចប់នៃប្រធានបទសារណារបស់យើងខ្ញុំដែលបានផ្តោតសំខាន់ទៅលើ"យន្តការនៃការដោះស្រាយវិវាទដោយសន្តិវិធីក្នុងក្របខណ្ឌអន្តរជាតិ" យើងឃើញថា អង្គការសហប្រជាជាតិដែលត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៤៥ បានជួយរក្សាសន្តិភាពនិងបង្កើតវិបុលភាពដល់ពិភពលោកអស់រយៈពេល៧៥ឆ្នាំ។ យ៉ាងណាមិញអង្គការនេះក៏មិនបានបំពេញភារកិច្ចល្អឥតខ្ចោះនោះទេ ដោយសារតែស្ថានភាពពិភពលោកនៅកន្លែងមួយចំនួនមានភាពតឹងតែងជាពិសេសវិវាទរវាងរដ្ឋនិងរដ្ឋ។ រីឯគូភាគីជម្លោះនៃរដ្ឋក៏ចូលរួមចំនែកដោះស្រាយបញ្ហារបស់ខ្លួនដោយឈរលើឥរិយាបថទន់ភ្លន់ គឺការស្វែងរកសន្តិភាព។

ដូច្នេះយើងខ្ញុំសូមធ្វើការផ្តល់ជាអនុសាសន៍ខ្លះៗដូចខាងក្រោមៈ

- ការដោះស្រាយជម្លោះព្រំដែនដែលទើបចាប់ផ្តើមកើតឡើង រដ្ឋភាគីជម្លោះនីមួយៗគួរខិតខំប្រឹងប្រែងដោះស្រាយទាំងពីរ របៀបដើម្បីបន្ថយភាពតានតឹងគឺ**ទី(១)** តាមផ្នែកការទូតនិងផ្នែកច្បាប់ ពោលគឺតាមរយៈការចរចានិងប្រើប្រាស់ច្បាប់នឹងបទដ្ឋានគតិយុត្ត។ ប្រសិនជាក្នុងករណីចំបាច់គឺបញ្ជូនបញ្ហាទៅតុលាការដើម្បីការពារនឹងបកស្រាយដើម្បីការពារអធិបតេយ្យរបស់ខ្លួន។ រីឯរបៀប**ទី(២)** គឺការបញ្ជូនកងកម្លាំងទ័ពក្នុងន័យការការពារខ្លួននៅក្នុងតំបន់នោះ យោងតាមសន្ធិសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិឬរដ្ឋធម្មនុញ្ញកុំឲ្យខ្មាន់ចូលមកឈ្លានពាននឹងបំផ្លាញសម្បត្តិវប្បធម៌។ឧទាហរណ៍រឿងក្តីស្តីពីប្រាសាទព្រះវិហារ ក្នុងឆ្នាំ២០១៣។
- ចំពោះវិវាទទើបចាប់ផ្តើមកើតឡើងការបន្តនីតិវិធីតុលាការដើម្បីដោះស្រាយបញ្ហាអធិបតេយ្យភាពដែនដីមាននូវហានិភ័យជាច្រើនពីព្រោះដំណោះស្រាយជាទូទៅមានលក្ខណៈ "ឈ្នះឬចាញ់"។ ដូច្នេះរដ្ឋភាគីជម្លោះគួរតែដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការជាមុនសិន គឺឲ្យគូភាគីជម្លោះដោះស្រាយដោយសន្តិវិធីហើយសេចក្តីសម្រេចកើតចេញពីភាគីទាំងសងខាងនោះធ្វើការអនុវត្តន៍ដោយស្ម័គ្រចិត្តដើម្បីជម្លោះកុំឲ្យកើតឡើងបន្ត។
- តែបើភាគីជម្លោះណាមួយមិនពេញចិត្តនូវយន្តការក្រៅប្រព័ន្ធតុលាការ នោះការជ្រើសរើសអាចយក យន្តការដោះស្រាយតាមប្រព័ន្ធតុលាការបាន ព្រោះថាសេចក្តីសម្រេចនេះមានអនុភាពចាប់បង្ខំ ប្រតិបត្តិតាមនិងចងភ្ជាប់កាតព្វកិច្ចគូភាគីនៃជម្លោះ។ ជាក់ស្តែងរឿងក្តីស្តីពីប្រាសាទព្រះវិហារ ក្នុងឆ្នាំ២០១៣ និង រឿងក្តីស្តីពី ដែនដីកោះលីហ្គីតាន់ នឹងកោះស៊ីប៉ាដាន់ក្នុងឆ្នាំ២០០២។
- ក្រៅពីឆន្ទៈរបស់រដ្ឋក្នុងការដោះស្រាយជម្លោះ សារពត៌មានក៏មានតួនាទីសំខាន់ក្នុងការផ្តល់ព័ត៌មានទៅដល់មហាជនផ្សេងទៀតដែរ។ សារពត៌មានទាំងឯកជននឹងរដ្ឋមានតួនាទីសំខាន់ក្នុងការពាំនាំនូវពត៌មានទៅដល់អ្នកផ្សេងទៀត ក្នុងការផ្សព្វផ្សាយ ឲ្យមហាជនបានដឹងអំពី ហេតុការណ៍នៃវិវាទនីមួយៗ។ ប្រសិនសារពត៌មាន លម្អៀងមិនត្រឹមត្រូវតាមវិជ្ជាជីវៈដូចជា ការញុះញង់ បំផុសបំផុល នាំឲ្យមានការប្រើភាសា

ហិង្សា ឬផ្សព្វផ្សាយពត៌មានក្លែងក្លាយ(Fake News) អាចនាំឲ្យមានចលាចលដល់ទំនាក់ទំនងការទូតផង ដែរ។ ការផ្សាយពត៌មានចេញទៅត្រូវមានគោលការណ៍សំខាន់៎៤គឺ ទី(១)ជាពត៌មានដែលមានឯករាជ្យ ភាព គឺស្ថិតក្នុងខ្សែកណ្ដាលមួយ ដោយមិនលំអៀងទៅរកទំនោរណាទាំងអស់ និងផ្ដល់ប្រយោជន៍សាធារ ណៈជនជាធំ។ ទី(២)ពត៌មានបន្ថយភាពឈឺចាប់គឺមានភាពយល់យោគ និងកាត់បន្ថយអ្នករងគ្រោះ ដោយសារពត៌មាន។ទី(៣) ពត៌មានស្វែងរកការពិត គឺការផ្សព្វផ្សាយ នៅអ្វីដែលពិតប្រាកដ មិនក្លែងក្លា យ។ចុងក្រោយការទទួលខុសត្រូវនៃការផ្សាយឬសរសេរពត៌មានសំដៅលើបុគ្គលឬនីតិបុគ្គលផ្សព្វផ្សាយ ពត៌មាន ឬគ្រឹះស្ថានសារពត៌មានត្រូវមានទំនួលខុសត្រូវ។

សរុបមកការដោះស្រាយវិវាទដោយសន្តិវិធីក្នុងក្របខណ្ឌរវាងរដ្ឋភាគីជម្លោះនិងរដ្ឋភាគីជម្លោះគឺអាស្រ័យ លើឆន្ទះរបស់រដ្ឋភាគីជម្លោះ យកចិត្តទុកដាក់លើផ្ដល់តម្លៃសន្តិភាព កិច្ចសហប្រតិបត្តិការល្អ ព្រមទាំងគោល ការណ៍អ្នកជិតខាងល្អ។ លើសពីនេះ សន្តិភាព មិត្តភាព និងការអភិវឌ្ឍនៅតាមតំបន់ព្រំដែននិងទំនាក់ទំនង រវាងរដ្ឋនិងរដ្ឋកាន់តែប្រសើរ។៕

# ឯកសារយោង

## ឯកសារជាតិ

### ១. សៀវភៅទ្រឹស្ដីទូទៅ

- សាស្ត្រាចារ្យអនុបណ្ឌិត នួន សុធិមន្ត. ច្បាប់ការទូត. បោះពុម្ពឆ្នាំ២០០៤
- ពុទ្ធសាសនបណ្ឌិត. វចនានុក្រមខ្មែរ. សម្ដេច ជួន ណាត. ឆ្នាំ១៩៦៧.ភ្នំពេញ
- នីតិអន្តរជាតិសាធារណៈ. រៀបរៀងដោយ សាស្ត្រាចារ្យ អ៊ឹង រដ្ឋា. បោះពុម្ពលើកទី៨.ឆ្នាំ២០១៨
- សេចក្ដីផ្ដើមវិទ្យាសាស្ត្រនយោបាយ. រៀបរៀងដោយ បណ្ឌិត ឈុន ណារ៉េត. បោះពុម្ពលើកទី៤.ឆ្នាំ ២០១២
- ទំនាក់ទំនងអន្តរជាតិ.រៀបរៀងដោយ សាស្ត្រាចារ្យ ជុំ អ៊ីម. បោះពុម្ពលើកទី២.ឆ្នាំ២០១១
- មជ្ឈត្តការអន្តរជាតិ ស្ថាប័ន និង នីតិវិធី. រៀបរៀងដោយ ផល ពិសាល. បោះពុម្ពលើកទី១.ឆ្នាំ២០២០
- ពីភ្នំពេញទៅកាន់ក្រុងញូវយ៉ក តើគេធ្វើអ្វីខ្លះនៅអង្គការសហប្រជាជាតិ?. រៀបរៀងដោយ យោងចាន់សុភារ. បោះពុម្ពលើកទី១.ឆ្នាំ២០១៧
- ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ.រៀបរៀងដោយ វិទ្យាស្ថានសភាកម្ពុជា. បោះពុម្ពលើកទី១.ឆ្នាំ២០១៥
- ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា. រៀបរៀងដោយ មេធាវី ស៊ីវិន អ៊ែម អូស្ទើរមីឡើរ៍. បោះពុម្ពលើកទី២.ឆ្នាំ២០១០
- ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ. រៀបរៀងដោយ មូលនិធិអាស៊ី. បោះពុម្ពលើកទី១.ឆ្នាំ២០០១

## ឯកសារអន្តរជាតិ

### ២.ច្បាប់អន្តរជាតិ

- ធម្មនុញ្ញអង្គការសហប្រជាជាតិ(អនុម័តនៅថ្ងៃ ២៦ ឧសភា ឆ្នាំ១៩៤៥ និងចូលជាធរមានថ្ងៃទី ២៤ តុលា ឆ្នាំ១៩៤៥)
- លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ(អនុម័តនៅថ្ងៃទី ២៦ ឧសភា ឆ្នាំ ១៩៤៥ និងចូលជាធរមានថ្ងៃទី២៤ តុលា ឆ្នាំ ១៩៤៥)
- វិធានផ្ទៃក្នុងនៃតុលាការយុត្តិធម៌អន្តរជាតិ(អនុម័តនៅថ្ងៃទី ១៤ មេសា ឆ្នាំ ១៩៤៥ និងចូលជាធរមានថ្ងៃទី០១ កក្កដា ១៩៧៨)
- General Act for the Pacific Settlement of International Disputes, 1949

- Manila Declaration on the Peaceful Settlement of International Disputes,1982
- Declaration on Principles of International law Concerning Friendly Relations and Co-operation Among States in Accordance with the Charter of the United Nations,1970
- Treaty of Amity and Cooperation in Southeast Asia, 1976
- Vienna Convention on Diplomatic Relations),1961
- Vienna Convention on Consular Relations),1963
- Convention on Special Missions,1969

## ៣. ឯកសារទូទៅ

- The International Court of Justice and the Territorial Dispute between Indonesia and Malaysia in the Sulawesi
- Dispute between Indonesia and Malaysia on the Sovereignty over Sipadan and Ligitan Islands
- Daniel S. PAPP. Comtemporary International Relations Frameworks for Understanding. Sixth Edition,2002

## ៤.គេហទំព័រ

- http://www.icj-cij.org (តុលាការយុត្តិធម៌អន្តរជាតិ)
- www.pca-cpa.org (តុលាការអចិន្ត្រៃយ៍កណ្តាល)
- https://www.icj-cij.org/en/case/102
- https://www.icj-cij.org/en/members
- https://en.wikipedia.org/wiki/International_Court_of_Justice
- https://www.icj-cij.org/en/history
- https://www.icj-cij.org/en/case/151
- https://casebook.icrc.org/case-study/cambodiathailand-border-conflict-around-temple-preah-vihear
- http://www.rfi.fr/km/preah-vihear-case-icj-1962
- https://km.wikipedia.org/wiki/ប្រាសាទព្រះវិហារ
- https://www.un.org/en/sections/issues-depth/global-issues-overview/index.html
- https://www.crisisgroup.org/global/10-conflicts-watch-2020
- https://owlcation.com/social-sciences/The-Main-Reasons-For-War
- https://www.thestreet.com/politics/what-is-nationalism-14642847
- https://www.rfi.fr/km/hitler-and-nazi-party-in-germany,
- https://thmeythmey.com/?page=detail&id=37080
- https://www.ushmm.org/genocide-prevention/countries/bosnia-herzegovina/case-study/background/1992-1995

# ឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

# ជំពូកទី១

# សញ្ញាណទូទៅនៃវិវាទក្នុងទំនាក់ទំនងអន្តរជាតិ

# ជំពូកទី២

# យន្តការនៃការដោះស្រាយជម្លោះអន្តរជាតិ

# ជំពូកទី៣

# ករណីសិក្សាស្តីពីដំណោះស្រាយ វិវាទតាមរយៈតុលាការយុត្តិធម៌ អន្តរជាតិ

# សេចក្តីសន្និដ្ឋាន

# អនុសាសន៍

# ឯកសារយោង

# បញ្ជីឧបសម្ព័ន្ធ

១. Charter of The United Nations

២. Statute of The International Court of Justice

៣. Rules of Court

៤. Resolutions Adopted on the Reports of the Sixth Committee

៥. Manila Declaration on the Peaceful Settlement of International Disputes

៦. Request for Interpretation of the Judgement of 15 June 1962 in the Case Concerning the Temple of Preah Vihea (Cambodia v. Thailand) Judgement of 11 November 2013

៧. **រូបភាព៖ ផែនទីឧបសម្ព័ន្ធទី ១**

៨. Case Concerning Sovereignty Over Pulau Ligitan and Pulau Sipadan (Indonesia/Malaysia) Judgement of 12 December 2002

៩. **រូបភាពទី១៖ កោះលីហ្គីតាន់នឹងកោះស៊ីប៉ាដាន់**

១០. **រូបភាពទី២៖ កោះលីហ្គីតាន់នឹងកោះស៊ីប៉ាដាន់**